ការរៀនតាមរយៈការលេង និងបរិស្ថានសំដៅលើការអប់រំដើម្បីអភិវឌ្ឍបំណិនផ្សេងៗរបស់កុមារ តាមរយៈបទពិសោធ និងការលេងជាមួយបរិស្ថានមនុស្ស ធម្មជាតិ និងសង្គម-វប្បធម៌ដោយខ្លួនឯង។

ទម្លាប់រស់នៅល្អ មិត្តភាពបវរ អនាគតរុងរឿង

JICA

Social Welfare Corporation
TENRYU-KOHSEIKAI

SVA
Shanti Volunteer Assoc.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការរៀបចំបរិស្ថានសិក្សាតាមរយៈការលេង សម្រាប់កុមារតូច






នាយកដ្ឋានអប់រំកុមារតូច អង្គការសន្តិស្ម័គ្រចិត្ត (SVA)
ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការរៀបចំបរិស្ថានសិក្សាតាមរយៈការលេង សម្រាប់កុមារតូច









នាយកដ្ឋានអប់រំកុមារតូច    អង្គការសន្តិស្ម័គ្រចិត្ត (SVA)

ឆ្នាំ២០២៤

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡាបានអភិវឌ្ឍកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍកុមារតូចពេញលេញ និងគ្រប់ជ្រុងជ្រោយ កែលម្អលទ្ធផលសិក្សាពេញមួយជីវិតរបស់កុមារកម្ពុជាឱ្យពួកគេក្លាយជាមនុស្សពេញវ័យប្រកបដោយគុណសម្បទាពលរដ្ឋសកល និងដើម្បីកសាងសង្គមកម្ពុជាមានភាពចម្រើនរុងរឿង និងសុខសន្តិភាព។

ការអភិវឌ្ឍកុមារតូច គឺជាអន្តរកម្មជាមួយកុមារទៅនឹងបរិស្ថាន វត្ថុ មនុស្ស ធម្មជាតិ និងបាតុភូត ដែលនៅជុំវិញ។ ក្នុងដំណាក់កាលនេះ កុមារតូចចាប់ផ្ដើមចេះសង្កេត បទពិសោធន៍ មានទម្លាប់ល្អ កត់សម្គាល់ព្រឹត្តការណ៍ដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងបរិស្ថានតាមរយៈសកម្មភាពការលេងបែបធម្មជាតិ ឬសម្ភារៈផ្សេងៗ។

ដើម្បីឱ្យកុមារមានការអភិវឌ្ឍប្រកបដោយភាពឆ្លើយតប សាលាមត្តេយ្យសិក្សា និងគ្រូបង្រៀនចាំបាច់ត្រូវមានសមត្ថភាពសម្បូរបែបក្នុងការដឹកនាំ និងផ្ដល់ឱកាសឱ្យកុមារបានអនុវត្តសកម្មភាពលេងជាមួយសម្ភារៈល្បែងសិក្សា ក្នុងបរិស្ថានស្អាត បៃតង សុវត្ថិភាព ផាសុកភាព និងមេត្រីភាពស្របតាមទ្រឹស្ដី **«រៀនតាមរយៈការលេង និងបរិស្ថាន»និង«ការលេងគឺជាការរៀនរបស់កុមារតូច»**។

ផ្អែកលើមូលដ្ឋាននេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារគន្លឹះជាជំនួយផ្នែកវិធីសាស្ត្រសម្រាប់គ្រូបង្រៀនមត្តេយ្យសិក្សាក្នុងការផលិត និងច្នៃប្រឌិតតាមទម្រង់ប្រភេទសម្ភារៈល្បែងសិក្សា និងដំណើរការរៀបចំបរិស្ថានសិក្សា ជាពិសេសវិធីសាស្ត្រអនុវត្តសកម្មភាពនៃការនិទានរឿង ក្នុងគោលដៅអភិវឌ្ឍន៍បំណិនពុទ្ធិ និងបំណិនមិនមែនពុទ្ធិរបស់កុមារតូច ឱ្យកាន់តែប្រសើរឡើង តាមលក្ខណៈវិទ្យាសាស្ត្រ។

ក្រសួងអប់រំ យុវជន និងកីឡា មានសុទិដ្ឋិនិយមថា គ្រប់អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងគ្រូបង្រៀនមត្តេយ្យសិក្សា នឹងចូលរួមសហការនិងគាំទ្រដល់ការអនុវត្តឯកសារនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កុមារតូចនៅកម្ពុជា ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា ជាប្រធានគណៈកម្មការគ្រប់គ្រងនិងរៀបចំចងក្រងឯកសារ **ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) អង្គការសន្តិស្ម័គ្រចិត្ត(SVA)** ជាពិសេស**សាជីវកម្មសុខុមាលភាព ចិនរីយុ កូសេកៃ(TKK) ប្រទេសជប៉ុន មន្ត្រីជំនាញនាយកដ្ឋានអប់រំកុមារតូច** ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួម និងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ដឹកនាំរៀបចំតាក់តែងឯកសារសម្រាប់ការអប់រំកុមារតូចនេះ ឱ្យសម្រេចជាផ្លែផ្កាឡើងនាខណៈនេះ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| លោកជំទាវ **គឹម សេដ្ឋានី** | លោកជំទាវ **ឃុន រចនា** | ឯកឧត្តម **ពុត សាមិត្ត** |
| ឯកឧត្តម **ឡោ ឆវណ្ណា** | ឯកឧត្តម **ប្រាក់ កុសល** | លោកស្រី **ផ្លុង មុនីកុសល** |
| ឯកឧត្តម **ឈួន ប៊ុនឈឿន** | លោក **យិន ធី** | លោក **យី សុខគី** |
| លោក **តាកាស៊ី ការសេ** | លោកស្រី **អាយ៉ាណុ គិគុឌិ** | |

## គណៈកម្មការនិពន្ធ

| | | |
|---|---|---|
| លោក **ប៉ាត់ គឹមនីន** | លោក **ឆន ឈាង** | លោកស្រី **ង៉ុយ គឹមច័ន្ទដាវី** |
| លោកស្រី **រ័ត្ន ម៉ារិន** | លោកស្រី **ម៉ៅ ណាវី** | លោកស្រី **ហេង ចាន់ណា** |
| លោកស្រី **សាំនី លីពី** | លោក **សេង រ៉ាស៊ីន** | លោក **ហ៊ឹម កក្កដា** |
| លោកស្រី **សុខ អេង** | លោកស្រី **រស់ សិរិនិមល់** | លោក **សៀង គឹមឈឿន** |
| លោកស្រី **ជា ដូរ៉ានី** | លោកស្រី **ឆៃ ស្រីមុំ** | លោក **គួន ម៉ុងក្រាត់** |
| លោកស្រី **ហួន សុធារ័ត្ន** | លោក **ស៊ីវ ហឿន** | កញ្ញា **យ៉ា ហ្សារីណា** |
| កញ្ញា **ទីង ទិវ័ន** | | |

## ទីប្រឹក្សាបច្ចេកទេស

សាជីវកម្មសុខុមាលភាពសង្គម ចិនរីយូ កូសេកៃ (TKK)

## ក្រុមការងារសម្របសម្រួល

| | | |
|---|---|---|
| លោកស្រី **អាយ៉ាណុ គិគុឌិ** | លោក **យន់ វាសនា** | លោកស្រី **អ៊ីស៊ីសុកា សាគី** |

## គណៈកម្មការពិនិត្យ

| | | |
|---|---|---|
| ឯកឧត្តម **ឈួន ប៊ុនឈឿន** | លោក **យិន ធី** | លោក **យី សុខគី** |
| | លោក **ប៉ាត់ គឹមនីន** | |

## គាំទ្រដោយ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)

## អារម្ភកថា

ឯកសារស្តីពីការរៀបចំបរិស្ថានថ្នាក់រៀនមត្តេយ្យសិក្សាបង្កើតឡើងក្នុងគោលបំណងជួយដល់ការបង្រៀន និងរៀននៅមត្តេយ្យសិក្សាឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព ស្របតាមទ្រឹស្តី«រៀនតាមរយៈការលេង និងបរិស្ថាន» ក្នុងគោលបំណងដើម្បីពន្លឿនដល់ការអភិវឌ្ឍរបស់កុមារតូច។

ឯកសារនេះបានចងក្រងឡើងចូលរួមចំណែកដល់ការអនុវត្តកម្មវិធីសិក្សារដ្ឋរបស់ក្រសួងអប់រំ យុវជន និងកីឡា និងឯកសារ និងស្តង់ដារនៃការរៀបចំថ្នាក់រៀនរបស់មត្តេយ្យសិក្សារដ្ឋ។ លើសពីនេះ គណៈកម្មការនិពន្ធក៏បានទទួលបានធាតុចូលពីពិសោធជាក់ស្តែង និងប្រឹក្សាបច្ចេកទេសពីគ្រូមត្តេយ្យសិក្សានៅសាជីវកម្មសុខុមាលភាពសង្គម ចិនរីយូកូសេកៃ ខេត្តស៊ីហ្សូកា ប្រទេសជប៉ុន ដែលធ្វើឱ្យឯកសារនេះកាន់តែមានខ្លឹមសារសាកល សមស្របតាមបរិបទពិភពលោក។ ការរៀបចំបរិស្ថានឱ្យបានល្អតាមការណែនាំជារឿងសំខាន់មួយ តែអ្វីដែលគ្រូមត្តេយ្យសិក្សាត្រូវពិចារណាគឺតើបរិស្ថាននោះអាចយកទៅប្រើប្រាស់ឱ្យទូលំទូលាយក្នុងសកម្មភាពលេងរបស់កុមារដើម្បីឆ្លើយទៅនឹងតម្រូវការសិក្សា វត្ថុបំណង និងចំណាប់អារម្មណ៍របស់កុមារ។ នៅក្នុងសៀវភៅនេះ យើងបានផ្តល់នូវគន្លឹះក្នុងការរៀបចំបរិស្ថានតាមជ្រុងផ្សេងៗ ពិសេសគឺមានផ្តល់ឧទាហរណ៍ដែលគ្រូមត្តេយ្យសិក្សាបានយកការរៀបចំបរិស្ថាននេះទៅប្រើប្រាស់ក្នុងសកម្មភាពបង្រៀន និងរៀននៅក្នុងមត្តេយ្យសិក្សា។

គណៈកម្មការយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងក្លាយជាឯកសារជំនួយស្មារតីដល់លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធទាំងអស់យកទៅប្រើប្រាស់ ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព។

យើងខ្ញុំរង់ចាំទទួលនូវរាល់មតិស្ថាបនា ផ្តល់ជាគំនិតយោបល់ ក្នុងការចូលរួមចំណែកកែលម្អ ដើម្បីឱ្យឯកសារនេះកាន់តែមានខ្លឹមសារល្អប្រសើរ។

គណៈកម្មការនិពន្ធ និងរៀបរៀង

# មាតិកា


**សេចក្តីផ្តើម** ..... **១**

**ជំពូកទី១ ការរៀបចំបរិស្ថានសិក្សាតាមរយៈការលេង** ..... **២**

១. បរិស្ថានសិក្សាសម្រាប់កុមារតូច ..... ៥

២. ការរៀបចំបរិស្ថានសិក្សា និងការអភិវឌ្ឍរបស់កុមារតូច ..... ៦

៣. ប្រសិទ្ធភាពនៃការរៀបចំបរិស្ថានសិក្សា ..... ៧

៤. គន្លឹះសម្រាប់ការរៀបចំបរិស្ថានសិក្សា ..... ១១

៥. តួនាទី និងការពិចារណារបស់គ្រូបង្រៀន ..... ១២

**ជំពូកទី២ ការរៀបចំបរិស្ថានក្នុងថ្នាក់រៀន** ..... **១៤**

១. ការរៀបចំរដ្ឋបាលថ្នាក់រៀន ..... ១៦

១.១ តារាងទាំង៧ ..... ១៦

១.២ សៀវភៅរដ្ឋបាល ..... ១៨

១.៣ បញ្ជីបញ្ជូនឈ្មោះកុមារឡើងថ្នាក់ ..... ១៩

១.៤ ក្តារខៀនព័ត៌មាន ..... ២០

២. ការរៀបចំសកម្មភាពប្រចាំថ្ងៃ ..... ២៤

២.១ តារាង ..... ២៤

២.២ ធ្នើរដាក់ស្បែកជើងរបស់កុមារ ..... ៣២

២.៣ កន្លែងដាក់សម្ភារៈ និងសម្លៀតរបស់កុមារ ..... ៣៤

២.៤ កន្លែងធ្វើសកម្មភាពផ្សេងៗក្នុងថ្នាក់រៀន ..... ៣៦

៣. ការរៀបចំជ្រុងថ្នាក់ ..... ៤០

៣.១ ជ្រុងវិទ្យាសាស្ត្រ ..... ៤០

៣.២ ជ្រុងអនាម័យ ..... ៥០

៣.៣ ជ្រុងសិល្បៈ ..... ៥២

៣.៤ ជ្រុងល្បែង ..... ៥៨

៣.៥ ជ្រុងសិក្សា ..... ៦៤

**ជំពូកទី៣ ការរៀបចំបរិស្ថានក្រៅថ្នាក់រៀន** ..... **៧៦**

១. ប្រសិទ្ធភាពការអភិវឌ្ឍរបស់កុមារ ..... ៧៨

២. ល្បែងក្រៅថ្នាក់ ..... ៧៩

៣. សួនជីវៈចម្រុះ ..... ៨៨

៤. ទីកន្លែងធ្វើសកម្មភាពផ្សេងៗនៅក្រៅថ្នាក់ ..... ៩៦

៥. កន្លែងទុកដាក់សំរាម ..... ១០២

៦. កន្លែងលាងដៃ ..... ១០៣

៧. បង្គន់អនាម័យ ..... ១០៤

**ឧបសម្ព័ន្ធ** ..... **១០៦**

I.ឧទាហរណ៍ប្លង់នៃការរៀបចំថ្នាក់រៀនមត្តេយ្យសិក្សារដ្ឋ ..... ១០៨

# ទម្រង់ឯកសារសង្ខេប

## ១. ទម្រង់ទូទៅ

ឯកសារនេះបែងចែកជា ៣ ជំពូកដូចខាងក្រោម៖

ជំពូក១ ការរៀបចំបរិស្ថានសិក្សាតាមរយៈការលេង៖ ជាផ្នែកទ្រឹស្តីពណ៌នាអំពីសារៈសំខាន់នៃបរិស្ថានសិក្សាបានសមស្របលើការការអភិវឌ្ឍរបស់កុមារ។

ជំពូក២ ការរៀបចំបរិស្ថានក្នុងថ្នាក់រៀន៖ ពណ៌នាអំពីលំនាំនៃការរៀបចំ និងរបៀបដែលគ្រូមត្តេយ្យសិក្សាធ្លាប់បានអនុវត្តន៍កន្លងមក ដោយផ្តោតទៅលើ៣ផ្នែក៖

- ការរៀបចំផ្នែករដ្ឋបាល៖ តារាងទាំង៧ សៀវភៅរដ្ឋបាល បញ្ជីកុមារឡើងថ្នាក់ ការប្រើប្រាស់ក្តារខៀនព័ត៌មាន។
- ការរៀបចំសកម្មភាពភាពបង្រៀនប្រចាំថ្ងៃ៖ មានតារាងទាំង៥ ដែលគ្រូប្រើប្រាស់ប្រចាំថ្ងៃ។
- ការរៀបចំជ្រុងថ្នាក់៖ សំដៅលើការរៀបចំជ្រុងទាំង៥រួមមានជ្រុងវិទ្យាសាស្ត្រ ជ្រុងអនាម័យ ជ្រុងសិល្បៈ ជ្រុងល្បែង និងជ្រុងសិក្សា។ ក្នុងជ្រុងមួយចំនួនមានឧទាហរណ៍ពិសេស ព្រមទាំងមានពន្យល់បន្ថែមនៅផ្នែកបន្ទាប់។

ជំពូក៣ ការរៀបចំបរិស្ថានក្រៅថ្នាក់រៀន៖ ពណ៌នាពីការរៀបចំបរិស្ថាននៅក្រៅថ្នាក់រៀនដូចជាការរៀបចំសួនជីវៈជម្រុះ កន្លែងធ្វើសកម្មភាពផ្សេងៗ ការទុកដាក់សំរាម លាងសម្អាតដៃជើង និងបង្គន់អនាម័យ។

## ២. ទម្រង់ការរៀបចំជ្រុង

នៅជ្រុង ឬកន្លែងមួយចំនួន មានទម្រង់អត្ថបទចែក ចេញជា២ទំព័រ មាន៣ផ្នែកសំខាន់ៗ ដូចខាងក្រោម៖

១.សេចក្តីផ្តើម៖ ពន្យល់ខ្លឹមសារនៃជ្រុង។

២.លទ្ធផលរំពឹងទុក ឬប្រសិទ្ធភាព៖ ពណ៌នាអំពីការអភិវឌ្ឍសំខាន់ៗដែលកុមារទទួលបានពីការរៀបចំជ្រុង

៣.ការរៀបចំ៖ ផ្តល់នូវគន្លឹះសំខាន់ដល់គ្រូមត្តេយ្យសិក្សា ដើម្បីរៀបចំជ្រុងមួយឱ្យបានសមស្រប ឆ្លើយតបតាមលទ្ធផលរំពឹងទុក

៣.៣. ជ្រុងសិល្បៈ





ជ្រុងសិល្បៈមានមុខងារ២៖ ទីមួយ ជាកន្លែងដាក់តាំងគ្រប់ស្នាដៃរបស់កុមារ ឧបករណ៍ភ្លេងខ្លះៗ និងទីពីរ ជាកន្លែងលេង និងសាកល្បងការងារសិល្បៈដូចជារាំ លេងឧបករណ៍ភ្លេងបុរាណ ឬសម័យ ងាយៗ តុក្កតា ...ដើម ដែលទាក់ទងនឹងកុមារមត្តេយ្យ។ ជ្រុងនេះមានសកម្មភាពផ្សេងៗជាច្រើននៅថ្នាក់មត្តេយ្យសិក្សា ដែលកុមារបានចូលរួមអនុវត្តន៍ និងបង្កើតជាលទ្ធផលសិក្សាហៅថាស្នាដៃកុមារ(សិល្បៈ) ដូចជាបត់រូប គូររូប ហែកបិទតាមស្នាមចុចៗ រោយកម្ទេចកម្ទីតូចៗលើរូប(អាចម៍រណា កម្ទេចក្រដាស ស្លឹកឈើ...) ដោត ដេរ ត្បាញ កាត់បិទរូប ហែកបិទរូប សូនរូប ផលិតសម្ភារៈនានា យកមកដាក់តាំង។

៣.៣.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីឈ្មោះឧបករណ៍ភ្លេងខ្មែរ ទ្រ ស្គរ ឆាប ឈិង... ចំណងជើងបទចម្រៀង ចង្វាក់រាំ ពណ៌សម្លៀកបំពាក់តាមថ្ងៃ សម្លៀកបំពាក់ប្រពៃណី និងព្រឹត្តិការណ៍សង្គម។<br>- ប្រាប់បានពីឈ្មោះសម្ភារៈនានាដែលផលិតបានដូចជារូបកែវ ក្បាលសត្វ ផ្កា សត្វស្លាប ជង្គូវ កន្ទេល សត្វ និងរូបភាពផ្សេងៗ<br>- ប្រាប់ពីរបៀបបត់ រោយ ដោត ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែកបិទ ដែលបានដាក់តាំងស្នាដៃ។ |
| បំណិនសម្បទា | - បង្ហាញពីការប្រើប្រាស់ឧបករណ៍ភ្លេងខ្មែរទ្រស្គរ ឆាប ឈិង ... សម្លៀកបំពាក់ និងសូត្រកំណាព្យ ច្រៀងចម្រៀង ធ្វើកាយវិការ ព្រមទាំងច្រៀងបទនគររាជ ពង្សាវតារខ្មែរបានត្រឹមត្រូវ<br>- បង្កើតបានស្នាដៃតាមរយៈការបត់ក្រដាសបានជារូបផ្សេងៗ សូនរូប រោយ ដេរ ត្បាញ គូរ ផាត់ពណ៌ ហែក និងកាត់បិទ។ |
| ចរិយាសម្បទា | - ស្រឡាញ់ឧបករណ៍ភ្លេងខ្មែរ សម្លៀកបំពាក់ប្រពៃណី ចង្វាក់រាំ និងចូលចិត្តសូត្រកំណាព្យ ច្រៀងបទនគររាជ ពង្សាវតារខ្មែរ និងចម្រៀងថ្នាក់មត្តេយ្យសិក្សា<br>- មានអារម្មណ៍រំភើបសប្បាយរីករាយពេលឃើញស្នាដៃខ្លួនដែលត្រូវបានដាក់តាំង<br>- មានមោទនភាពចំពោះទេពកោសល្យដែលគេបានធ្វើ និងចង់បង្ហាញស្នាដៃខ្លួនទៅអ្នកដទៃ។ |



៣.៣.២. ការរៀបចំ

ក. ការរៀបចំកន្លែងដាក់សម្ភារៈសិល្បៈ៖



- ដាក់តុ ធ្នើរ ឬកញ្ច្រែងតាំងឧបករណ៍ភ្លេងខ្មែរទ្រ ស្គរ ឆាប ឈិង និងសម្ភារៈភ្លេងងាយៗដែលកុមារផលិតបាន។
- តាំងស្នាដៃកុមារលើក្រដាសកាតុងរឹង ផ្ទាំងស្នោរ ផ្ទាំងប្លាស្ទិច ឬក្តារខៀនកម្ទី។
- ជ្រើសរើសពណ៌ខៀវ ឬបៃតងចាស់សម្រាប់ធ្វើផ្ទាំងដាក់តាំងស្នាដៃដើម្បីឱ្យកុមារមើលឃើញរូបភាពបានច្បាស់។
- កម្ពស់ផ្ទាំងរូបភាពនៃជ្រុងសិល្បៈគួរឱ្យសមល្មមនឹងកម្ពស់កុមារ។

ខ. ការដាក់តាំងស្នាដៃកុមារ៖



- ដាក់តាំងស្នាដៃកុមារឱ្យបានច្រើន និងផ្លាស់ប្តូរញឹកញាប់យ៉ាងតិច២ ឬ៣ដងក្នុងមួយខែ។
- ដាក់តាំងស្នាដៃកុមារប្រមូលពីសកម្មភាពថ្នាក់មត្តេយ្យសិក្សាប្រចាំថ្ងៃដូចជាបត់រូប គូររូប ហែកបិតតាមស្នាមចុច រោយកម្ទេចផ្សេងៗលើរូប ដេរ ត្បាញ កាត់បិតរូប ផលិតសម្ភារៈនានា។
- ត្រូវដាក់តាំងស្នាដៃកុមារគ្រប់គ្នាដើម្បីជាការលើកទឹកចិត្តដល់កុមារ។
- ដឹកនាំកុមារចូលរួមតុបតែង ឬដាក់តាំងជ្រុងនេះជាការប្រសើរ ហើយការរៀបចំនេះបម្រើដល់ប្រធានប... ការសិក្សាធ្វើឱ្យកុមារយល់បានកាន់តែច្បាស់។

គ. សោភណភាព



- ការរៀបចំតាំងឧបករណ៍ភ្លេង សម្ភារៈលេងឱ្យមានរបៀបដាក់វត្ថុពីតូចទៅធំតាមលំដាប់លំដោយដើម្បីឱ្យកុមារអាចមើលឃើញសម្ភារៈទាំងនេះបានច្បាស់ងាយស្រួលយកប្រើប្រាស់ និងទុកដាក់ត្រឹមត្រូវ។
- តុបតែងលម្អផ្កាភ្ញីនៅកន្លែងតាំងស្នាដៃកុមារឱ្យមានភាពទាក់ទាញ បង្កើតសោភ័ណភាព ប៉ុន្តែមិនស្មុគស្មាញ។

## ៣. ឧទាហរណ៍

នៅជ្រុងមួយចំនួនមានបន្ថែមផ្នែកពិសេសមួយគឺឧទាហរណ៍ ដែលលើកយកនូវបទពិសោធរបស់គ្រូមត្តេយ្យសិក្សាបានអនុវត្តន៍កន្លងមក ក្នុងគោលបំណងផ្សារភ្ជាប់ទ្រឹស្តី និងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍មាន៤ទំព័រ ចែកចេញជា៤ផ្នែកសំខាន់ៗ ដូចខាងក្រោម៖




<u>១.សេចក្តីផ្តើម៖</u> ផ្តល់នូវព័ត៌មានទូទៅពីសកម្មភាព

<u>២.ព័ត៌មានទូទៅ៖</u> ដូចជាមុខវិជ្ជា វត្ថុបំណង និងរយៈពេលជាដើម

<u>៣.ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ៖</u> ជាអ្វីដែលគ្រូត្រូវធ្វើដើម្បីឱ្យសកម្មភាពអាចដំណើរការទៅបានរហូត និងសម្រេចតាមវត្ថុបំណងដែលបានគ្រងទុក។

- បរិស្ថាន៖ បរិស្ថានទាំង៣ដែលគ្រូត្រូវពិចារណា
- ការចូលរួមរបស់គ្រូ៖ ជាអន្តរកម្មសម្រួលដល់សកម្មភាពរបស់កុមារដូចជាការជួយពន្យល់បន្ថែម ការលើកទឹកចិត្ត ការសរសើរជាដើម។

<u>៤.សកម្មភាពឆ្លើយតប និងលទ្ធផល៖</u> ពណ៌នាអំពីសកម្មភាពដែលបានកើតឡើង អារម្មណ៍និងសម្តីរបស់កុមារ វាយតម្លៃរបស់គ្រូជាដើម

## ៤. គន្លឹះបន្ថែម

ផ្តល់នូវឧទាហរណ៍បន្ថែមសម្រាប់ពង្រីកការយល់ដឹងលើប្រធានបទឱ្យកាន់តែស៊ីជម្រៅ។ ជាឧទាហរណ៍ ជ្រុងវិទ្យាសាស្ត្រអាចរៀបចំ និងប្រើប្រាស់បានច្រើនបែបបត់បែនតាមមុខវិជ្ជានីមួយៗ។



# សេចក្តីផ្តើម

ការអប់រំកុមារតូចត្រូវបានយកចិត្តទុកដាក់ជាវិស័យសំខាន់មួយដោយបណ្តាប្រទេសជាច្រើនជុំវិញពិភពលោក។ ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) រយៈពេល១៥ឆ្នាំ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០៣០ ចំណុចទី៤ ផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡាបានដាក់គោលនយោបាយគាំទ្រការអប់រំ និងគាំពារកុមារតូច។ នៅខែមិថុនា ឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់កម្មវិធីមត្តេយ្យសិក្សារដ្ឋដែលតម្រូវឱ្យគ្រូមត្តេយ្យសិក្សាមានភាពបត់បែនក្នុងការរៀបចំសកម្មភាពថ្នាក់រៀនដើម្បីអភិវឌ្ឍន៍ការរៀនសូត្ររបស់កុមារ។ គោលបំណងក្នុងកម្មវិធីមត្តេយ្យសិក្សារដ្ឋបានកំណត់អំពីវិជ្ជា បំណិន និងចរិយាសម្បទា ហើយ គោលដៅរួមនៃការសិក្សាបានចែងថា «ការសិក្សារៀនសូត្ររបស់កុមារបានចាប់ផ្តើមឡើងពីការប្រើប្រាស់ញាណ និងចិត្តចលភាពតាមរយៈការលេង និងសកម្មភាពដោយផ្ទាល់របស់កុមារ»។

សៀវភៅនេះ បានលើកយកទ្រឹស្តី«រៀនតាមរយៈការលេង និងបរិស្ថាន» សម្រាប់កុមារមត្តេយ្យសិក្សាដើម្បីឆ្លើយតបនឹងគោលបំណង និងគោលដៅរួមខាងលើ។ កុមារគ្រប់រូបកើតមក និងរស់នៅក្នុងបរិស្ថានមិនដូចគ្នាទេ តែអ្វីដែលមិនខុសគ្នានោះ គឺរបៀបរៀនវិញទេ ដែលកុមារម្នាក់ៗតែងតែចូលចិត្ត និងទទួលបានចំណេះដឹង និងបំណិនយ៉ាងច្រើន សម្រាប់អភិវឌ្ឍន៍វិស័យទាំង៥[1] ប្រកបដោយប្រសិទ្ធភាព។

រៀនតាមរយៈការលេង និងបរិស្ថានសំដៅលើការអប់រំ ដែលមានគោលបំណងអភិវឌ្ឍបំណិនផ្សេងៗរបស់កុមារ តាមរយៈបទពិសោធ និងការលេងជាមួយនឹងបរិស្ថានវត្ថុ មនុស្ស និងធម្មជាតិ/បាតុភូតជុំវិញខ្លួនដោយឯករាជ្យ រួចតាមរយៈការលេង និងបទពិសោធទាំងនេះ កុមារទទួលបានចំណេះដឹង និងបំណិនសមស្រប ។

ការលេងជាតម្រូវការបែបធម្មជាតិខានមិនបាន និងជាការងារប្រចាំថ្ងៃរបស់កុមារតូច។ ការលេងមានអត្ថន័យជ្រាលជ្រៅជាងការលេងសប្បាយធម្មតាប្រចាំថ្ងៃ។ ការលេងធ្វើកុមារអភិវឌ្ឍផ្នែកស្មារតី រាងកាយចំណេះដឹង បំណិនរូបវន្ត និងបំណិនអរូបវន្ត(បំណិនមិនមែនពុទ្ធិ) ពោលគឺកុមារនឹងមានបំណិនគិតពិចារណានូវទង្វើដែលបានធ្វើម្តងត្រូវ ម្តងខុសក្នុងពេលលេងល្បែងផ្សេងៗ។ ដើម្បីសម្រេចបាននូវចំណុចខាងលើយើងចាំបាច់ត្រូវរៀបចំបរិស្ថានដែលធានាថាកុមារជាអ្នកគ្រប់គ្រងការលេងដោយខ្លួនឯង។ គ្រូរៀបចំផែនការសកម្មភាព និងបរិស្ថានសមស្រប ដោយដឹកនាំសកម្មភាពឱ្យឆ្លើយតបនឹងវិស័យទាំង៥។ ការលេងដោយសេរីរបស់កុមារមិនអាចសង្ឃឹមថាកុមារបានអភិវឌ្ឍន៍អ្វីដែលគ្រូចង់បាននោះទេ លុះត្រាតែគ្រូជាអ្នកសម្របសម្រួល និងរៀបចំបរិស្ថានសមស្រប ទើបកុមារទទួលបាននូវការអភិវឌ្ឍតាមការរំពឹងទុក។ ឯកសារនេះមានបញ្ចូលនូវខ្លឹមសារ និងមគ្គុទេសន៍ជាច្រើនដើម្បីជួយឱ្យយល់ដឹងកាន់តែច្បាស់អំពីទ្រឹស្តី«រៀនតាមរយៈការលេង និងបរិស្ថាន»។

---

1 វិស័យទាំង៥រួមមាន៖ ១.ការអភិវឌ្ឍរូបរាងកាយ និងសុខភាព ២.ការអភិវឌ្ឍសីលធម៌ និងវប្បធម៌ ៣.ការអភិវឌ្ឍសង្គម និងអារម្មណ៍ ៤.ការអភិវឌ្ឍការយល់ដឹង និងការពិចារណា ៥.ការអភិវឌ្ឍភាសា



# ជំពូកទី ១
# ការរៀបចំបរិស្ថានសិក្សាតាមរយៈការលេង

ការលេងជាផ្នែកមួយដ៏សំខាន់ក្នុងវ័យកុមារភាព។ ប្រភពជាច្រើនបានផ្តល់និយមន័យផ្សេងៗគ្នាលើការលេង។ ខាងក្រោមជាអត្ថន័យនៃការលេង៖

- ជាសកម្មភាពដោយឯកឯង ដោយស្ម័គ្រចិត្ត ប្រកបដោយភាពរីករាយ និងមានភាពបត់បែន ដោយរួមបញ្ចូលគ្នានូវការប្រើប្រាស់រាងកាយ វត្ថុ ប្រើប្រាស់សញ្ញា និងទំនាក់ទំនង។
- ជាសិទ្ធិស្របច្បាប់ក្នុងវ័យកុមារភាព ដែលជាកត្តាកំណត់នូវការអភិវឌ្ឍសំខាន់ៗនៃរូបរាងកាយ បញ្ញា និងទំនាក់ទំនងសង្គម។
- ផ្លាស់ប្តូរតាមពេលវេលា បន្ទាប់ពីកុមារបានរៀនចេះនូវបំណិន ឬឈានដល់ដំណាក់កាលអភិវឌ្ឍណាមួយ។ ការលេងមានដូចជា ការដេញចាប់មេអំបៅនៅទីធ្លាសួនច្បារ ស្លៀកសម្លៀកបំពាក់ធ្វើខ្លាឃ្មុំ សាងសង់អគារពីដុំឈើ ឬប្រគុំតន្ត្រីពីប្រអប់ក្រដាសផ្សេងៗ។
- មិនបង្កគ្រោះថ្នាក់ដល់អ្នកលេង ជាការផ្សារភ្ជាប់ជាមួយបទពិសោធ ជំរុញឱ្យមានការចូលរួម និងមានចម្ងល់។

សរុបមក ការលេងគឺជាការធ្វើសកម្មភាពតាមចំណង់ចំណូលចិត្ត ដើម្បីសប្បាយរីករាយ ជាពិសេសការលេងគឺជាការរៀនរបស់កុមារ។

ក្នុងបរិបទការអប់រំកុមារតូច«លេងគឺជាការរៀន»។ កុមារតូចអភិវឌ្ឍខ្លួនរបស់ពួកគេតាមរយៈបទពិសោធក្នុងបរិស្ថានមានផាសុកភាព និងអំណោយផល ដោយកុមាររីកចម្រើនលើការប្រើប្រាស់ញាណទាំង៥ និងបង្កើនការយល់ដឹងទៅលើបរិមាណ ចំនួន រូបរាងធរណីមាត្រជាដើម នៅពេលកុមារឃើញ ប៉ះ កាន់វត្ថុនានា គេនឹងបង្កើតជាចម្ងល់ផ្សេងៗតាមរយៈសកម្មភាពនេះ។ ឧទាហរណ៍ កុមារលេងសាងសង់អគារពីដុំឈើ។ ដុំឈើមានទំហំ រូបរាង សណ្ឋាន និងពណ៌ផ្សេងៗគ្នា។ នៅពេលតម្រៀបដុំឈើទាំងនោះ កុមារចាប់ផ្តើមសង្កេតឃើញ និងចាប់អារម្មណ៍ពីភាពខុសគ្នាទាំងនេះ ដែលចូលរួមចំណែកការរៀនរបស់គេនៅពេលជួបប្រទះនៅថ្ងៃក្រោយ ដូចជា កុមារនិយាយថា «អូ! វារឹង» «វាមានរាងមូល» «វាមានពណ៌លឿង» «អានេះខ្ពស់ជាង» ជាដើម។

ការរៀបចំថ្នាក់រៀនមានសារៈសំខាន់ណាស់ ធ្វើឱ្យកុមារមានការផ្ចង់អារម្មណ៍ទៅលើសកម្មភាពនានា ដោយជំរុញឱ្យកុមារកាន់តែចង់ចេះចង់ដឹង។ ការរៀបចំសំដៅទាំងក្នុង និងក្រៅថ្នាក់រៀន រួមមានការរៀបចំជ្រុង សួនកុមារ និងបរិស្ថាន។

បរិស្ថានបានជះឥទ្ធិពលដល់ទម្លាប់រស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់កុមារ ដោយស្វែងយល់អំពីបរិស្ថានសណ្តាប់ធ្នាប់ និងផាសុកភាព។ ដូច្នេះកុមារព្យាយាមយកគំរូតាមដោយអនុវត្តន៍ជាក់ស្តែង និងរៀបចំខ្លួនប្រាណគ្រប់ពេលវេលា។ កុមារបានរៀបចំសម្ភារៈឱ្យមានសណ្តាប់ធ្នាប់បន្ទាប់ពីគ្រូណែនាំពីរបៀបធ្វើ និងអនុវត្តន៍មួយជំហានម្តងៗ។ ការរៀបចំនេះមានសារៈសំខាន់ណាស់ដោយផ្តល់នូវចំណេះដឹងដល់កុមារអំពីរបៀបរក្សាអនាម័យ។

ក្នុងនាមជាអ្នកអាណាព្យាបាលកុមារ យើងមិនបាច់ប្រាប់កូនៗរបស់យើងថាគាត់ត្រូវលេងអ្វី ឬត្រូវផ្តល់ភាគលាភអ្វីមួយដើម្បីឱ្យគាត់ទៅលេងអ្វីមួយនោះឡើយ។ ទាំងនេះក៏ដោយសារតែកុមារទំនងជាមាននូវតម្រូវការធម្មជាតិខ្លាំងក្នុងការលេង ហើយការលេងនេះនឹងនាំឱ្យកុមារមានភាពសប្បាយរីករាយ និងចាប់អារម្មណ៍ដោយមិនចាំបាច់នរណាម្នាក់មកផ្តល់រង្វាន់ដល់គាត់ឡើយ។



## ១. បរិស្ថានសិក្សាសម្រាប់កុមារតូច

បរិស្ថានថ្នាក់រៀនមត្តេយ្យសិក្សាមិនមែនសំដៅតែលើភាពស្រស់ស្អាត ការតុបតែងលម្អផ្កាភ្លើស្រស់បំព្រងមានដាំដើមផ្កា ថ្នាក់រៀនរៀបចំបានស្អាត មានអនាម័យ និងគ្មានសំរាមប៉ុណ្ណោះទេ។ បរិស្ថានមានអត្ថន័យទូលំទូលាយ និងមានគោលបំណងជំរុញការអភិវឌ្ឍរបស់កុមារសមស្របតាមទ្រឹស្តី«រៀនតាមរយៈការលេង និងបរិស្ថាន»។

ការរៀបចំបរិស្ថានសមស្របជួយសម្រេចបាននូវវត្ថុបំណងជាក់លាក់ តាមរយៈការធ្វើអន្តរកម្មដោយផ្ទាល់របស់កុមារ និងបរិស្ថាន ក្នុងពេលធ្វើសកម្មភាពផ្សេងៗ ហើយកុមារទទួលបានបទពិសោធនជាច្រើន។ គ្រូត្រូវរៀបចំបរិស្ថានសមស្រប ដោយផ្តោតលើស្ថានភាពរស់នៅ វ័យ និងតម្រូវការរបស់កុមារជាសំខាន់។ គ្រូត្រូវបង្កើតស្ថានភាពចាំបាច់ដោយផ្សារភ្ជាប់ ទីកន្លែង ពេលវេលា លំហ មនុស្ស សត្វ វត្ថុ ធម្មជាតិ ឬបាតុភូតជុំវិញខ្លួន ដែលជាគោលដៅនៃការសិក្សា។

គេចែកបរិស្ថានជា៣ ដូចក្នុងដ្យាក្រាម៖




| | |
|---|---|
| បរិស្ថានធម្មជាតិ | អាកាសធាតុ វត្ថុធម្មជាតិ បាតុភូត លំហ និងពេលវេលាជាដើម។ |
| បរិស្ថានសង្គម វប្បធម៌ | អគារសិក្សា គ្រឿងសង្ហារិម ឧបករណ៍កំសាន្ត សម្ភារៈ បរិក្ខាររៀន និងបង្រៀនប្រចាំថ្ងៃដែលជាវត្ថុទាក់ទងនឹងការកំសាន្ត វត្ត ពិធីបុណ្យផ្សេងៗ និងការរស់នៅរបស់កុមារ។ |
| បរិស្ថានមនុស្ស | អ្នកថែទាំ មិត្តភក្តិ និងមនុស្សជុំវិញខ្លួនជាដើម។ |

## ២. ការរៀបចំបរិស្ថានសិក្សា និងការអភិវឌ្ឍរបស់កុមារតូច

**កុមារតូចមានចរិតលក្ខណៈ៖**

- ផ្ទង់អារម្មណ៍ទៅលើការលេងក្នុងបរិស្ថានអំណោយផលដល់ការលូតលាស់ និងប្រើប្រាស់ ការស្រមើស្រមៃ។
- ចាប់អារម្មណ៍លើល្បែងលេង ឬសម្ភារៈរៀនដោយសារបទពិសោធលេង ហើយលេងប្រកបដោយអារម្មណ៍ស្រឡាញ់ពេញចិត្ត រួចចាប់ផ្ដើមចាប់អារម្មណ៍ពិភពខាងក្រៅ។
- ផ្ទង់អារម្មណ៍ទៅលើការលេងប្រកបដោយភាពពេញចិត្ត ក្នុងបរិស្ថានមានផាសុកភាពដូចជាជ្រុងថ្នាក់រៀនដែលមានជ្រុងសិក្សា ជ្រុងល្បែង ជ្រុងវិទ្យាសាស្ត្រ ជ្រុងសិល្បៈ និងជ្រុងអនាម័យ កន្លែងទុកដាក់ឯកសារគ្រូ សម្ភារៈតុបតែងលម្អថ្នាក់រៀនជាដើម និងជាបន្តបន្ទាប់ កុមារនឹងកាន់តែមានចំណាប់អារម្មណ៍ស្វែងយល់ទៅលើវត្ថុទាំងអស់នោះ។
- មានចំណាប់អារម្មណ៍ថាមានទំនាក់ទំនងជាមួយអ្វីដែលនៅជុំវិញខ្លួនគេ និងចង់ប៉ះពាល់វាដោយប្រុងប្រយ័ត្ន។
- ជ្រើសរើសនូវសម្ភារៈរៀនដែលគេពេញចិត្តលេង ហើយក្រោយមករៀបចំរបស់ទាំងនោះឱ្យមានសណ្ដាប់ធ្នាប់ដោយខ្លួនគេផ្ទាល់។
- ចាប់ផ្ដើមចាប់អារម្មណ៍លើរូបរាង និងតួអក្សរនៅក្នុងថ្នាក់រៀន ងឿងឆ្ងល់ពីរបស់ទាំងនោះ ហើយសួរសំណួរទៅកាន់មនុស្សធំ។

**ឥទ្ធិពលបរិស្ថានលើការអភិវឌ្ឍរបស់កុមារ**




តាមរយៈការរស់នៅប្រចាំថ្ងៃ រួមទាំងសកម្មភាពនៅសាលារៀន កុមារមានបទពិសោធយ៉ាងច្រើនជាមួយបរិស្ថាននៅជុំវិញខ្លួន។ នៅពេលកុមារចាប់ផ្ដើមចាប់អារម្មណ៍ ចូលចិត្ត និងមានអន្តរកម្មជាមួយបរិស្ថានទាំងនោះ ពួកគេទទួលបាននូវឥទ្ធិពលផ្សេងៗជាច្រើន ដូចជាការអភិវឌ្ឍផ្នែករូបរាងកាយ បញ្ញា និងស្មារតីជាដើម។ កុមារធ្វើសកម្មភាពផ្សេងៗជាមួយបរិស្ថានទាំងនោះរហូតទទួលបានអារម្មណ៍ពេញចិត្ត និងគ្រប់គ្រាន់។

## ៣. ប្រសិទ្ធភាពនៃការរៀបចំបរិស្ថានសិក្សា

កុមារកើតមកមានការចង់ដឹងនៅពេលពួកគេសប្បាយរីករាយនឹងការលេងក្នុងបរិស្ថាន ដែលមានអំណោយផលល្អដល់ពួកគេ និងតាមរយៈសកម្មភាពនេះ កុមារអភិវឌ្ឍសមត្ថភាពនៃការគិត ពិចារណា ចាប់ផ្ដើមអភិវឌ្ឍន៍សមត្ថភាពលើការយល់ដឹងផ្សេងៗដូចជា រាងធរណីមាត្រ ចំនួន ទីតាំង ទិសដៅ(មុខ ក្រោយ លើ ក្រោម ក្នុង ក្រៅ ចំហៀង ឆ្វេង ស្ដាំ ឆ្ងាយ ជិត) ពេលវេលាជាដើម។ កុមារចាប់អារម្មណ៍ និងយល់ដឹងកាន់តែស៊ីជម្រៅ ទៅលើចំណុចទាំងនេះបន្តិចម្ដងៗ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

កុមារតូចគឺជាវ័យដែលគួរទទួលបានការបណ្ដុះនូវទម្លាប់រស់នៅប្រកបដោយ ភាពល្អប្រសើរ និងអាចរៀនពីរបៀបរស់នៅក្នុងបរិស្ថានមួយដែលមានការរៀបចំសមស្រប។ ការរៀបចំបរិស្ថានថ្នាក់រៀនគឺចូលរួមអភិវឌ្ឍន៍បំណិនរូបវន្ត និងបំណិនអរូបវន្ត ប្រកបដោយប្រសិទ្ធភាព។

យើងអាចវាស់បំណិនរូបវន្ត បំណិនរឹង ឬសមត្ថភាពគិតបានងាយ តាមរយៈការធ្វើតេស្តការចងចាំ សំណេរ ការគណនា ការវិនិច្ឆ័យ ការសម្រេចចិត្ត ចំណេះដឹងភាសាជាដើម។ យើងក៏មានតេស្តស្ទង់ដារ(IQ) ក្នុងការវាយតម្លៃបំណិន ឬសមត្ថភាពគិតផងដែរ។

**បំណិនរូបវន្ត (Cognitive)** **អរូបវន្ត (Non-Cognitive Skill)**




@Emiko Kiyohara

បំណិនអរូបវន្ត បំណិនទន់ ឬបំណិនសង្គមជាសមត្ថភាពដែលយើងពិបាកសង្កេតពីខាងក្រៅ។ វាជាសមត្ថភាពទាក់ទងនឹងបំណងប្រាថ្នា ការសហការសាមគ្គី ការខិតខំប្រឹងប្រែង ការតស៊ូ ការរៀបចំផែនការ សេចក្ដីមេត្តា សុទិដ្ឋិនិយម(គិតថាខ្លួនអាចធ្វើបាន) សមត្ថភាពប្រឈមនៅពេលមានអ្វីមួយកើតឡើងខុសពីការគិតរបស់ខ្លួន សមត្ថភាពគ្រប់គ្រងអារម្មណ៍ ងើបឈរឡើងវិញក្រោយបរាជ័យជាដើម។ បំណិនអរូបវន្តជាកត្តាមួយសំខាន់ដែលជះឥទ្ធិពលដល់ទំនាក់ទំនងអន្តរបុគ្គល រវាងកុមារ និងកុមារ កុមារ និងគ្រូភាពស្និទ្ធស្នាល និងការបើកចំហក្នុងទំនាក់ទំនង ការគ្រប់គ្រងខ្លួនឯង វិន័យផ្ទាល់ខ្លួន និងការច្នៃប្រឌិតជាដើម។

ការសិក្សាជាច្រើនអំពីអន្តរកម្មរវាងបំណិនរូបវន្ត និងបំណិនអរូបវន្ត បានរកឃើញថា យើងអាចខកខានក្នុងការអភិវឌ្ឍបំណិនរូបវន្ត បើសិនជាយើងមិនបានផ្ដោតការយកចិត្តទុកដាក់លើបំណិនអរូបវន្ត។ ផ្ទុយទៅវិញ ការផ្ដោតលើបំណិនអរូបវន្តអាចបង្កើនការរីកចម្រើនបន្ថែម លើលទ្ធផលការសិក្សាទាក់ទងនឹងភាសា ការសរសេរ និងគណិតវិទ្យាជាដើម។

បំណិនអរូបវន្តកាន់តែមានភាពលេចធ្លោក្នុងបរិបទអភិវឌ្ឍរបស់ពិភពលោកនាសតវត្សទី២១។ របាយការណ៍របស់ធនាគារពិភពលោកនៅឆ្នាំ២០១៨ បានលើកឡើងថា«ការអប់រំនៅមត្តេយ្យសិក្សាជួយឱ្យកុមារក្លាយជាមនុស្សពេញវ័យមានគុណភាពឆ្លើយតបនឹងតម្រូវការទីផ្សារការងារក្នុងយុគសម័យទំនើប ដោយកុមារមានបំណិនក្នុងការគិតបែបស៊ីជម្រៅ ការសហការ ទំនាក់ទំនង ការចរចា ការគ្រប់គ្រងខ្លួនឯង ការអត់ធ្មត់ និងការច្នៃប្រឌិត»។ ទន្ទឹមនឹងនេះ របាយការណ៍របស់មូលនិធិកុមារអង្គការសហប្រជាជាតិបានធ្វើការសិក្សានៅប្រទេសចំនួន១២ រកឃើញថា មានទំនាក់ទំនងជាវិជ្ជមាន និងគួរឱ្យចាប់អារម្មណ៍ រវាងការចូលរៀននៅមត្តេយ្យសិក្សា និងការអភិវឌ្ឍបំណិនរូបវន្ត បំណិនសង្គមរូបារម្មណ៍(បំណិនអរូបវន្ត) និងលទ្ធផលទីផ្សារការងារ។ ក្នុងនោះ ការសិក្សាក៏បានរកឃើញភស្តុតាងដែលបង្ហាញពីការរីកចម្រើនលើការបើកចិត្ត មនសិការ ភាពអង់អាចក្លាហាន ការអត់ធ្មត់ និងបំណិនចាំបាច់សម្រាប់កន្លែងការងារដទៃៗទៀត។

ជាការពិតណាស់ បំណិនរូបវន្តអាចកសាងក្នុងវ័យសិក្សានៅសាលារៀន ប៉ុន្តែវ័យដែលមានប្រសិទ្ធភាពបំផុតគឺ ក្នុងវ័យកុមារតូចដោយសារ វាជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍរបស់មនុស្ស។ ចូរក្រលេកមើលឧទាហរណ៍ទាំងនេះ ហើយប្រៀបធៀបរវាងកុមារតូច និងមនុស្សធំ៖

| **បំណិនអរូបវន្ត** | **កុមារតូច** | **មនុស្សធំ** |
|---|---|---|
| ការចង់ចេះ ចង់ដឹង៖ ឫសគល់មួយនៃការចង់ចេះចង់ដឹងគឺការសួរសំណួរ «ហេតុអ្វី?» ការសួរធ្វើឱ្យខួរក្បាលជំរុញការគិត។ អ្នកវិទ្យាសាស្ត្រល្បីៗ សុទ្ធតែពូកែខាងសួរសំណួរមួយនេះ។ | កុមារតូចចូលចិត្តសួរមិនឈប់ សួរពីមួយទៅមួយទៀត មិនខ្វល់ថាគេឆ្លើយ ឬមិនឆ្លើយ គេធុញ ឬអត់ សំណួរហ្នឹងសម ឬមិនសម។ ជារឿយៗ គាត់រៀនបាននូវអ្វីថ្មីជានិច្ច។ | អាចពិបាកនឹងសួរពីព្រោះថាគាត់គិតថាខ្លាចគេថាមិនចេះ ខ្លាចគេថាសួរមិនសមហេតុផល សួរច្រើនខ្លាចគេធុញជាដើម ដោយសារគាត់ធ្លាប់ជួប ឬមានបទពិសោធបែបនេះ។ ជាលទ្ធផល ពេលខ្លះព្រមសុខចិត្តទាំងមិនយល់ ថាយល់ទាំងមិនយល់។ |
| ភាពច្នៃប្រឌិត៖ ការបង្កើតនូវអ្វីដែលថ្មី ឬកើតចេញពីគំនិតដើមរបស់ខ្លួន | នៅពេលកុមាររីករាយនឹងការលេង គូររូបភាព ឬអានសៀវភៅរូបភាពសេរី ជាញឹកញាប់គេប្រាប់ពីសាច់រឿង និងបង្កើតអ្វីជាច្រើនពីពិភពមួយដែលខុសឆ្ងាយពីស្ថានភាពកំពុងរស់នៅ ឬពិភពពិតដែលមនុស្សធំមិនដែលគិតដល់។ | ច្រើនតែគិតថា«នេះជាអ្វីដែលយើងធ្លាប់ធ្វើ» ឬ«ខ្ញុំគួរតែធ្វើដូច្នេះ» ដោយផ្អែកលើបទពិសោធ និងចំណេះដឹងទូទៅ ដូច្នេះធ្វើឱ្យមនុស្សធំរារែកក្នុងការគិត ឬទទួលយកនូវគំនិត ឬអ្វីដែលថ្មី។ |
| ទំនាក់ទំនងអន្តរបុគ្គល(ការចងមិត្តជាដើម) | កុមារតូចមានភាពងាយស្រួលក្នុងការរាប់អានមិត្តភក្តិ។ ជាទូទៅ បើគេដាក់កុមារមិនស្គាល់គ្នាមួយក្រុមក្នុងសួនកុមារ ក្នុងរយៈពេលដ៏ខ្លីពួកគាត់នឹងងាយលេងជាមួយគ្នា ដោយគ្រាន់តែញញឹម ហើយនិយាយស្ដីរកគ្នា។ | អាស្រ័យលើប្រភេទមនុស្ស មនុស្សធំពិបាកជាងកុមារតូចក្នុងការរាប់អានមិត្តថ្មីដោយសារមានកត្តាផ្ទាល់ខ្លួន(ឧ៖ ចូលចិត្តនៅម្នាក់ឯង ខ្មាសអៀន) និងសង្គម(ឧ៖ មានអារម្មណ៍តូចទាបជាងគេ មនុស្សប្លែកមុខមិនគួរឱ្យទុកចិត្ត គិតពីផលប្រយោជន៍ផ្ទាល់ខ្លួន)។ |

## ការរៀបចំថ្នាក់រៀន និងការអភិវឌ្ឍរបស់កុមារ




នេះជាឈ្មោះ និងកន្លែងរបស់ខ្ញុំ(ឈ្មោះលើស្លាកសញ្ញាសម្គាល់កុមារ)



ថ្នាក់រៀនរបស់ខ្ញុំមានសណ្តាប់ធ្នាប់ល្អ!



ថ្នាក់រៀនរបស់ខ្ញុំមានរបស់របរលេងច្រើន ខ្ញុំចង់លេងដែរ





ថ្នាក់រៀនរបស់ខ្ញុំស្អាត មានផាសុកភាព!



ខ្ញុំចង់ទៅសាលាលាមត្តេយ្យ! "ចង់សាកល្បងលេង និងរៀន!"

ធ្ងល់ណាស់! អ្វីហ្នឹង?

កុមារទទួលការរំភើប និងព័ត៌មានជាច្រើនពីបរិស្ថានខាងក្រៅ
កុមារឆ្ងល់ ភ្ញាក់ផ្អើល សប្បាយ និងមានការចាប់អារម្មណ៍ជាមួយអ្វីៗជាច្រើន។



## ៤. គន្លឹះសម្រាប់ការរៀបចំបរិស្ថានសិក្សា

- រៀបចំបរិស្ថានដែលអំណោយផលល្អ និងគួរជាទីចាប់អារម្មណ៍ទាក់ទាញកុមារឱ្យចង់លេង ឬជាកន្លែងមួយដែលមានសម្ភារៈរៀន ហើយកុមារអាចលេងជាមួយបរិស្ថានរបស់ខ្លួនបាន។
- រៀបចំកន្លែងសម្រាប់កុមារដាក់សម្ភារៈផ្ទាល់ខ្លួនដូចជា ធ្នើរដាក់ស្បែកជើង ឬដាក់សម្លៀតជាដើម ដើម្បីដាក់របស់គេដាច់ពីកុមារដទៃ និងរៀបចំសម្ភារៈទាំងនោះឱ្យមានសណ្តាប់ធ្នាប់ល្អ។ ការធ្វើបែបនេះបង្រៀនឱ្យកុមារអាចយកវាទៅអនុវត្តជាក់ស្តែង នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។
- រក្សាបរិស្ថានល្អ ជាពិសេសកន្លែងអនាម័យផ្សេងៗដូចជា កន្លែងពិសាទឹកស្អាត កន្លែងលាងដៃ លាងជើង និងបន្ទប់ទឹក។ លើសពីនេះ ណែនាំកុមារពីសារៈសំខាន់នៃការធ្វើអនាម័យ និងពីរបៀបរក្សាបាននូវអនាម័យ។
- រៀបចំកន្លែង ឬជ្រុងដែលកុមារអាចលេងសប្បាយទៅតាមអ្វីដែលគេចង់លេង ដូចជាជ្រុងសិក្សាបណ្ណាល័យ ជ្រុងថ្នាក់ ឬជ្រុងល្បែងសម្រាប់ដាក់សម្ភារៈល្បែង(សម្ភារៈបត់រូប ដីឥដ្ឋ រូបគំនូរ ល្បែងសិក្សាជាដើម)។
- រៀបចំកន្លែងលំហែអារម្មណ៍សម្រាប់កុមារ ដែលធ្វើឱ្យគេអាចផ្ចង់ទៅលើសកម្មភាពដែលគេកំពុងធ្វើ (ឧ.ដាក់កម្រាល ឬញ៉ែកកន្លែងណាមួយសម្រាប់ដាក់សៀវភៅ)។
- រៀបចំគ្រឿងសង្ហារិមឱ្យសមស្របទៅនឹងកម្ពស់របស់កុមារ ដើម្បីឱ្យកុមារអាចមើលបានច្បាស់។
- រៀបចំគ្រឿងសង្ហារិមសមស្របទៅតាមសកម្មភាព ដោយប្តូរប្លង់តុ កៅអីជាដើម។

ការរៀបចំបរិស្ថានសំដៅលើការអប់រំដែលមានគោលបំណងអភិវឌ្ឍជំនាញផ្សេងៗរបស់កុមារ តាមរយៈបទពិសោធ និងការលេងជាមួយនឹងវត្ថុ និងមនុស្សជុំវិញខ្លួនដោយខ្លួនឯង រួចតាមរយៈការលេង និងបទពិសោធទាំងនេះ កុមារទទួលបានចំណេះដឹង និងជំនាញសមស្រប។

ការយល់ច្រឡំមួយចំនួនដែលទាក់ទងនឹងការរៀនតាមរបៀបនេះដូចខាងក្រោម៖

- ការរៀបចំសម្ភារៈលេង និងសម្ភារៈផ្សេងៗ រួចហើយទុកឱ្យកុមារលេងដោយខ្លួនឯង។
- គ្រូគ្រាន់តែយកបរិស្ថានអប់រំដែលមានមកឱ្យកុមារអនុវត្តតាម ដោយមិនចាំបាច់មានការច្នៃប្រឌិតអ្វីបន្ថែម។
- ការធ្វើសកម្មភាពដែលដឹកនាំដោយគ្រូតែម្ខាងប៉ុណ្ណោះ។

ផ្ទុយទៅវិញ ជាការសម្របសម្រួលឱ្យកុមារអាចអនុវត្តសកម្មភាពនីមួយៗប្រកបដោយប្រសិទ្ធភាព ប៉ុន្តែត្រូវគិតផងដែរពីដំណើរការរៀនដោយកុមារខ្លួនឯងផ្ទាល់ ឱ្យគាត់បានសាកល្បង ខុសត្រូវៗជាច្រើនសា។

## ៥. តួនាទី និងការពិចារណារបស់គ្រូបង្រៀន

ជាតុសំខាន់នៃសកម្មភាពគឺកុមារ រីឯគ្រូមានតួនាទីបង្កើតបរិស្ថានសមស្របដើម្បីឱ្យសកម្មភាពមានដំណើរការទៅមុខៗ។ គ្រូមានតុល្យភាពល្អរវាងភាពជាម្ចាស់ការរបស់កុមារតូច និងគោលបំណងក្នុងការអប់រំរបស់គ្រូ មានន័យថាពេលរៀបចំសកម្មភាពគ្រូប្រាកដជាចង់ឱ្យកុមារអភិវឌ្ឍអ្វីមួយ តែមិនប្រាកដថាត្រូវតែសម្រេចឱ្យបាន១០០%នោះទេ ព្រោះកុមារមានចំណង់ចំណូលចិត្តខ្លួនឯង ហើយពួកគេក៏មិនចង់ធ្វើតាមការរៀបចំរបស់គ្រូរហូតនោះដែរ។

ដើម្បីឱ្យកុមារអាចមានសកម្មភាពឯករាជ្យម្ចាស់ការបាន គ្រូបង្រៀនត្រូវយល់ និងគិតជាមុនពីសកម្មភាព និងការអភិវឌ្ឍរបស់កុមារម្នាក់ៗ ដើម្បីរៀបចំបរិស្ថានឱ្យបានសមស្របតាមសកម្មភាព។ ក្នុងករណីនេះ គ្រូបង្រៀនត្រូវរៀបចំសម្ភារៈ និងទីកន្លែង ដោយគិតពីសារៈសំខាន់នៃអន្តរកម្មរវាងកុមារ និងមនុស្សជុំវិញខ្លួនកុមារ និងវត្ថុ។

ឧទាហរណ៍៖ សកម្មភាពសូនសត្វគោពីដីឥដ្ឋ

គ្រូបានគិតថាដើម្បីឱ្យកុមារសប្បាយនឹងសកម្មភាពដំបូងគ្រូត្រូវធ្វើយ៉ាងណាឱ្យកុមារចាប់អារម្មណ៍ និងស្គាល់ពីសត្វគោជាមុនសិន។ ប្រាកដណាស់កុមារមួយចំនួនស្គាល់ តែកុមារមួយចំនួនក៏មិនទាន់ស្គាល់ច្បាស់។ ដូច្នេះ គ្រូបានដឹកនាំសកម្មភាពទស្សនាសង្កេតសត្វគោនៅទីធ្លាក្នុងសាលារៀន។

ជាលទ្ធផល នៅពេលសូនរូបគោ គ្រូសង្កេតឃើញថាកុមារមានភាពរីករាយដែលបានសូនរូបសត្វគោដែលខ្លួនទើបនឹងឃើញ។ ផ្ទុយទៅវិញ ក៏មានកុមារខ្លះមិនសូវចេះសូនដែរ ដោយសារគេមិនទាន់ចេះប្រើប្រាស់ដីឥដ្ឋឱ្យបានល្អនៅឡើយទេ។ គ្រូមិនបានជួយកុមារភ្លាមនោះទេ ដោយសារចង់ទុកពេលឱ្យកុមារបានសង្កេតមើលកុមារដទៃ និងឱ្យពួកគេចេះជួយគ្នាទៅវិញទៅមក។

លើសពីនេះ គ្រូក៏បានអនុញ្ញាតឱ្យកុមារសូនរូបផ្សេងក្រៅពីសត្វគោ តាមការចាប់អារម្មណ៍របស់គេផងដែរ។




**សកម្មភាពទស្សនាសង្កេតសត្វគោ**









**សកម្មភាពសូនរូបគោ**

គ្រូមានតួនាទីផ្សេងៗក្នុងការសម្របសម្រួលសកម្មភាពរបស់កុមារម្នាក់ៗ និងធ្វើឱ្យសកម្មភាពរបស់ពួកគេមានលក្ខណៈសម្បូរបែប។ នេះជាឧទាហរណ៍ខ្លះនៃការចូលរួមរបស់គ្រូបង្រៀនដើម្បីសម្រួលដល់ការរៀនរបស់កុមារ៖

| ការពិចារណារបស់គ្រូ | ការអភិវឌ្ឍរបស់កុមារ |
|---|---|
| មិនត្រូវណែនាំ ឬដំបូន្មានដូចជា«ធ្វើបែបនេះ!» ឬ «គួរធ្វើដូច្នេះ!»ទៅឱ្យកុមារជាមុន។ | កុមារឱកាសគិត និងធ្វើការសម្រេចចិត្តដោយខ្លួនឯង បានសាកល្បងធ្វើ ទោះជាខុស ឬត្រូវក៏ដោយ។ |
| ចៀសវាងប្រើពាក្យអវិជ្ជមាន តាមដែលអាចធ្វើទៅបាន និងត្រូវចាប់អារម្មណ៍ ដោយយល់ពីអារម្មណ៍របស់កុមារ ព្រមទទួលយកការគិតរបស់ពួកគេ។ | កុមារបានបណ្តុះនូវភាពជឿជាក់ និងមានទំនុកចិត្តលើខ្លួនឯង។ |
| ត្រូវទទួលស្គាល់ និងសរសើរការខិតខំប្រឹងប្រែងរបស់កុមារនៅក្នុងការធ្វើអ្វីមួយ ទោះបីជាលទ្ធផលល្អ ឬមិនល្អក៏ដោយ។ ក្នុងករណីកុមារសម្រេចការងារបានលទ្ធផលមិនល្អ គ្រូគប្បីលើកទឹកចិត្តកុមារឱ្យបានគិត បានប្រៀបធៀប បានយល់ដឹងពីចំណុចខ្វះខាតនូវលទ្ធផលការងាររបស់ខ្លួន ហើយនឹងមានការប្តេជ្ញាក្នុងចិត្តថាលើកក្រោយនឹងធ្វើឱ្យល្អជាងនេះ។ | កុមារមានអារម្មណ៍ថា បានធ្វើបានសម្រេច និងនាំឱ្យពួកគេមានទំនុកចិត្តថា«ខ្ញុំអាចធ្វើវាបាន»។ |



# ជំពូកទី ២

## ការរៀបចំបរិស្ថានក្នុងថ្នាក់រៀន

## ១. ការរៀបចំរដ្ឋបាលថ្នាក់រៀន

កិច្ចការរដ្ឋបាលនៅក្នុងថ្នាក់រៀនមានច្រើនប្រភេទ ដែលគ្រូបន្ទុកថ្នាក់មត្តេយ្យសិក្សាម្នាក់ៗត្រូវរៀបចំរួមមាន៖ សៀវភៅរដ្ឋបាលសិក្សា តារាងព្យួរនៅជញ្ជាំង បញ្ជីផ្សេងៗ និងក្តារខៀនព័ត៌មានជាដើម។ រដ្ឋបាលថ្នាក់រៀនមត្តេយ្យសិក្សាសំដៅលើសកម្មភាពគ្រប់គ្រង ថែរក្សា និងចាត់ចែងនៅថ្នាក់មត្តេយ្យសិក្សា តាមរយៈការទទួលឯកសារ រក្សាទុក បង្កើត និងបញ្ជូនលិខិត។

ការរៀបចំរដ្ឋបាលថ្នាក់រៀន គឺត្រូវរៀបចំតុបតែងនៅខាងក្នុងថ្នាក់រៀន និងខាងក្រៅថ្នាក់រៀនឱ្យមានលក្ខណៈគរុកោសល្យ លក្ខណៈជាតិ និងមានសោភណភាព ដើម្បីទាក់ទាញការចាប់អារម្មណ៍ពីកុមារចង់ទៅសាលារៀន និងមាតាបិតា និងអ្នកអាណាព្យាបាលកុមារ មានទំនុកចិត្តក្នុងការបញ្ជូនកូនទៅរៀនផងដែរ។

ថ្នាក់រៀនមានបរិស្ថានស្អាត មានសោភ័ណភាព និងការតុបតែងមានសណ្តាប់ធ្នាប់ល្អ បានឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់រៀន ការបង្រៀន និងរៀន ប្រកបដោយគុណភាព ដែលជាបំណងប្រាថ្នារបស់មាតាបិតា និងអ្នកអាណាព្យាបាលកុមារ ព្រមទាំងបានឆ្លើយតបទៅនឹងគោលនយោបាយទី១(ធានាឱ្យការអប់រំមានគុណភាព) របស់ក្រសួងអប់រំ យុវជន និងកីឡា។

### ១.១. តារាងទាំង៧




ក្នុងថ្នាក់មត្តេយ្យសិក្សានីមួយៗ គ្រូបង្រៀនបានដាក់តាំងនូវតារាងទាំង៧នេះ ដើម្បីងាយស្រួលដល់ការគ្រប់គ្រង និងពិនិត្យតាមដានក្នុងការសិក្សារបស់កុមារ និងសកម្មភាពប្រចាំថ្ងៃរបស់គ្រូបង្រៀន។ តារាងទាំងអស់នេះត្រូវព្យួរនៅលើជញ្ជាំងខាងក្រោយ ឬខាងស្តាំដៃ ឬខាងឆ្វេងដៃនៃតុគ្រូ កម្ពស់ងាយស្រួលគ្រូ និងកុមារមើល។ តារាងព្យួរនៅជញ្ជាំងមានដូចខាងក្រោម ៖



**១.១.១. បទបញ្ជាផ្ទៃក្នុង៖** ជាវិន័យ៩ប្រការ សម្រាប់អនុវត្តន៍ក្នុងដំណើរការរៀន និងបង្រៀន ឱ្យមានសណ្តាប់ល្អ ប្រកបដោយការទទួលខុសត្រូវ។

**១.១.២. ប្រកាស ឬសេចក្តីណែនាំ៖** ជាលិខិតបទដ្ឋាននានា ដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា ឬអាជ្ញាធរដែនដី។ ក្នុងនោះអាចមានព្រឹត្តិការណ៍ថ្មីៗ ដែលអនុញ្ញាតឱ្យប្រើប្រាស់ក្នុងកម្មវិធីសិក្សា ឬលិខិតនានា សម្រាប់គ្រូ និងកុមារប្រតិបត្តិ។

**១.១.៣. បញ្ជីសារពើភ័ណ្ឌ៖** ជាបញ្ជីសម្រាប់គ្រប់គ្រងសម្ភារៈ(ចលនព្រទ្យ និងអចលនព្រទ្យ) បានច្បាស់លាស់ និងសម្រាប់តាមដាន និងវាយតម្លៃគុណភាពសម្ភារៈ ដែលកំពុងប្រើប្រាស់នៅថ្នាក់មត្តេយ្យសិក្សាតាមឆ្នាំសិក្សានីមួយៗ។

**១.១.៤. បំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ៖** ជាតារាងកម្មវិធីមុខវិជ្ជា មេរៀន និងរយៈពេលបង្រៀនសម្រាប់គ្រូមត្តេយ្យសិក្សាអនុវត្តការងារតាមលំដាប់លំដោយនៃកម្មវិធីសិក្សា ឱ្យចំទិសដៅក្នុងរយៈពេលមួយឆ្នាំសិក្សា តាមឆ្នាំនីមួយៗ។

**១.១.៥. បំណែងចែកកម្មវិធីសិក្សាប្រចាំខែ៖** ជាតារាងកម្មវិធីមុខវិជ្ជា មេរៀន និងរយៈពេលបង្រៀន ដែលស្រង់ចេញពី បំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ សម្រាប់គ្រូអនុវត្តការងារប្រចាំថ្ងៃ និងសប្តាហ៍ តាមខែនីមួយៗ ឱ្យចំទិសដៅ ទាន់ពេលវេលា ងាយស្រួលតាមដានការបង្រៀនរបស់គ្រូ និងអនុវត្តន៍តាមលំដាប់លំដោយនៃកម្មវិធីសិក្សា ក្នុងរយៈពេលមួយខែ។

**១.១.៦. កាលវិភាគ៖** ជាតារាងពេលវេលា មុខវិជ្ជា និងរយៈពេលរៀន និងបង្រៀន ក្នុងសកម្មភាពប្រចាំថ្ងៃក្នុងមួយសប្តាហ៍។

**១.១.៧. តារាងបែងចែកវេនសម្អាត៖** ជាតារាងបង្ហាញវេនសម្អាតតាមក្រុមនីមួយៗ របស់កុមារដោយមានប្រធានថ្នាក់ និងប្រធានក្រុមចូលរួមដឹកនាំទៅតាមថ្ងៃដែលបានកំណត់។

## ១.២. សៀវភៅរដ្ឋបាល



គ្រូមត្តេយ្យសិក្សាត្រូវរៀបចំសៀវភៅ និងបញ្ជីកិច្ចការរដ្ឋបាលថ្នាក់រៀន តាមពេលវេលាឱ្យមានសណ្ដាប់ធ្នាប់ និងងាយស្រួលក្នុងការយកមកប្រើប្រាស់ ដោយរក្សាទុកលើតុគ្រូ ឬក្នុងទូឯកសារ។ សៀវភៅ និងបញ្ជីទាំងនោះរួមមាន៖

**១.២.១. សៀវភៅផែនការអភិវឌ្ឍថ្នាក់រៀន៖** សៀវភៅផែនការអភិវឌ្ឍថ្នាក់រៀនរៀបចំធ្វើ ដើម្បីឱ្យដឹងពីសកម្មភាព ពេលវេលា ធនធាន និងអ្នកទទួលខុសត្រូវ។ គ្រូមត្តេយ្យសិក្សាអនុវត្តការងារឱ្យចំទិសដៅ និងទាន់ពេល ព្រមទាំងងាយស្រួលក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍថ្នាក់រៀន។

**១.២.២. សៀវភៅកិច្ចតែងការបង្រៀន៖** ជាសៀវភៅកិច្ចការដែលគ្រូត្រូវប្រើប្រាស់ប្រចាំថ្ងៃ ផ្ដល់ភាពងាយស្រួលក្នុងដំណើរការបង្រៀនតាមដំហាននីមួយៗ ទាន់ពេលវេលា និងមានប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងលទ្ធផលរំពឹងទុកនៃមេរៀននីមួយៗ។

**១.២.៣. សៀវភៅផែនការសកម្មភាពបង្រៀនប្រចាំថ្ងៃ៖** ជាសកម្មភាពបង្រៀនប្រចាំថ្ងៃ គ្រូត្រូវសរសេររាល់ថ្ងៃក្នុងសៀវភៅ ឬសរសេរជាសន្លឹកដាក់ក្នុងក្រូណូដើម្បីជាជំនួយជាឯកសារយោងបន្ថែមលើសៀវភៅកិច្ចតែងការបង្រៀន។

**១.២.៤. សៀវភៅប្រជុំបច្ចេកទេស និងការងារទូទៅ៖** ជាសៀវភៅសម្រាប់កត់ត្រានូវចំណុចសំខាន់ៗ និងលទ្ធផលក្នុងអង្គប្រជុំសម្រេចបាន និងការណែនាំរបស់ប្រធានអង្គប្រជុំ។ ចំណុចសំខាន់ៗទាំងនោះរួមមានរបៀបវារៈ សមាសភាពចូលរួម ខ្លឹមសារក្នុងរបៀបវារៈនីមួយៗ សកម្មភាពដែលបានឯកភាពគ្នា និងផែនការអនុវត្តបន្ត។



**១.២.៥. សៀវភៅតាមដានការសិក្សាកុមារ៖** ជាសៀវភៅសម្រាប់គ្រូពិនិត្យតាមដានលទ្ធផលសិក្សារបស់កុមារម្នាក់ៗ និងទទួលមតិយោបល់កែលម្អពីមាតាបិតា និងអ្នកអាណាព្យាបាលកុមារ ផ្ញើត្រឡប់មកគ្រូមត្តេយ្យសិក្សាវិញ។

**១.២.៦. សៀវភៅទំនាក់ទំនងជាមួយមាតាបិតា និងអ្នកអាណាព្យាបាលកុមារ៖** ជាសៀវភៅដែលគ្រូមត្តេយ្យសិក្សាប្រើប្រាស់សម្រាប់ជូនដំណឹងដល់មាតាបិតា និងអ្នកអាណាព្យាបាលកុមារ អំពីព័ត៌មានរបស់កុមារក្នុងករណីមានបញ្ហាកើតឡើងដូចជា អវត្តមានច្រើនគ្មានច្បាប់ ឬការឈប់រៀនរបស់កុមារ។

**១.២.៧. សៀវភៅអនុសាសន៍៖** បង្កើតសម្រាប់ជូននាយក នាយិកា និងគណៈប្រតិភូក្រុមអធិការកិច្ចដែលចុះពិនិត្យតាមដានថ្នាក់រៀន ត្រូវសរសេរនៅក្នុងសៀវភៅនេះ ដោយលើកសរសើរអំពីចំណុចល្អ និងផ្ដល់អនុសាសន៍ លើចំណុចខ្វះខាតដល់គ្រូមត្តេយ្យសិក្សា ដើម្បីកែលម្អចំណុចខ្វះខាតទាំងនោះ។ សម្រាប់នាយក នាយិកាពិនិត្យមើលពេលក្រោយ និងក្រើនរំលឹកដល់គ្រូមត្តេយ្យសិក្សាអនុវត្តការងារបន្ត។

**១.២.៨. សៀវភៅទទួលសម្ភារៈ និងឯកសារ៖** ជាសៀវភៅកត់ត្រានូវរាល់ចំណូលសម្ភារៈ ឬឯកសារដែលបានទទួលពីនាយក នាយិកា និងសប្បុរសជននានា។

**១.២.៩. សៀវភៅបញ្ជីហៅឈ្មោះកុមារ៖** ជាសៀវភៅសម្រង់ប្រវត្តិរូបសង្ខេបកុមារ ចុះអវត្តមានកុមារដែលមិនបានមករៀនប្រចាំថ្ងៃ ដើម្បីធ្វើរបាយការណ៍ប្រចាំខែជូនមាតាបិតា និងអ្នកអាណាព្យាបាលកុមារ និងនាយក នាយិកា។

**១.២.១០. សៀវភៅតាមដានសុខភាពកុមារ៖** ជាសៀវភៅកំណត់ត្រារបស់គ្រូប្រចាំថ្នាក់ ដែលចាំបាច់កត់ត្រាប្រចាំខែនៃលទ្ធផលត្រួតពិនិត្យ និងតាមដានអំពីការអភិវឌ្ឍសុខភាព រូបរាងកាយ ទម្ងន់ និងកម្ពស់របស់កុមារដែលមានសារៈសំខាន់ណាស់ ដើម្បីធ្វើរបាយការណ៍ប្រចាំខែ ជូននាយក នាយិកា មាតាបិតា និងអ្នកអាណាព្យាបាលកុមារបានដឹងអំពីការអភិវឌ្ឍ រូបរាងកាយសុខភាព ទម្ងន់ កម្ពស់ និងការព្យាបាលជំងឺរបស់កុមារផងដែរ។

**ចំណាំ៖** ក្រៅពីសៀវភៅដូចបានរៀបរាប់ទាំង១០ខាងលើ សាលារៀនអាចបង្កើតសៀវភៅផ្សេងៗ តាមស្ថានភាពសាលារៀននីមួយៗ បានតាមតម្រូវការប្រើប្រាស់រៀងៗខ្លួន។

## ១.៣. បញ្ជីបញ្ជូនឈ្មោះកុមារឡើងថ្នាក់

ជាបញ្ជីដែលគ្រូមត្តេយ្យសិក្សារៀបចំធ្វើនៅដំណាច់ឆ្នាំសិក្សានីមួយៗ ដើម្បីស្រង់ឈ្មោះកុមារ ដែលគ្រប់អាយុត្រូវឡើងទៅតាមកម្រិតថ្នាក់ ពីកម្រិតទាបទៅមធ្យម ពីមធ្យមទៅកម្រិតខ្ពស់ និងពីកម្រិតខ្ពស់ទៅថ្នាក់ទី១ នៅសាលាបឋមសិក្សា តាមអក្ខរក្រម ព្រមទាំងមានការចុះហត្ថលេខាដោយគ្រូបន្ទុកថ្នាក់ និងឯកភាពពីនាយក ឬនាយិកាសាលាមត្តេយ្យសិក្សា ចំពោះមត្តេយ្យសិក្សាសហគមន៍ ពីមេឃុំ ឬចៅសង្កាត់។ បញ្ជីនេះត្រូវធ្វើចំនួន៣ច្បាប់ ១ច្បាប់រក្សាទុកនៅគ្រូបន្ទុកថ្នាក់ ១ច្បាប់រក្សានៅទីចាត់ការសាលារៀន ចំពោះមត្តេយ្យសិក្សាសហគមន៍រក្សាទុកនៅសាលាឃុំ ឬសង្កាត់ និង១ច្បាប់ទៀតបញ្ជូនទៅសាលាបឋមសិក្សា។

## ១.៤. ក្តារខៀនព័ត៌មាន



ការធ្វើទំនាក់ទំនងជាមួយមាតាបិតា និងអ្នកអាណាព្យាបាលកុមារ គឺជាការងារដ៏សំខាន់របស់គ្រូមត្តេយ្យសិក្សាតាមមធ្យោបាយនានា ដែលងាយស្រួលក្នុងការផ្តល់ និងទទួលព័ត៌មានពីថ្នាក់មត្តេយ្យសិក្សា។ គ្រូមត្តេយ្យសិក្សា និងមាតាបិតា អ្នកអាណាព្យាបាលផ្តល់ការអប់រំ និងថែទាំកុមារតូចដូចគ្នា ដូច្នេះមាតាបិតា និងអ្នកអាណាព្យាបាលកុមារគ្រប់រូបទទួលព័ត៌មានសំខាន់ៗ ពីគ្រូមត្តេយ្យសិក្សាតាមរយៈក្តារខៀនព័ត៌មានប្រចាំថ្ងៃ។

ក្តារខៀនព័ត៌មាន គឺជាក្តារខៀនតូចមួយប្រើជាមធ្យោបាយផ្តល់ព័ត៌មានថ្មីៗ មេរៀន សកម្មភាពប្រចាំថ្ងៃ ផែនការដែលបានគ្រោងទុក និងព័ត៌មានទទួលបានពីថ្នាក់លើ ដើម្បីជូនដំណឹងដល់មាតាបិតា និងអ្នកអាណាព្យាបាលកុមារ ព្រមទាំងសហគមន៍ឱ្យបានយល់ដឹងគ្រប់សកម្មភាពរបស់សាលារៀន។

### ១.៤.១. ប្រសិទ្ធភាព៖

- ការធ្វើទំនាក់ទំនង និងការចែករំលែកព័ត៌មានរវាងគ្រូមត្តេយ្យសិក្សា ជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលកុមារនឹងជំរុញឱ្យការថែទាំ និងអប់រំកុមារកាន់តែប្រសើរឡើង។
- មាតាបិតា និងអ្នកអាណាព្យាបាលកុមារនឹងមានការយល់ដឹងកាន់តែស៊ីជម្រៅពីសារៈសំខាន់នៃការអប់រំកូន។
- ចូលរួមចំណែកពង្រឹងចំណងទំនាក់ទំនងរវាងសាលា និងសហគមន៍។
- បានចែករំលែកព័ត៌មានទៅវិញទៅមក រវាងគ្រូមត្តេយ្យសិក្សា និងមាតាបិតា និងអ្នកអាណាព្យាបាលកុមារអំពីការថែទាំ និងអប់រំកុមារកាន់តែជិតស្និទ្ធ។
- មាតាបិតា និងអ្នកអាណាព្យាបាលកុមារដឹងអំពីផែនការរបស់គ្រូ និងសាលារៀន ដែលនឹងធ្វើនៅថ្ងៃបន្ទាប់។



### ១.៤.២. របៀបនៃការរៀបចំ និងការប្រើប្រាស់៖

- ក្តារខៀនព័ត៌មានត្រូវរៀបចំនៅខាងមុខថ្នាក់រៀន ឬលើសន្លឹកទ្វារខាងស្តាំ ឬខាងឆ្វេង ឬនៅកន្លែងណាមួយនៅលើជញ្ជាំងថ្នាក់រៀនខាងក្រៅ ដែលមិនរំខានដល់កុមារកំពុងសិក្សា នៅពេលដែលមានអ្នកទៅមើលព័ត៌មាន។ ការជ្រើសរើសទំហំធំ ឬតូចអាស្រ័យលើស្ថានភាពបន្ទប់ ឬអគារ និងលទ្ធភាពរបស់សាលារៀន។
- តុបតែងដាក់ផ្កាភ្ញីលើក្តារខៀន ផ្ទាំងរូបភាពជាគំនូរ ឬរូបថត ដើម្បីទាក់ទាញការយកចិត្តទុកដាក់ក្នុងការអាន របស់មាតាបិតា និងអ្នកអាណាព្យាបាលកុមារ។
- ផ្តល់ព័ត៌មានសំខាន់ទាក់ទងនឹងសកម្មភាពថ្នាក់មត្តេយ្យសិក្សា ធ្វើយ៉ាងណាឱ្យមាតាបិតា និងអ្នកអាណាព្យាបាលកុមារមានអារម្មណ៍ថាក្តារខៀននេះមានអត្ថប្រយោជន៍សម្រាប់ពួកគាត់។ ដូច្នេះ គ្រូត្រូវជំរុញលើកទឹកចិត្តឱ្យពួកគាត់អានព័ត៌មាននៅលើក្តារខៀនឱ្យបានញឹកញាប់។
- ផ្ទាំងព័ត៌មានអប់រំផ្សេងៗដែលទាក់ទងនឹងកុមារតូចក៏អាចបិទលើក្តារខៀនព័ត៌មាន ឬជញ្ជាំងខាងមុខទំនេរបានដែរ។



ផ្ទាំងព័ត៌មានអប់រំផ្សេងៗ

## គន្លឹះបន្ថែម

ឧទាហរណ៍ការប្រើប្រាស់ក្តារខៀនព័ត៌មានៈ

១. កាលវិភាគ / ព័ត៌មានសិក្សាប្រចាំថ្ងៃ

ថ្ងៃចន្ទ ទី១៤ ខែមិថុនា ឆ្នាំ២០២១

សកម្មភាពប្រចាំថ្ងៃៈ

- ចិត្តចលភាពៈ ហាត់ប្រាណតាមបទចម្រៀង
- បុរេគណិតៈ គូសភ្ជាប់ចំនួនទៅនឹងលេខពី៥ដល់១០
- សិក្សាសង្គមៈ គូសតាមស្នាមចុចៗលើរូបផ្លែក្រូច
- ភាសាខ្មែរៈ ល្បែង«ប្រព័ន្ធគ្រួសារ»
- សិក្សាសង្គមៈ ល្បែងសេរី

ថ្ងៃពុធ ៦កើត ខែផល្គុន ឆ្នាំជូត
ទោស័ក ពស ២៥៦៤

សកម្មភាពប្រចាំថ្ងៃៈ

- ចិត្តចលភាពៈ លោតជើងពីរ ទៅមុខ ទៅក្រោយ ទៅឆ្វេង ទៅស្តាំ
- បុរេគណិតៈ ល្បែងរើសយកវត្ថុវែង ខ្លី
- សិក្សាសង្គមៈ ចម្រៀង«ស្អាតជានិច្ច»
- ភាសាខ្មែរៈ ស្គាល់អក្សរ«គ»

២. ព័ត៌មានអំពីកម្មវិធីផ្សេងៗ

ថ្ងៃស្អែកទី១ ខែមិថុនា ឆ្នាំ២០២១ ត្រូវនឹងថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៤ ជា **ទិវាកុមារអន្តរជាតិ** ចាប់ផ្តើមនៅម៉ោង ៧:៣០នាទី ដល់ ១០:៣០នាទីព្រឹក និងមានសកម្មភាពដូចខាងក្រោមៈ

- ការបង្ហាញសម្ផតពនិទានរឿង
- ការប្រកួតគ្រាប់តាមកាយវិការសត្វ
- ការប្រកួតញ៉ាំនំរវាងកុមារ និងមាតាបិតា

បញ្ជាក់ៈ សូមអ្នកអាណាព្យាបាលត្រៀមសម្លៀកបំពាក់សម្រាប់កុមារងាយស្រួលធ្វើកម្មភាព។

៣. ព័ត៌មានថ្ងៃឈប់សម្រាក

**ព័ត៌មាន**

ឈប់សម្រាកចំនួន១ថ្ងៃ នៅថ្ងៃសុក្រ ទី១៨ ខែមិថុនា ឆ្នាំ ២០២១ ដើម្បីអបអរសាទរ

**ព្រះរាជពិធីចម្រើនព្រះជន្ម សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្តម មុនីនាថ សីហនុ**

## ២. ការរៀបចំសកម្មភាពប្រចាំថ្ងៃ






ការរៀបចំសកម្មភាពប្រចាំថ្ងៃមានសារៈសំខាន់ណាស់ឱ្យកុមារបានសិក្សារៀនសូត្រពីសកម្មភាពដែលគ្រូបានរៀបចំក្នុងមួយថ្ងៃៗ។ ការរៀបចំទីកន្លែងអនុវត្តសកម្មភាពនីមួយៗនៅក្នុងថ្នាក់ ត្រូវបត់បែនទៅតាមសកម្មភាពដែលត្រូវរៀនក្នុងមួយថ្ងៃៗ ហើយជាសកម្មភាពដែលគ្រូនាំកុមារអនុវត្តជាប្រចាំនៅរៀងរាល់ថ្ងៃក្នុងដំណើរការបង្រៀន។ តាមរយៈនៃការរៀបចំនេះកុមារនឹងទទួលបាននូវការអភិវឌ្ឍសមត្ថភាពបានពេញលេញ និងគ្រប់ផ្នែក។

### ២.១. តារាង





ដើម្បីឱ្យការអនុវត្តសកម្មភាពប្រចាំថ្ងៃទទួលបាននូវប្រសិទ្ធភាព គ្រូបង្រៀនគប្បីរៀបចំតារាងសកម្មភាពប្រចាំថ្ងៃឱ្យសម្បូរបែប មានលក្ខណៈទាក់ទាញកុមារឱ្យចូលចិត្ត និងចេះប្រើតារាងសកម្មភាពនីមួយៗបានត្រឹមត្រូវ ក្នុងគោលបំណងឱ្យកុមារមាន ការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន និងមានទម្លាប់ល្អក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ តារាងសកម្មភាពប្រចាំថ្ងៃមាន៖

១.តារាងឈ្មោះកុមារតាមក្រុម/តារាងវត្តមានកុមារ
២.តារាងប្រតិទិនប្រចាំសប្តាហ៍
៣.តារាងប្រតិទិនប្រចាំខែ
៤.តារាងឈ្មោះ ខែ ទាំង១២
៥.តារាងឈ្មោះឆ្នាំខ្មែរទាំង១២។

ក្រៅពីតារាងខាងលើគ្រូអាចរៀបចំតារាងផ្សេងទៀត ដែលបម្រើឱ្យសកម្មភាពបង្រៀន និងរៀនបាន។

### ២.១.១. លទ្ធផលរំពឹងទុកការអភិវឌ្ឍរបស់កុមារតូច

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីឈ្មោះខ្លួនឯងឈ្មោះ មិត្តភក្តិ ចំណាំពាក្យឈ្មោះ និងគូសចម្លងឈ្មោះរបស់ខ្លួនបាន<br>- ប្រាប់បានពីកាលបរិច្ឆេទថ្ងៃខែឆ្នាំ ឈ្មោះថ្ងៃមករៀន ថ្ងៃឈប់សម្រាកនៅផ្ទះ អាកាសធាតុ និងឈ្មោះឆ្នាំខ្មែរ។ |
| បំណិនសម្បទា | - ដាក់បណ្ណសម្គាល់នីមួយៗតាមតារាងបានត្រឹមត្រូវ<br>- រាប់ឈ្មោះថ្ងៃខែ និងឆ្នាំបានត្រឹមត្រូវតាមលំដាប់លំដោយ។ |
| ចរិយាសម្បទា | - ឈ្លាសវៃក្នុងការកំណត់លេខរៀងនៃខែ និងឈ្មោះសត្វតាមឆ្នាំនីមួយៗបានត្រឹមត្រូវ<br>- ចេះរង់ចាំវេន និងសហការជួយគ្នាអនុវត្តការងារបានល្អ។ |

## ២.១.២. ការរៀបចំ




ការព្យួរត្រូវស្រេបតាមកម្ពស់ភ្នែករបស់កុមារ( ១ម៉ែត្រ ចុះក្រោម) ងាយស្រួលក្នុងការមើល និងយកមកប្រើប្រាស់ជាប្រចាំ។

* តារាងទាំង៥ខាងលើ ត្រូវព្យួរនៅជញ្ជាំងខាងមុខសងខាងក្ដារខៀនតាមការរៀបចំរបស់គ្រូ។
* តារាងនីមួយៗត្រូវដាក់ក្នុងថង់ប្លាស្ទិច ឬបិទប្លាស្ទិកស្រោបដើម្បីប្រើប្រាស់បានយូរ។

### ក.តារាងឈ្មោះកុមារតាមក្រុម




គំរូតារាងមិនទាន់បំពេញកាតព័ត៌មាន

តារាងឈ្មោះកុមារតាមក្រុម

| ក្រុមទី១ | | ក្រុមទី២ | | ក្រុមទី៣ | |
|---|---|---|---|---|---|
| សំ ដារ៉ា | សំ ដារ៉ា | យ៉ា ធីតា | យ៉ា ធីតា | ផើង សំភិន | ផើង សំភិន |
| ជន ប៊ុនណា | ជន ប៊ុនណា | សំ ជីនិត | សំ ជីនិត | សេង ផានី | សេង ផានី |
| ផែន សីហា | | រិន មង្គល | រិន មង្គល | ណាត់ ណាក់ | |
| សើច ភាព | សើច ភាព | កៅ សុផាត | កៅ សុផាត | ដួង ចាន់ដារ | ដួង ចាន់ដារ |
| យក់ កក្កដា | យក់ កក្កដា | សេចក្ដី សុខ | សេចក្ដី សុខ | ផន កិច្ច | ផន កិច្ច |
| ដំ សក្កដា | ដំ សក្កដា | លេង លីដា | | ណុប ដេត | ណុប ដេត |
| សម្បត្តិ សំបូ | សម្បត្តិ សំបូ | ពិត ធម្មតា | ពិត ធម្មតា | កៅ គីឡា | កៅ គីឡា |
| ឌួង ឡៀត | ឌួង ឡៀត | ប្រក សៀង | ប្រក សៀង | មករា មីនា | មករា មីនា |
| ហាក់ សំណាង | ហាក់ សំណាង | ស្រៀង សាក | ស្រៀង សាក | លី កាកា | លី កាកា |

ស្លាកឈ្មោះដែលគ្មានអក្សរនៅខាងស្ដាំបញ្ជាក់ថាកុមារអវត្តមាន។

គំរូតារាងបំពេញកាតព័ត៌មានរួច

- ត្រូវគូស និងបិទ ឬសរសេរលើបណ្ណឱ្យច្បាស់ល្អរួចបិទប្លាស្ទីកនិងបត់យកផ្នត់ៗជាហោប៉ៅដោយក្នុងផ្នត់ហោប៉ៅនីមួយៗត្រូវចែកចេញជាពីរផ្នែក ខាងឆ្វេងដាក់បណ្ណស្លាកឈ្មោះកុមារ និងផ្នែកខាងស្ដាំទុកសម្រាប់កុមារយកបណ្ណស្លាកឈ្មោះរបស់ខ្លួនទៅដាក់តាមឈ្មោះក្នុងក្រុម។
- បណ្ណស្លាកឈ្មោះកុមារគ្រូត្រូវឧស្សាហ៍ផ្លាស់ប្ដូរទីតាំងឈ្មោះក្នុងក្រុមដើម្បីបញ្ជាក់ថាកុមារចំណាំឈ្មោះរបស់គេបានច្បាស់។

### ខ.តារាងប្រតិទិនប្រចាំសប្ដាហ៍




គំរូតារាងមិនទាន់បំពេញកាតព័ត៌មាន




គំរូតារាងបំពេញកាតព័ត៌មានរួច

- ត្រូវគូស និងបិទ ឬសរសេរក្នុងតារាងឱ្យច្បាស់ល្អរួចបិទប្លាស្ទិក និងបត់យកផ្នត់ៗ ជាហោប៉ៅខាងលើសម្រាប់កុមារដាក់បណ្ណសម្គាល់អាកាសធាតុ ខាងក្រោមដាក់បណ្ណសម្គាល់ថ្ងៃមករៀន និងបណ្ណសម្គាល់ថ្ងៃនៅផ្ទះ។

## គ.តារាងប្រតិទិនប្រចាំខែ

| តារាងប្រតិទិនប្រចាំខែ | | | | | | |
|---|---|---|---|---|---|---|
| ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

គំរូតារាងមិនទាន់បំពេញកាតព័ត៌មាន

| តារាងប្រតិទិនប្រចាំខែ វិច្ឆិកា | | | | | | |
|---|---|---|---|---|---|---|
| ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
| ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ |
| ០៨ | ០៩ | ១០ | ១១ | ១២ | ១៣ | ១៤ |
| ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ |
| ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ |
| ២៩ | ៣០ | | | | | |

គំរូតារាងបំពេញកាតព័ត៌មានរួច( កាតពណ៌ក្រហមបញ្ជាក់ពីថ្ងៃឈប់សម្រាក )

## ឃ.តារាងឈ្មោះខែទាំង១២

| តារាងឈ្មោះខែទាំង១២ | | | | | |
|---|---|---|---|---|---|
| មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |

ត្រូវគូស និងបិទ ឬសរសេរក្នុងតារាងឱ្យច្បាស់ល្អរួចបិទប្លាស្ទិកដើម្បីរក្សាការប្រើប្រាស់ឱ្យបានយូរ។

## ង.តារាងឈ្មោះឆ្នាំខ្មែរទាំង១២

| តារាងឈ្មោះឆ្នាំខ្មែរទាំង១២ | | | | | |
|---|---|---|---|---|---|
| ជូត | ឆ្លូវ | ខាល | ថោះ | រោង | ម្សាញ់ |
| មមី | មមែ | វក | រកា | ច | កុរ |

ត្រូវគូស និងបិទ ឬសរសេរក្នុងតារាងឱ្យច្បាស់ល្អរួចបិទប្លាស្ទិកដើម្បីរក្សាការប្រើប្រាស់ឱ្យបានយូរ។

## គន្លឹះបន្ថែម

### ការប្រើប្រាស់តារាងឈ្មោះកុមារតាមក្រុម

ក្រៅពីគំរូតារាងខាងលើ គ្រូក៏អាចរៀបចំទម្រង់ និងការប្រើប្រាស់តារាងបានតាមការច្នៃប្រឌិតរៀងៗខ្លួនបានដែរ តែមិនត្រូវចាកឆ្ងាយពីលំនាំដើមនោះទេ។ សូមមើលឧទាហរណ៍ដូចខាងក្រោម។

### ក. ការរៀបចំតារាង







គំរូតារាង៖ ខាងឆ្វេងជាគំនូសតារាង ខាងស្តាំងជារូបដាក់ស្តែង

### ខ. ការរៀបចំស្លាកឈ្មោះ




សន្លឹកស្លាកឈ្មោះផ្នែកខាងមុខ សម្រាប់កុមារវត្តមាន




សន្លឹកស្លាកឈ្មោះផ្នែកខាងក្រោយសម្រាប់កុមារអវត្តមាន

- សរសេរឈ្មោះកុមារ និងរូបស្លាកសញ្ញាសម្គាល់។
- បិទកាត់ទាំងពីរបញ្ចូលគ្នា ធ្វើជាកូនកាស។

### គ. ការប្រើប្រាស់




- រៀបស្លាកឈ្មោះសម្គាល់កុមារដាក់ក្នុងកូនកញ្ច្រែងសម្រាប់កុមារយកទៅបំពេញ។
- ឱ្យកុមារជាអ្នកដាក់ស្លាកឈ្មោះដោយខ្លួនឯង នៅពេលគេចាំស្លាកឈ្មោះសម្គាល់របស់ខ្លួន។
- ករណីកុមារចាំអស់ហើយ ឱ្យកុមារស្ម័គ្រចិត្តឡើងបំពេញតារាងសម្រាប់ក្រុមរបស់ខ្លួនក៏បានដែរ។ ជារួម គ្រូមើលស្ថានភាពជាក់ស្តែង ហើយច្នៃរបៀបដាក់ស្លាកឈ្មោះសម្គាល់ដោយខ្លួនឯង។

## ២.២. ធ្នើរដាក់ស្បែកជើងរបស់កុមារ







ធ្នើរនេះជាកន្លែងចាំបាច់សម្រាប់ឱ្យកុមារដាក់ស្បែកជើងទៅតាមទីកន្លែងដែលបានកំណត់ និងត្រូវមានរបៀបរៀបរយរក្សាបាននូវអនាម័យ និងសណ្តាប់ធ្នាប់ល្អ។ ដើម្បីឱ្យកុមារដាក់ស្បែកជើងចំទីកន្លែងកំណត់បានត្រឹមត្រូវគ្រូគប្បីបិទស្លាកឈ្មោះរូបសញ្ញាតាមទីតាំងសម្គាល់របស់កុមារម្នាក់ៗពេលនោះកុមារនឹងបានរៀនចំណាំទីកន្លែងឈ្មោះ និងរូបសញ្ញារបស់ខ្លួនឯង និងមិត្តភក្តិ។ ធ្នើរនេះអាចធ្វើអំពីឈើ ផ្តៅ ដែក ឬគូសទីតាំងនៅកន្លែងណាមួយគ្រូគិតថាសមស្រប។

### ២.២.១ លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីទីកន្លែងដែលត្រូវដាក់ឈ្មោះស្លាកសញ្ញាសម្គាល់ ឬស្លាកឈ្មោះរបស់ខ្លួនឯង និងមិត្តភក្តិបាន<br>- ប្រាប់បានពីរបៀបអនាម័យ និងថែរក្សាថ្នាក់រៀនឱ្យបានស្អាត<br>- ចំណាំតួអក្សរនៅលើស្លាកឈ្មោះរបស់ខ្លួន។ |
| បំណិនសម្បទា | - ដាក់ស្បែកជើងត្រូវតាមទីតាំងនៃសញ្ញាសម្គាល់ ឬឈ្មោះរបស់ខ្លួនបាន។ |
| ចរិយាសម្បទា | - មានទម្លាប់ល្អក្នុងការទុកដាក់សម្ភារៈប្រើប្រាស់ឱ្យមានសណ្តាប់ធ្នាប់<br>- សហការចូលរួមអនាម័យ និងថែរក្សាថ្នាក់រៀនឱ្យបានស្អាត។ |



### ២.២.២ ការរៀបចំ

**ក. ការរៀបចំធ្នើរដាក់ស្បែកជើង៖**



- អាចជ្រើសរើសធ្នើរធ្វើពីឈើ ឬផ្តៅ . . .
- រៀបចំធ្នើរនៅជិតទ្វារចូលដែលកុមារអាចដាក់ស្បែកជើងពេលចូលក្នុងថ្នាក់។
- ក្នុងករណីកន្លែងដាក់ស្បែកជើងមានកន្លែងមិនគ្រប់តាមចំនួនកុមារ ត្រូវរៀបចំធ្នើរដាក់បន្ថែមឱ្យបានគ្រប់តាមចំនួនកុមារ។

**ខ. ស្លាកសញ្ញាសម្គាល់សម្រាប់កុមារ៖**

- មានស្លាកសញ្ញាសម្គាល់ឱ្យបានគ្រប់តាមចំនួនកុមារម្នាក់ៗ នៅកន្លែងដែលងាយមើលឃើញ ហើយឧស្សាហ៍ផ្លាស់ប្តូរក្នុងករណីរហែក ឬហើរពណ៌មើលមិនច្បាស់រូបសម្គាល់ និងអក្សរ។
- ការជ្រើសរើសស្លាកសញ្ញាសម្គាល់មកបិទ ត្រូវគិតពីកម្រិតអាយុរបស់កុមារពីរូបងាយ ទៅលំបាក ឬថ្នាក់កម្រិតខ្ពស់បិទតែស្លាកឈ្មោះក៏បាន។




**គ. ការថែទាំធ្នើរ**

- បោសសម្អាតធ្នើរជាប្រចាំ បង្ការកុំឱ្យកណ្តៀរស៊ី និងរក្សាឱ្យបានស្អាតជានិច្ច។
- ក្នុងរដូវភ្លៀងធ្លាក់ គួរគប្បីប្រើបន្ទះប្រអប់ក្រដាសទ្រាប់ស្បែកជើងបន្ថែមដើម្បីកាត់បន្ថយការប្រឡាក់ធ្នើរ។



## ២.៣. កន្លែងដាក់សម្ភារៈ និងសម្ពៀតរបស់កុមារ





ការរៀបចំទីកន្លែងដាក់សម្ពៀត និងការកំណត់ដាក់ស្លាកសញ្ញាសម្គាល់របស់កុមារម្នាក់ៗគឺមានសារៈសំខាន់ណាស់សម្រាប់ឱ្យកុមារបានដាក់សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់គេឱ្យមានសណ្ដាប់ធ្នាប់ល្អទៅតាមទីកន្លែងដែលបានកំណត់។ កុមារអាចរក្សាទុកសម្ភារៈដទៃដូចជាកន្ត្រៃ និងស្នាដៃពីសកម្មភាពផ្សេងនៅក្នុង«ប្រអប់ផ្ទាល់របស់គេម្នាក់ៗ។

### ២.៣.១ លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីទីកន្លែង និងសញ្ញាសម្គាល់សម្រាប់ដាក់សម្ពៀត សម្ភារៈផ្សេងៗរបស់ខ្លួន និងមិត្តភក្ដិ។ |
| បំណិនសម្បទា | - ដាក់សម្ពៀត និងសម្ភារៈប្រើប្រាស់តាមទីកន្លែងកំណត់ឈ្មោះ និងកំណត់ចំណាំតួអក្សរគូសចម្លងតួអក្សរតាមឈ្មោះរបស់ខ្លួនបាន។ |
| ចរិយាសម្បទា | - ប្រកាន់ខ្ជាប់ខ្ជួននូវទម្លាប់ល្អរក្សាបាននូវសណ្ដាប់ធ្នាប់។ |



### ២.៣.២. ការរៀបចំ

#### ក. ការរៀបចំ៖



- រៀបដាក់សម្ភារៈ និងសម្ពៀតក្នុងទូដែលមានថតៗ ឬធ្នើរដែលមានថតកញ្ច្រែង ឬប្រអប់ក្រដាសសម្រាប់ដាក់សម្ពៀត និងរបស់ប្រើប្រាស់កុមារម្នាក់ៗ។
- រៀបចំទំពក់សម្រាប់ដាក់សម្ពៀត និងសម្ភារៈកុមារម្នាក់ៗ។ ទំពក់ដាក់ជាប់នឹងជញ្ជាំងក៏ជាជម្រើសមួយល្អអាចកាត់បន្ថយភាពចង្អៀតក្នុងទីធ្លាបន្ទប់រៀន។

ករណីសាលាមិនមានលទ្ធភាពទិញទូ ឬធ្នើរដាក់សម្ភារៈ សាលាអាចប្រើប្រអប់ក្រដាស(ដូចក្នុងរូប) ឬកញ្ច្រែង ឬរបស់ផ្សេងទៀតជំនួសបាន។




#### ខ. បិទស្លាកសញ្ញាសម្គាល់ និងថែទាំធ្នើរ

- បិទស្លាកសញ្ញាសម្គាល់ទីកន្លែងដាក់សម្ភារៈសម្រាប់កុមារម្នាក់ៗនៅពីមុខចំកណ្ដាលថតទូ ឬប្រអប់កេះ ឬនៅខាងលើជាប់នឹងទម្ពក់ដើម្បីឱ្យកុមារងាយមើលឃើញ។
- កន្លែង ឬសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ ត្រូវបិទស្លាកសញ្ញាសម្គាល់តែមួយដូចៗគ្នា។ ឧទាហរណ៍៖ កៅអីរបស់កុមារឧត្តម បិទស្លាកសញ្ញាសម្គាល់រូបផ្លែល្ហុង ប្រអប់ក្រដាស់ ឬទម្ពក់ក៏ត្រូវបិទស្លាកសញ្ញាសម្គាល់រូបផ្លែល្ហុងដែរ អ្វីៗដែលជាសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់កុមារឧត្តមត្រូវតែបិតរូបផ្លែល្ហុងទាំងអស់ ។
- ស្លាកសញ្ញាសម្គាល់សម្រាប់កុមារម្នាក់ៗដែលត្រូវប្រើប្រាស់តាមទីកន្លែងផ្សេងៗគ្នាត្រូវមានលក្ខណៈសម្គាល់ស្លាកសញ្ញាតែមួយដូចៗគ្នាងាយស្រួលដល់កុមារក្នុងពេលប្រើប្រាស់។
- ប្រសិនបើប្រើប្រអប់ក្រដាស ឡាំង កញ្ច្រែង ឬរបស់ផ្សេងៗតម្រូវឱ្យផ្លាស់ប្ដូរសម្ភារៈទាំងនោះត្រូវប្ដូរថ្មីក្នុងករណីមានរហែក ឬខូចអាស្រ័យលើការប្រើប្រាស់របស់កុមារ។
- ណែនាំកុមារឱ្យចៀសវាងយកចំណីអាហារណាដែលមានក្លិនមិនល្អដាក់ក្នុងសម្ពៀត ថតទូ ឬប្រអប់ដើម្បីរក្សាអនាម័យថ្នាក់រៀន។
- ស្លាកសញ្ញាសម្គាល់ត្រូវបញ្ចៀសកុំឱ្យប៉ះពាល់នឹងទំនៀមទម្លាប់ វប្បធម៌ និងប្រពៃណីខ្មែរ។

## ២.៤. កន្លែងធ្វើសកម្មភាពផ្សេងៗក្នុងថ្នាក់រៀន



កុមារតូចមានភាពពើសចង់ចេះចង់ដឹង និងធ្វើសកម្មភាពច្រើនបែបច្រើនយ៉ាង ចូលចិត្តលេងអ្វីដែលប្លែកហើយថ្មីៗ។ កុមារតូចរៀនតាមរយៈការលេង ហើយការលេងមិនមែននៅតែមួយកន្លែងនោះទេ គេតែងតែផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយ និងពីសកម្មភាពមួយទៅសកម្មភាពមួយទៀត ដូចជាធ្វើចិត្តចលភាព (ចលករតូច)លេងល្បែង និងសិល្បៈជាដើម។ ដូច្នេះ ទាមទារឱ្យគ្រូមានការរៀបចំផ្លាស់ប្តូរសង្ហារិម សម្ភារៈ និងទីកន្លែងបត់បែនទៅតាមសកម្មភាពនីមួយៗ ធ្វើយ៉ាងណារក្សាបរិស្ថានស្អាតមានផាសុកភាព សំខាន់ទាក់ទាញកុមារចង់មករៀន ចូលរួមអនាម័យ និងមានទម្លាប់ល្អ។

### ២.៤.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីទីកន្លែងដែលបានរៀបចំសកម្មភាពតាមផែនការបង្រៀនប្រចាំថ្ងៃនៅក្នុងថ្នាក់ សម្រាប់កុមារលេង។ |
| បំណិនសម្បទា | - អនុវត្តន៍សកម្មភាពតាមផែនការបង្រៀនប្រចាំថ្ងៃតាមការរៀបចំរបស់គ្រូនៅក្នុងថ្នាក់។ |
| ចរិយាសម្បទា | - មានចំណាប់អារម្មណ៍ សប្បាយរីករាយ ចូលរួមធ្វើសកម្មភាពនានា ជួយថែរក្សាសម្ភារៈ និងសង្ហារិម និងចង់មករៀនជារៀងរាល់ថ្ងៃ<br>- ពេញចិត្តចូលរួមសកម្មភាពជាមួយគ្រូ។ |



### ២.៤.២. ការរៀបចំ

**ក. ការរៀបចំកម្រាល៖**





- ថ្នាក់រៀនត្រូវរៀបចំឱ្យមានកម្រាលឥដ្ឋការ៉ូ ឬក្រាលកម្រាលកៅស៊ូទៅតាមលទ្ធភាពងាយស្រួលកុមារធ្វើសកម្មភាព ឬ លេង។
- កម្រាលឥដ្ឋការ៉ូ ឬកម្រាលកៅស៊ូ ដែលយកមកក្រាល ត្រូវជ្រើសរើសពណ៌ដូចជាពណ៌ស ឬពងមាន់។

**ខ. ការរៀបចំតុ កៅអី៖**

- រៀបចំតុ ឬកៅអីទៅតាមតម្រូវការសកម្មភាពថ្នាក់រៀន ជាក្រុមតូច ឬក្រុមធំ។ ក្នុងករណីសកម្មភាពមិនតម្រូវឱ្យមានរៀបតុ ឬកៅអី ដាក់របស់ទាំងនេះទៅកៀន ឬខាងនៃថ្នាក់រៀន។
- តុ និងកៅអីរបស់កុមារត្រូវតែសមស្របទៅតាមវ័យ និងអាចចល័តបាន(ចៀសវាងប្រើតុកៅអីថ្នាក់បឋមសិក្សា)។

**គ. ការផ្លាស់ប្តូរតាមសកម្មភាព៖**

- កន្លែងធ្វើសកម្មភាពផ្សេងៗក្នុងថ្នាក់ត្រូវរៀបចំឱ្យទូលាយ ស្រឡះល្អ ស្អាត មានអនាម័យ មានភាពទាក់ទាញ មានផាសុកភាព និងសុវត្ថិភាព។
- រៀបចំទីកន្លែង តុ កៅអី សម្ភារៈ និងកុមារជាក្រុមធំ ក្រុមតូចបត់បែនទៅតាមសកម្មភាពជាក់ស្តែង។

## គន្លឹះបន្ថែម

កុមាររៀនតាមរយៈការលេង ដូចនេះគ្រូត្រូវរៀបចំ បរិស្ថានក្នុងថ្នាក់រៀន ទៅតាមសកម្មភាពបង្រៀនប្រចាំថ្ងៃ ធ្វើយ៉ាងណាឱ្យកុមារផ្តោតអារម្មណ៍លើសកម្មភាពក្នុងថ្នាក់ និងចង់ចូលរួម។ ការរៀបចំកន្លែងមានសារៈសំខាន់ណាស់ព្រោះថាកុមារបានលេង កុមារនឹងទទួលបានអភិវឌ្ឍន៍ពេញលេញ។

ខាងក្រោមនេះជាឧទាហរណ៍៤ប្រភេទនៃការរៀបចំថ្នាក់រៀន ដែលត្រូវឱ្យកុមារអនុវត្តទៅតាមសកម្មភាពប្រចាំថ្ងៃ ប៉ុន្តែមិនមានន័យថាគ្រូត្រូវតែរៀបចំតាមឧទាហរណ៍នេះទេ។ គ្រូត្រូវរៀបចំទៅតាមស្ថានភាពជាក់ស្តែងក្នុងថ្នាក់រៀនដែលខ្លួនគិតថាសមស្របតាមមូលដ្ឋាន។



ឧទាហរណ៍ទី១ ៖ រៀបចំតុ និងកៅអី ជារាងអក្សរអ៊ុយ(U) សម្រាប់សកម្មភាពធម្មតា។



ឧទាហរណ៍ទី២ ៖ ផ្តុំ តុ និងកៅអី សម្រាប់សកម្មភាពក្រុម។



ឧទាហរណ៍ទី៣ ៖ ទុកទំនេរនៅចន្លោះកណ្តាលឱ្យទំនេរ
សម្រាប់សកម្មភាពដែលត្រូវការទីធ្លាធំ។

## ៣. ការរៀបចំជ្រុងថ្នាក់

### ៣.១. ជ្រុងវិទ្យាសាស្ត្រ







ជ្រុងវិទ្យាសាស្ត្រ គឺជាជ្រុងដែលធ្វើឱ្យកុមារស្វែងយល់អំពីបទពិសោធប្រចាំថ្ងៃ និងធ្វើអន្តរកម្មជាមួយគ្រប់ទិដ្ឋភាពទាំងអស់នៃបរិស្ថានរបស់ពួកគេ ដូចជាសាលារៀន ផ្ទះ គ្រួសារ និងព្រឹត្តិការណ៍ផ្សេងៗក្នុងសង្គម។ កុមារចង់ដឹងពីបម្រែបម្រួលនៃបាតុភូតធម្មជាតិក្នុងបរិស្ថានសិក្សាមាន ភាវៈមានជីវិត និងគ្មានជីវិតតាមការចាប់អារម្មណ៍របស់ពួកគេ ដូច្នេះគ្រូមត្តេយ្យសិក្សាដើរតួសំខាន់ជួយសម្រួលដល់ដំណើរការរៀបចំសកម្មភាពដើម្បីឱ្យសម្រេចបាននូវអ្វីដែលកុមារបានពេញចិត្តចង់ដឹងចង់ឃើញរំភើប និងទទួលបានចំណេះដឹង បំណិនកាន់តែច្រើនប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ និងមានប្រសិទ្ធភាព។

#### ៣.១.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីការលូតលាស់ និងលក្ខខណ្ឌរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ<br>- ប្រាប់បានពីបម្រែបម្រួលអាកាសធាតុ វត្ថុ និងបាតុភូតធម្មជាតិដែលនៅជុំវិញកុមារ<br>- ប្រាប់បានពីវប្បធម៌(ប្រាសាទ) សង្គម(ពិធីបុណ្យផ្សេងៗ) វិទ្យាសាស្ត្រងាយៗ។ |
| បំណិនសម្បទា | - កំណត់បានពីលូតលាស់ និងលក្ខខណ្ឌរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ<br>- កំណត់បានពីបម្រែបម្រួលអាកាសធាតុ វត្ថុ និងបាតុភូតធម្មជាតិដែលនៅជុំវិញកុមារ<br>- កំណត់បានពីវប្បធម៌ ពិធីបុណ្យប្រពៃណីផ្សេងៗ និងពិធីបុណ្យសាសនាក្នុងសង្គមរស់នៅ។ |
| ចរិយាសម្បទា | - ស្រឡាញ់ចូលចិត្ត ថែរក្សា និងការពារជីវិតមនុស្ស សត្វ និងរុក្ខជាតិ<br>- រីករាយចូលរួមធ្វើសកម្មភាពពិសោធដោយមានបម្រុងប្រយ័ត្ន និងមានសុខសុវត្ថិភាព<br>- យកចិត្តទុកដាក់ផ្សាភ្ជាប់ខ្លួននឹងការប្រែប្រួលអាកាសធាតុ<br>- ចាប់អារម្មណ៍ទៅលើធម្មជាតិ និងវិទ្យាសាស្ត្រកាន់តែខ្លាំង។ |



#### ៣.១.២. ការរៀបចំ

**ក. ការរៀបចំធ្នើរ ឬតុ៖**

- ជ្រើសរើសធ្នើរ ឬតុសមស្របនឹងកម្ពស់កុមារ ធានាសុវត្ថិភាព ងាយស្រួលប្តូរទីតាំងនៅថ្នាក់រៀន។
- ធ្នើរ ឬតុត្រូវដាក់នៅក្បែរមាត់បង្អួច ឬទ្វារដែលមានពន្លឺ និងខ្យល់គ្រប់គ្រាន់។
- រៀបចំទូ ឬធ្នើរមួយដែលអាចដាក់តាំងសម្ភារៈសម្រាប់ពិសោធដូចជាគ្រាប់ពូជ គ្រាប់ធញ្ញជាតិ កែវចិញ្ចឹមត្រីជាដើម។

**ខ. ការផ្លាស់ប្តូរសម្ភារៈតាមសកម្មភាព៖**

- តាំងវត្ថុពិត ឬវត្ថុដែលទាក់ទងនឹងវិទ្យាសាស្ត្រទៅតាមប្រធានបទសកម្មភាពថ្នាក់រៀន។
- គ្រូជាអ្នកគិតច្នៃប្រឌិតរៀបចំដាក់តាំង ឱ្យកុមារអនុវត្ត បង្កើនការយល់ដឹង ហើយកុមារស្រាវជ្រាវ បន្ថែមលើប្រធានបទដែលកំពុងរៀន។
- គ្រូសង្កេតមើលសកម្មភាពកុមារ តើពួកគេចាប់អារម្មណ៍លើអ្វីដែលកំពុងតាំងដែរឬទេ និងគួររៀបចំរយៈពេលយូរប៉ុណ្ណា។
- ភាវៈមានជីវិតដូចជាកូនរុក្ខជាតិ ត្រី ក្តាម ខ្យង ... មិនអាចតាំងយូរបើសិនគ្មានការថែទាំបានល្អ។
- វត្ថុផ្សេងៗអាចតាំងបានយូរគឺឧបករណ៍វាស់កំដៅ ចំណីអាហារ គ្រឿងអលង្ការ និងល័ក្តជ្រលក់ ពណ៌ទឹកពណ៌(គូល័រទឹក).....។

**គ.ការរៀបចំប្រកបដោយភាពទាក់ទាញ៖**

- រៀបចំយ៉ាងណាឱ្យកុមារចាប់អារម្មណ៍ទៅលើជ្រុងនេះ។
- រៀបចំធ្វើឱ្យកុមារយល់ច្បាស់ពីការលូតលាស់របស់រុក្ខជាតិ សត្វ កត់ត្រាពីការលូតលាស់ និងធ្វើការសង្កេតបន្តទៀត កុមារនឹងភ្លេចបើសិនជាលោកគ្រូ អ្នកគ្រូមិនធ្វើការរំឭកឡើងវិញ។
- រៀបចំវត្ថុដាក់តាំងឱ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ។

**ឃ. ការតាំងសៀវភៅ ឬផ្ទាំងរូបភាពស្របនឹងប្រធានបទ៖**

- សៀវភៅរូបភាពវិទ្យាសាស្ត្រ ឬសៀវភៅរឿងទាក់ទងវិទ្យាសាស្ត្រ។
- ផ្ទាំងរូបភាពបង្ហាញពីប្រធានបទមេរៀនក្នុងកម្មវិធីសិក្សាដែលត្រូវរៀនក្នុងថ្នាក់។
- រៀបចំសៀវភៅរូបភាពវិទ្យាសាស្ត្រ ឬសៀវភៅរឿងទាក់ទងវិទ្យាសាស្ត្របង្ហាញរូប។

## ឧទាហរណ៍

### ពិសោធន៍ឥន្ទធនូ





ថ្ងៃមួយគ្រូបានរៀបចំព្រឹត្តិការណ៍ផ្សាភ្ជាប់នឹង«អាកាសធាតុ» នៅក្នុងជ្រុងវិទ្យាសាស្ត្រ។ ក្នុងពេលនោះគ្រូបាននិទានរឿងទាក់ទងនឹងអាកាសធាតុ និងសកម្មភាពច្នៃប្រឌិត។ ករណីនេះបានធ្វើឱ្យកុមារចង់ដឹងបន្ថែមទៀតអំពីអាកាសធាតុ។ ជំហានបន្ទាប់គ្រូរៀបចំសកម្មភាពដែលកុមារបានឃើញ និងទទួលបាននូវអ្វីក្នុងសៀវភៅរូបភាពមកភ្ជាប់វាទៅនឹងជីវិតប្រចាំថ្ងៃ ដូចជាព្រះអាទិត្យ ភ្លៀង ខ្យល់ ឥន្ទធនូ ផ្កាយ ឬបាតុភូតធម្មជាតិផ្សេងៗកើតឡើងនៅលើមេឃរាល់ថ្ងៃ ដែលកុមារបានស្គាល់ច្បាស់។ ការពិសោធសាមញ្ញក៏ជួយកុមារឱ្យរៀនបន្ថែមអំពីគ្នាទៅវិញទៅមក ហើយបង្វែរចំណេះដឹងរបស់ពួកគេឈានទៅបំណិនផ្សេងៗ។ ប្រសិនបើគ្រូអាចរៀបចំសកម្មភាពបន្តនៅជ្រុងវិទ្យាសាស្ត្រនោះ កុមារនឹងកាន់តែចង់ដឹងអំពីអ្វីៗ ផ្សេងទៀតនៅជុំវិញខ្លួនដោយភាពរីករាយ។

| | |
|---|---|
| មុខវិជ្ជា(១) | - សិក្សាសង្គម (សកម្មភាពកសាង ការបង្កើតរូបភាពឥន្ទធនូ) |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីរបៀបបិទក្រដាសពណ៌តូចៗបង្កើតជារូបឥន្ទធនូ<br>- ប្រាប់បានពីលក្ខណៈ រូបរាង ពណ៌របស់ឥន្ទធនូ ។<br>បំណិនសម្បទា៖<br>- ប្រើការលាបលើក្រដាសពណ៌តូចៗបិទតាមពណ៌របស់ឥន្ទធនូ<br>- បង្ហាញបានរបៀបបង្កើតរូបឥន្ទធនូ។<br>ចរិយាសម្បទា៖<br>- សហការគ្នាបង្កើតរូបភាពឥន្ទធនូ<br>- ឈ្លាសវៃ រហ័សរហួន ប៉ិនប្រសប់បិទការលើក្រដាសពណ៌តូចៗបង្កើតជារូបឥន្ទធនូមានសោភ័ណ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម កុមារអាយុ៤ឆ្នាំ |
| រយៈពេល | - ៣០នាទី(១ម៉ោងសិក្សា) |
| សម្ភារៈ | ១. ការនិទានរឿង<br>- សៀវភៅរូបភាពទាក់ទងនឹងអាកាសធាតុ ឬឥន្ទធនូ<br>២. បង្កើតរូបឥន្ទធនូ<br>- ក្រដាសធំ ក្រដាសពណ៌(ហែកជាបំណែកតូចៗ) ចានតូចៗ ទឹក កាវបិទអេធីអឹម កន្សែងសើមសម្រាប់សម្អាតដៃ។ |
| របៀបលេង | - ចែកកុមារជាក្រុមតូចៗទៅតាមចំនួនកុមារ<br>- រៀបចំសម្ភារៈទៅតាមក្រុមនីមួយៗ<br>- គ្រូបានត្រៀមទុកជាមុនផ្ទាំងរូបភាពដែលឱ្យកុមារបិទតាមពណ៌ជាគម្រូផ្ទាំងធំបិទចន្លោះៗទុកឱ្យកុមារបំពេញ ហើយកាត់ផ្ទាំងធំនោះជាចំណែកតាមក្រុមកុមារ<br>- គ្រូបានហែកក្រដាសចំនួន៥ពណ៌តូចៗ រួចជាស្រេច។<br>- កុមារជ្រើសរើសក្រដាសពណ៌តូចៗដែលខ្លួនស្រឡាញ់បិទទៅលើផ្ទាំងដែលគ្រូចែកឱ្យតាមក្រុម<br>- ពេលចប់គ្រូប្រមូលក្រដាសផ្ទាំងធំតាមក្រុមមកបិទភ្ជាប់គ្នាបង្កើតជារូបឥន្ទធនូធំដាក់តាំងនៅជ្រុងសិល្បៈ។ |

| | |
|---|---|
| មុខវិជ្ជា(២) | វិទ្យាសាស្ត្រ (ពិសោធន៍ឥន្ទធនូ) |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីលក្ខណៈពណ៌ រូបរាង និងពេលវេលាដែលកើតមានបាតុភូតឥន្ទធនូ។<br>បំណិនសម្បទា៖<br>- ពណ៌នាអំពីពណ៌របស់ឥន្ទធនូ។<br>ចរិយាសម្បទា៖<br>- យកចិត្តទុកដាក់ទៅលើបម្រែបម្រួលអាកាសធាតុ<br>- រីករាយនឹងការពិសោធឥន្ទធនូ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម កុមារអាយុ៤ឆ្នាំ |
| រយៈពេល | - ៣០នាទី |
| សម្ភារៈ | - សៀវភៅរូបភាពទាក់ទងនឹងអាកាសធាតុ ឬឥន្ទធនូ(បង្ហាញតែរូបភាព)។<br>- ដបទឹកថ្លា ឬថាសឌីសចាស់ៗ ពិល ប្រអប់ក្រដាស។ |
| របៀបលេង | - ដាក់ដបទឹកថ្លា ឬថាសឌីសចាស់ៗ នៅក្នុងប្រអប់មួយ ហើយបញ្ចាំងពន្លឺពិលឱ្យមានពន្លឺផ្លេកប៉ះនឹងដបទឹកថ្លា ឬថាសឌីសចាស់ៗ<br>- ពន្លឺផ្លេកចាំងផ្លាតទៅប៉ះនឹងផ្ទៃប្រអប់នោះ យើងអាចឃើញរូបឥន្ទធនូនៅផ្ទៃប្រអប់នោះយ៉ាងច្បាស់។ |
| សម្គាល់៖ | - សូមនាំកុមារទៅមើលផ្ទាល់ប្រសិនបើមានបាតុភូតពិតប្រាកដ<br>- មុនធ្វើសកម្មភាពជាមួយកុមារគ្រូគួរធ្វើពិសោធជាមុន<br>- គ្រូអាចរកពិសោធផ្សេងៗទៀតតាមការច្នៃប្រឌិត។ |

## ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

### បរិស្ថាន



- រៀបចំទីធ្លាធំទូលាយដែលកុមារអាចមើលឃើញអ្នកគ្រូនិទានរឿង និងបិទក្រដាសតូចៗទៅលើក្រដាសផ្ទាំងធំបានជុំគ្នា (ឧទាហរណ៍អង្គុយជារង្វង់ ឬពាក់កណ្តាលរង្វង់អំឡុងពេលនិទានរឿង បង្កើតឥន្ទធនូនៅលើតុ ឬផ្ទាល់កម្រាលការ៉ូ)។
- បន្ទាប់ពីនិទានរឿង ចែកកុមារជា២ ឬ៣ក្រុម តាមចំនួនកុមារតិច ឬច្រើនសម្រាប់សកម្មភាពបិទឥន្ទធនូ។

### ការចូលរួមរបស់គ្រូ



**១. ការនិទានរឿង**

- គ្រូចាប់ផ្តើមនិទានរឿង។



**២. ការបិទរូបឥន្ទធនូ**

- គ្រូគូររូបរាងឥន្ទធនូនៅលើក្រដាសធំជាមុន។
- ពន្យល់កុមារពីរបៀបប្រើសម្ភារៈបិទឥន្ទធនូ។
- គ្រូចូលរួមជាមួយកុមារ ហើយជជែកជាមួយពួកគេ។
- លើកទឹកចិត្តឱ្យកុមាររៀបចំសម្ភារៈទាំងអស់នៅពេលចប់សកម្មភាព។



**៣. ពិសោធន៍ឥន្ទធនូ**

- ណែនាំកុមារកុំឱ្យមើលពន្លឺពិលផ្ទាល់ភ្នែក។
- ឆ្លើយតបនឹងការភ្ញាក់ផ្អើលពេលកុមាររកឃើញឥន្ទធនូនៅក្នុងប្រអប់ដែលចាំងផ្លាតពីស៊ីឌី ឬដប់ទឹកថ្លា។

## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



ពិតជាសប្បាយណាស់បានធ្វើការរួមគ្នាអីចឹង!

- តាមរយៈការនិទានរឿងរបស់គ្រូ និងសកម្មភាពបិទរូបឥន្ទធនូពីក្រដាសពណ៌តូចៗ កុមារចាប់អារម្មណ៍នឹងឥន្ទធនូជាខ្លាំង។ កុមារបានជ្រើសរើសពណ៌របស់ឥន្ទធនូដោយខ្លួនឯង និងសហការគ្នាបិតក្រដាសចម្រុះពណ៌។ កុមារឈ្មោះដារ៉ា និងមិត្តភក្តិបានប្រាប់គ្រូថាចង់ឃើញពណ៌ពិតនៃឥន្ទធនូ។
- គ្រូបានប្រាប់កុមារវិញថា«ថ្ងៃស្អែកអ្នកគ្រូនឹងបង្ហាញឥន្ទធនូដល់កូន»។ នៅថ្ងៃបន្ទាប់អ្នកគ្រូបាននាំកុមារទៅមើលជ្រុងវិទ្យាសាស្ត្រ ឱ្យកុមារពិសោធបញ្ចាំងពិលលើថាសឌីស នៅក្នុងប្រអប់។ «មើល! មានឥន្ទធនូនៅលើប្រអប់នេះ។ ពិតជាស្រស់ស្អាតណាស់!» កុមារមានការភ្ញាក់ផ្អើលដែលមានឥន្ទធនូតូចបានបង្ហាញខ្លួននៅប្រអប់ចំពោះមុខពួកគេ។
- ចាប់ពីពេលនោះមក កុមារចាប់ផ្តើមចាប់អារម្មណ៍លើឥន្ទធនូកាន់តែខ្លាំង។ ធីតាបាននិយាយថា«ពេលខ្ញុំជួយឪពុកខ្ញុំលាងឡាននៅផ្ទះ ខ្ញុំបានបាញ់ទឹកទៅលើ នៅពេលនោះ ខ្ញុំក៏មើលឃើញឥន្ទធនូដែរ»។ ក្នុងថ្នាក់រៀន កុមារបានចាប់ផ្តើមប្រាប់គ្នាថា លើអាវមិត្តភក្តិរបស់កុមារម្នាក់ និងនៅក្នុងថ្នាក់រៀនក៏មានរូបឥន្ទធនូដែរ។ គ្រូបានដឹងជាថ្មីម្តងទៀតថាកុមារអាចរៀនយ៉ាងសកម្មតាមរយៈបទពិសោធនេះ។



កុមារបញ្ចាំងពិលលើថាសឌីស មើលឥន្ទធនូ



មានឥន្ទធនូតូចនៅក្នុងថ្នាក់រៀនយើងដែរ

## គន្លឹះបន្ថែម

ការរៀបចំជ្រុងវិទ្យាសាស្ត្រតាមប្រភេទរឿងនិទាន ឬសកម្មភាព

ក. រឿង«បំណងគ្រាប់បាយ»៖ សាច់រឿងនេះចង់និយាយអំពីបំណងរបស់គ្រាប់បាយដែលចង់ចិញ្ចឹមមនុស្សលោក តែមនុស្សលោកបែរជាខ្ជីខ្ជាហូបចុកមិនសន្សំសំចៃទៅវិញ។ អត្ថន័យរឿងនេះគឺចង់ឱ្យមនុស្សស្រឡាញ់អាហារ ហើយហូបចុកត្រូវចេះសន្សំសំចៃ។ ចេញពីរឿងនេះ យើងរៀបចំជ្រុងវិទ្យាសាស្ត្រដូចខាងក្រោម ជាឧទាហរណ៍។






តាំងសៀវភៅរឿង «បំណងគ្រាប់បាយ»



ដាក់តាំងគ្រាប់ស្រូវ

ដាក់តាំងដើមស្រូវ



ដាក់តាំងសំណាបក្នុងកែវមានទឹក ដើម្បីបង្ហាញពីមជ្ឈដ្ឋានដែលវាលូតលាស់



ដាក់តាំងគ្រាប់អង្ករ

ខ. រឿង«ឌូឌូរៀនមើលម៉ោង»៖ សាច់រឿងនេះចង់បង្រៀនពីរបៀបមើលម៉ោងនៅលើនាឡិកា។ បន្ទាប់ពីនិទានរឿងនេះចប់ហើយ យើងអាចរៀបចំជ្រុងវិទ្យាសាស្ត្រដូចគំរូខាងក្រោម។



នាឡិកាផលិតពីក្រដាស | សៀវភៅរឿង | នាឡិកាពិត

គ. រឿង«យើងយោងបងខ្លា»៖ ខ្លាចង់ឆ្លងជ្រលងភ្នំមកលេងជាមួយសត្វដទៃទៀតនៅម្ខាងទៀត។ ដើម្បីឆ្លងបាន សត្វដទៃទៀតធ្វើដងយោង។ ដូច្នេះ យើងអាចរៀបនៅជ្រុងនេះដូចខាងក្រោម។



សៀវភៅរឿង | ដាក់តាំងតុក្កតាខ្លះដូចក្នុងសាច់រឿង | ផលិតដងយោងពីសម្ភារៈផ្សេងៗ ប្រើប្រាស់គំនិតច្នៃប្រឌិតផ្ទាល់ខ្លួន

## គន្លឹះបន្ថែម

ឃ. រឿង«កុលាបពីរទង»៖ សាច់រឿងចង់ប្រៀបធៀបពីភាពខុសគ្នារវាងកុលាបពីរទង មួយជាផ្កា កុលាបពិត និងមួយទៀតជាផ្កាកុលាបសិប្បនិម្មិត។ អត្ថន័យអប់រំក្នុងរឿងនេះគឺចង់ឱ្យមនុស្សចេះ ស្រឡាញ់បរិស្ថាន ស្រឡាញ់ធម្មជាតិ។ ចេញពីរឿងនេះ យើងអាចរៀបចំជ្រុងវិទ្យាសាស្រ្តដូចខាង ក្រោម។





ផ្កាពិត បើគ្មានផ្កាកុលាប អាចដាក់តាំងផ្កាផ្សេងជំនួសបាន




សៀវភៅរឿង



ផ្កាសិប្បនិម្មិត បើគ្មានផ្កាកុលាប អាចដាក់តាំងផ្កាផ្សេងជំនួសបាន

ង. មេរៀនទាក់ទងនឹងពណ៌៖ បន្ទាប់ពីគ្រូបង្រៀនមេរៀនអំពីពណ៌ដល់កុមារ យើងអាចរៀបចំជ្រុងវិទ្យាសាស្រ្តដូចខាងក្រោម។




ទឹកសម្រាប់លាយពណ៌ | ចានលាយពណ៌ និងជក់ | សៀវភៅអំពី «ពណ៌» | ថ្នាំពណ៌ ឬគូលរ



អនុញ្ញាតឱ្យកុមារបានអនុវត្តន៍លាយពណ៌

## ៣.២. ជ្រុងអនាម័យ





ជ្រុងអនាម័យរៀបចំឡើងដើម្បីឱ្យកុមារបានប្រើប្រាស់ដូចជា អនាម័យខ្លួនប្រាណ អវៈយវៈ ចៀសវាងពីជំងឺផ្សេងៗ និងបង្កើតទម្លាប់ល្អក្នុងការរស់នៅ។ កុមារផឹកទឹកស្អាត ចេះលាងសម្អាតដៃមុនពេលញ៉ាំចំណីអាហារ និងចេញពីបន្ទប់ទឹក ឬបង្គន់ពេលបត់ជើងរួច ចេះពាក់ម៉ាស់ការពារជាប្រចាំ ចេះរៀបចំសម្លៀកបំពាក់ មុខ មាត់ និងផ្ទះកញ្ចក់សិតសក់បានសមរម្យ។

### ៣.២.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីរបៀបលាងសម្អាតដៃមុន ក្រោយពេលបរិភោគចំណីអាហារ និងពេលចេញពីបន្ទប់ទឹក ឬបង្គន់ និងក្រោយពេលក្អក កណ្តាស់<br>- ប្រាប់បានពីរបៀបអនាម័យខ្លួនប្រាណ អវៈយវៈ មុខ មាត់ សក់ក្បាលនិងសម្លៀកបំពាក់ឱ្យស្អាតជានិច្ច<br>- ប្រាប់បានពីរបៀបពាក់ម៉ាស់ការពារជំងឺឆ្លងផ្សេងៗ។ |
| បំណិនសម្បទា | - ជួយសម្អាតបរិស្ថានដូចជាបន្ទោរបង់ឬខាកស្តោះ ទុកដាក់សំរាមក្នុងធុងសំរាម តាមកន្លែងកំណត់<br>- លាងសម្អាតដៃជាមួយសាប៊ូ អាល់កុលឬជែលមុននិងក្រោយញ៉ាំអាហារ ក្រោយពេលចេញពីបង្គន់ឬប៉ះពាល់របស់កង្វក់និងពេលក្អក កណ្តាស់<br>- ញ៉ាំទឹកស្អាត និងប្រើប្រាស់ម៉ាស់បានត្រឹមត្រូវតាមការណែនាំ។ |
| ចរិយាសម្បទា | - ទម្លាប់រស់នៅស្អាត មានអនាម័យល្អក្នុងការរស់នៅ រៀនសូត្រ ហូបស្អាត ផឹកស្អាត ចេះការការពារខ្លួនពីជំងឺផ្សេងៗ<br>- ស្រឡាញ់បរិស្ថានជុំវិញពោរពេញដោយភាពស្រស់ស្អាតគ្មានសំរាមគ្មានប្លាស្ទីច...។ |



### ៣.២.២. ការរៀបចំ

**ក. សម្ភារៈអនាម័យ៖** រៀបចំឱ្យមានកន្សែងជូតដៃ កញ្ចក់ និងក្រាស់សិតសក់ សាប៊ូ ធុងសំរាមអំបោស តង្កៀបចាប់សំរាម ធុងទឹកចម្រោះ ធុងទឹកសម្រាប់ធ្វើអនាម័យថ្នាក់រៀន ធុងទឹកលាងដៃ ឬកន្លែង សម្រាប់លាងសម្អាតនៅជិតថ្នាក់រៀន តាមលទ្ធភាពរបស់សាលារៀន។

**ខ. ការថែទាំជ្រុង៖**



- រៀបចំឱ្យមានកា ឬកែវផឹកទឹកសម្រាប់កុមារម្នាក់ៗ ឬមានដបទឹកដែលកុមារយកមករៀងខ្លួន និងមានបិទស្លាកសញ្ញាសម្គាល់។
- រៀបចំឱ្យមានកា ឬកែវទឹកសម្រាប់កុមារម្នាក់ៗឬមានដបទឹកដែលកុមារយកមករៀងៗខ្លួន និងមានបិទស្លាកសញ្ញាសម្គាល់ដោយរៀបចំដាក់ក្នុងកញ្ជ្រែងមានគម្របដើម្បីការពារមេរោគឆ្លងផ្សេងៗ។
- ត្រូវមានទឹកស្អាត ឬធុងទឹកចម្រោះសម្រាប់កុមារញ៉ាំ។
- រៀបចំកន្លែងលាងសម្អាតដៃខាងក្រៅ ជិតថ្នាក់រៀន ឬធុងលាងសម្អាតដៃ។

**គ. ការថែរក្សាអនាម័យ៖**



- ពន្យល់កុមារពីទម្លាប់អនាម័យជាប្រចាំ។
- ដឹកនាំកុមារផលិតធុងសំរាមពីសំបកប្រអប់ក្រដាស ដូច្នេះកុមារភ្ញាក់រឭកទុកដាក់សំរាមបានត្រឹមត្រូវ។
- បិទតាំងរូបសញ្ញាពីរបៀបលាងសម្អាតដៃ ដើម្បីឱ្យកុមារបន្តលាងដៃដោយរីករាយ។
- រៀបចំល្បែងត្រាប់តាម រូបភាព ឬរូបថតអប់រំកុមារពីអនាម័យមុខ មាត់ ដៃ...។

## ៣.៣. ជ្រុងសិល្បៈ





ជ្រុងសិល្បៈមានមុខងារ២៖ ទីមួយ ជាកន្លែងដាក់តាំងគ្រប់ស្នាដៃរបស់កុមារ ឧបករណ៍ភ្លេងខ្លះៗ និងទីពីរ ជាកន្លែងលេង និងសាកល្បងការងារសិល្បៈដូចជារាំ លេងឧបករណ៍ភ្លេងបុរាណ ឬសម័យ ងាយៗ តុក្កតាជាដើម ដែលទាក់ទងនឹងកុមារមត្តេយ្យ។ ជ្រុងនេះមានសកម្មភាពផ្សេងៗជាច្រើននៅថ្នាក់មត្តេយ្យសិក្សា ដែលកុមារបានចូលរួមអនុវត្តន៍ និងបង្កើតជាលទ្ធផលសិក្សាហៅថាស្នាដៃកុមារ( សិល្បៈ ) ដូចជាបត់រូប គូររូប ហែកបិទតាមស្នាមចុចៗ ពោយកម្ទេចកម្ទីតូចៗលើរូប(អាចម៍រណា កម្ទេចក្រដាស ស្លឹកឈើ...) ដោត ដេរ ត្បាញ កាត់បិទរូប ហែកបិទរូប សូនរូប ផលិតសម្ភារៈនានា យកមកដាក់តាំង។

### ៣.៣.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីឈ្មោះឧបករណ៍ភ្លេងខ្មែរ ទ្រ ស្គរ ឆាប ឈិង... ចំណងជើងបទចម្រៀងចង្វាក់រាំ ពណ៌សម្លៀកបំពាក់តាមថ្ងៃ សម្លៀកបំពាក់ប្រពៃណី និងព្រឹត្តិការណ៍សង្គម។<br>- ប្រាប់បានពីឈ្មោះសម្ភារៈនានាដែលផលិតបានដូចជារូបកែវ ក្បាលសត្វ ផ្កា សត្វស្លាប ដង្កូវ កន្ទេល សត្វ និងរូបភាពផ្សេងៗ<br>- ប្រាប់ពីរបៀបបត់ ពោយ ដោត ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែកបិទ ដែលបានដាក់តាំងស្នាដៃ។ |
| បំណិនសម្បទា | - បង្ហាញពីការប្រើប្រាស់ឧបករណ៍ភ្លេងខ្មែរទ្រស្គរ ឆាប ឈិង ... សម្លៀកបំពាក់ និងសូត្រកំណាព្យ ច្រៀងចម្រៀង ធ្វើកាយវិការ ព្រមទាំងច្រៀងបទនគររាជ ពង្សាវតារខ្មែរបានត្រឹមត្រូវ<br>- បង្កើតបានស្នាដៃតាមរយៈការបត់ក្រដាសបានជារូបផ្សេងៗ សូនរូប ពោយ ដេរ ត្បាញ គូរ ផាត់ពណ៌ ហែក និងកាត់បិទ។ |
| ចរិយាសម្បទា | - ស្រឡាញ់ឧបករណ៍ភ្លេងខ្មែរ សម្លៀកបំពាក់ប្រពៃណី ចង្វាក់រាំ និងចូលចិត្តសូត្រកំណាព្យ ច្រៀងបទនគររាជ ពង្សាវតារខ្មែរ និងចម្រៀងថ្នាក់មត្តេយ្យសិក្សា<br>- មានអារម្មណ៍រំភើបសប្បាយរីករាយពេលឃើញស្នាដៃខ្លួនដែលត្រូវបានដាក់តាំង<br>- មានមោទនភាពចំពោះទេពកោសល្យដែលគេបានធ្វើ និងចង់បង្ហាញស្នាដៃខ្លួនទៅអ្នកដទៃ។ |



### ៣.៣.២. ការរៀបចំ

#### ក. ការរៀបចំកន្លែងដាក់សម្ភារៈសិល្បៈ៖



- ដាក់តុ ធ្នើរ ឬកញ្ជ្រែងតាំងឧបករណ៍ភ្លេងខ្មែរទ្រ ស្គរ ឆាប ឈិង និងសម្ភារៈភ្លេងងាយៗដែលកុមារផលិតបាន។
- តាំងស្នាដៃកុមារលើក្រដាសកាតុងរឹង ផ្ទាំងស្នោរ ផ្ទាំងប្លាស្ទិច ឬក្តារខៀនកម្ទី។
- ជ្រើសរើសពណ៌ខៀវ ឬបៃតងចាស់សម្រាប់ធ្វើផ្ទាំងដាក់តាំងស្នាដៃដើម្បីឱ្យកុមារមើលឃើញរូបភាពបានច្បាស់។
- កម្ពស់ផ្ទាំងរូបភាពនៃជ្រុងសិល្បៈគួរឱ្យសមល្មមនឹងកម្ពស់កុមារ។

#### ខ. ការដាក់តាំងស្នាដៃកុមារ៖



- ដាក់តាំងស្នាដៃកុមារឱ្យបានច្រើន និងផ្លាស់ប្តូរញឹកញាប់យ៉ាងតិច២ ឬ៣ដងក្នុងមួយខែ។
- ដាក់តាំងស្នាដៃកុមារប្រមូលពីសកម្មភាពថ្នាក់មត្តេយ្យសិក្សាប្រចាំថ្ងៃដូចជាបត់រូប គូររូប ហែកបិតតាមស្នាមចុច ពោយកម្ទេចផ្សេងៗលើរូប ដេរ ត្បាញ កាត់បិតរូប ផលិតសម្ភារៈនានា។
- ត្រូវដាក់តាំងស្នាដៃកុមារគ្រប់គ្នាដើម្បីជាការលើកទឹកចិត្តដល់កុមារ។
- ដឹកនាំកុមារចូលរួមតុបតែង ឬដាក់តាំងជ្រុងនេះជាការប្រសើរ ហើយការរៀបចំនេះបម្រើដល់ប្រធានបទនៃការសិក្សាធ្វើឱ្យកុមារយល់បានកាន់តែច្បាស់។

#### គ. សោភណភាព



- ការរៀបចំតាំងឧបករណ៍ភ្លេង សម្ភារៈលេងឱ្យមានរបៀបដាក់វត្ថុពីតូចទៅធំតាមលំដាប់លំដោយដើម្បីឱ្យកុមារអាចមើលឃើញសម្ភារៈទាំងនេះបានច្បាស់ងាយស្រួលយកប្រើប្រាស់ និងទុកដាក់ត្រឹមត្រូវ។
- តុបតែងលម្អផ្កាភ្ញីនៅកន្លែងតាំងស្នាដៃកុមារឱ្យមានភាពទាក់ទាញ បង្កើតសោភ័ណភាព ប៉ុន្តែមិនស្មុគស្មាញ។

## ឧទាហរណ៍

### គំនូរសេរី



នៅដើមឆ្នាំសិក្សា គំនូរគឺជាផ្នែកមួយនៃការលេងដ៏ពេញនិយមបំផុតសម្រាប់កុមារ។ គំនូរមិនត្រឹមតែផ្តល់ភាពរីករាយប៉ុណ្ណោះទេប៉ុន្តែវាក៏ជួយកុមារឱ្យបង្កើនជំនាញដូចជាការស្គាល់ពណ៌ ការច្នៃប្រឌិត ការប្រើម្រាមដៃកាន់ជក់ ឬខ្មៅដៃពណ៌បានល្អ និងកម្រិតនៃការផ្តោតអារម្មណ៍របស់កុមារទៅលើរូបភាព។ ដូច្នេះគ្រូបានរៀបចំសកម្មភាពគូរគំនូរសេរី ដើម្បីឱ្យកុមារបានរីករាយជាមួយនឹងសម្ភារៈលាយពណ៌។ កុមារគិត និងចាប់អារម្មណ៍ប្លែកច្រើនជាងមនុស្សធំ ហើយព្យាយាមបង្ហាញចេញពីអារម្មណ៍ទាំងនេះតាមរយៈការគូររូប។ មិនមានបញ្ញត្តិណាមួយដែលកំណត់ថាកុមារត្រូវតែគូរគំនូរតាមរបៀបជាក់លាក់ណាមួយនោះ ដូច្នេះ យើងអាចរៀបចំទីកន្លែង និងសម្ភារៈៈសម្រាប់ឱ្យកុមារចូលរួមគូរបានដោយសេរី។

| | |
|---|---|
| មុខវិជ្ជា | - វិទ្យាសាស្ត្រ(គំនូរ) |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីឈ្មោះនៃរូបភាពដែលបានគូររួច<br>- ប្រាប់បានអំពីពណ៌ផ្សេងៗ។<br>បំណិនសម្បទា៖<br>- បញ្ជាក់របៀបគូរ និងការផាត់ពណ៌<br>- គូររូបភាព ឬផាត់ពណ៌បានត្រឹមត្រូវ<br>- កាន់ជក់ ឬខ្មៅដៃពណ៌ និងប្រើប្រាស់ទឹកពណ៌សម្រាប់គូរគំនូរ ផាត់ពណ៌បានត្រឹមត្រូវ។<br>ចរិយាសម្បទា៖<br>- រីករាយ និងសហការគ្នាបានល្អ<br>- ពេញចិត្តនឹងស្នាដៃរបស់ខ្លួន<br>- អភិវឌ្ឍន៍អារម្មណ៍ផ្សេងៗ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម៤ឆ្នាំ |
| រយៈពេល | - ៣០នាទី(១ម៉ោងសិក្សា) |
| សម្ភារៈ | - ទឹកពណ៌ ជក់អេប៉ុងសម្រាប់បោះត្រា (យកអេប៉ុងកាត់តូចៗចងភ្ជាប់ជាមួយមែកឈើតូច ឬចង្កឹះ) ឬជក់សម្រាប់គូរ ឬផាត់ពណ៌ ក្រដាស ទឹកពណ៌ ចានលាយពណ៌ កែវទឹកដើម្បីលាងជក់ កូនកន្សែងសើម៖<br>• ក្រដាសដែលប្រើរួចម្ខាងសម្រាប់កុមារគូរសេរី ឬរៀបចំរូបភាពដែលមានស្រាប់សម្រាប់ផាត់ពណ៌ដូចជា រូបសត្វ បន្លែ ផ្លែឈើ អាហារ...<br>• ឧបករណ៍គូរគំនូរផ្សេងទៀតដូចជាខ្មៅដៃពណ៌ គូល័រទៀន អាចជំនួសដោយទឹកពណ៌បាន។ |
| របៀបលេង | - ឱ្យកុមារគូរ ឬផាត់ពណ៌តាមការចូលចិត្ត |
| លក្ខខណ្ឌ | - គ្មាន |

## ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

### បរិស្ថាន





- បែងចែកកុមារជាក្រុមតូចៗអង្គុយនៅជុំវិញតុ
- រៀបចំសម្ភារៈសម្រាប់ក្រុមនីមួយៗ ក្នុងកញ្ច្រែង ដើម្បីឱ្យកុមារចេះទុកដាក់សម្ភារៈមានសណ្តាប់ធ្នាប់ល្អ។

### ការចូលរួមរបស់គ្រូ





- ពន្យល់ពីរបៀបប្រើសម្ភារៈ។ (ឧទាហរណ៍៖ របៀបប្រើដក់បរិមាណពណ៌ទឹកបន្តិចបន្តួចជាមួយដក់ សូមប្រយ័ត្នកុំឱ្យកំពប់ពណ៌ទឹកជាដើម)។
- លើកទឹកចិត្ត ទុកឱកាសឱ្យកុមារគូរតាមចំណូលចិត្ត គំនិត និងភាពច្នៃប្រឌិតរបស់កុមារ។ ក្នុងការលាយពណ៌ មិនមានខុស ឬត្រូវនោះទេសម្រាប់កុមារ។
- សង្កេតមើលសកម្មភាពឆ្លើយតបរបស់កុមារ និងនិយាយអំពីអ្វីដែលពួកគេកំពុងធ្វើ
- បន្ទាប់ពីលេងដក់អេប៉ុងរួចហើយ ឱ្យកុមារ លាងសម្អាត និងទុកកន្លែងដើមវិញ
- លើកទឹកចិត្តកុមារឱ្យទុកដាក់សម្ភារៈប្រើប្រាស់ឱ្យបានត្រឹមត្រូវ។



## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



- កុមារចូលចិត្តគូរគំនូរដោយប្រើទឹកពណ៌។ ឃើញដូច្នេះ គ្រូបានរៀបចំសកម្មភាព សម្រាប់គូរគំនូរ និងផាត់ទឹកពណ៌។
- កុមារីម្នាក់បានបោះត្រារាងមូលជាច្រើននៅលើក្រដាសដោយ ប្រើដក់ អេប៉ុងដែលគ្រូបានរៀបចំ។ គ្រូបានសួរថាតើទាំងនេះជាអ្វី ហើយនាងបានឆ្លើយតបថា «ទាំងនេះគឺជាថ្មនៅក្នុងទឹកជ្រោះ។ ខ្ញុំលេងនៅទីនោះជាមួយគ្រួសាររបស់ខ្ញុំ» ។ កុមារាម្នាក់ទៀតបានប្រើទឹកពណ៌គូររូបហើយនិយាយទៅកាន់គ្រូថា «ខ្ញុំបានគូរឡាន ខ្ញុំចង់បើកឡាននេះ»។ កុមារម្នាក់ៗចូលចិត្តគំនូរតាមរយៈការច្នៃប្រឌិតរៀងខ្លួន។
- បន្ទាប់ពីធ្វើសកម្មភាពចប់ គ្រូបានដាក់តាំងស្នាដៃកុមារនៅជ្រុងសិល្បៈ ដើម្បីឱ្យកុមារ និងឪពុកម្តាយពេញចិត្តចំពោះពួកគេ។ ពេលឃើញស្នាដៃរបស់ខ្លួនដាក់តាំង កុមារខ្លះនិយាយថា«លើកក្រោយខ្ញុំចង់ប្រើពណ៌ផ្សេង ហើយគូររូបមិត្តភក្តិខ្ញុំ»។
- តាមរយៈការអនុវត្តសកម្មភាពនេះគ្រូបានដឹងពីចំណុចមួយចំនួន។ កុមារខ្លះមិនទាន់ចេះប្រើទឹកពណ៌ទេ ដូច្នេះគ្រូគួរតែរៀបចំទឹកពណ៌បន្តិចបន្តួចនៅក្នុងចាននីមួយៗជាមុន ដើម្បីឱ្យកុមារអាចប្រើវាបានយ៉ាងងាយស្រួល។ ដូចគ្នានេះដែរ កុមារខ្លះបានប្រើពណ៌ទឹកពួកគេមានចិត្តរំភើប និងព្យាយាមប្រើប្រាស់ទឹកពណ៌យ៉ាងសប្បាយ។ អ្នកគ្រូគិតថាលើកក្រោយគួរលើកទឹកចិត្តឱ្យកុមារ និងមាតាបិតារៀបចំសម្លៀកបំពាក់ធម្មតាសម្រាប់សកម្មភាពបែបនេះ ដើម្បីឱ្យកុមារបានធ្វើសកម្មភាពបានពេញលេញដោយមិនសូវខ្លាចប្រឡាក់។



ពិតមែនហើយ! ខ្ញុំចូលចិត្តផាត់ពណ៌។



បន្ទាប់ពីសកម្មភាពគំនូរស្នាដៃរបស់កុមារទាំងអស់ត្រូវបានដាក់តាំងនៅជ្រុងសិល្បៈ។

## ៣.៤. ជ្រុងល្បែង



ជ្រុងល្បែង គឺជាកន្លែងទុកដាក់សម្ភារៈល្បែងសម្រាប់ឱ្យកុមារលេងមានដូចជាល្បែង សាងសង់ ឡូកឡាក់ ឡូតូ ដូមីណូ ផ្គុំរូប ល្បែងច្នៃប្រឌិត និងល្បែងចិត្តចលភាព (បាល់ កង ថង់ខ្សាច់ កន្ត្រក ខ្សែលោតអន្ទាក់...) សម្រាប់ឱ្យកុមារលេង ទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេ និងទុកដាក់របស់ទាំងនេះឱ្យមានរបៀបរៀបរយមានសណ្តាប់ធ្នាប់ល្អ និងធ្វើឱ្យកុមារចង់លេង។

### ៣.៤.១. លទ្ធផលរំពឹងទុកលើការអភិវឌ្ឍរបស់កុមារ

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់ឈ្មោះជ្រុងល្បែង និងប្រភេទសម្ភារៈមាននៅក្នុងជ្រុង<br>- ប្រាប់បានពីឈ្មោះល្បែង របៀបលេង របៀបរៀបចំទុកដាក់ទៅតាមទីកន្លែង។ |
| បំណិនសម្បទា | - បង្ហាញឈ្មោះ និងប្រភេទសម្ភារៈមាននៅក្នុងជ្រុង<br>- កំណត់ល្បែង របៀបលេង និងរៀបចំទុកដាក់ត្រូវតាមទីកន្លែង<br>- ជ្រើសរើសសម្ភារៈដែលគេចូលចិត្តបានដោយខ្លួនឯង ស្គាល់នូវអ្វីដែលពួកគេចូលចិត្ត និងអភិវឌ្ឍន៍ការយល់ដឹងដោយខ្លួនឯង។ |
| ចរិយាសម្បទា | - ស្រឡាញ់ ចូលចិត្ត ថែរក្សាសម្ភារៈទុកដាក់ទៅតាមទីកន្លែង និងមានសណ្តាប់ធ្នាប់ល្អដោយខ្លួនឯង<br>- លេងដោយប្រុងប្រយ័ត្ន និងមានសុវត្ថិភាព<br>- ទំនាក់ទំនងល្អ សហការគ្នាដោយរីករាយ និងលេងល្បែងដោយមិនបង្កទំនាស់<br>- ចាប់អារម្មណ៍ទៅលើអក្សរដែលសរសេរឈ្មោះ និងស្លាកសញ្ញាដែលបានបិទសម្គាល់។ |



### ៣.៤.២. ការរៀបចំ

**ក. ការរៀបចំជ្រុងល្បែង៖**

- រៀបចំជ្រុងសម្ភារៈល្បែងដោយដាក់ធ្នើរ ទូ ឬកញ្ជ្រែងនៅកន្លែងដាក់លាក់មួយ។
- ដាក់សម្ភារៈល្បែង ឱ្យសមស្របនឹងចំនួនកុមារ ធ្វើយ៉ាងណាឱ្យកុមារទាំងអស់អាចមានល្បែងលេងមួយលេងក្នុងពេលតែមួយ។
- ការជ្រើសរើសសម្ភារៈល្បែងអាចទិញពីផ្សារ ផលិតដោយគ្រូ និងកុមារជាពិសេសសម្ភារៈផលិតពីសំណល់អាចកែច្នៃបាន។

**ខ. ការប្រើប្រាស់៖** ការរៀបចំធ្នើរឱ្យសមស្របនឹងកម្ពស់កុមារ ដើម្បីងាយស្រួលក្នុងការយកលេង និងទុកដាក់នៅកន្លែងដើមវិញបន្ទាប់ពីលេងរួច។

- បែងចែកសម្ភារៈតាមប្រភេទ តាមក្រុម ហើយដាក់ក្នុងកញ្ជ្រែង កន្ត្រក ឬប្រអប់ក្រដាសត្រឹមត្រូវ។ បិទស្លាកសញ្ញាសម្គាល់នៅលើកញ្ជ្រែងនីមួយៗ តាមការច្នៃប្រឌិតរបស់គ្រូ។ គ្រូអាចយករូបពីកញ្ចប់សម្ភារៈល្បែង ឬប្រអប់ក្រដាសសម្ភារៈមកបិទលើកញ្ជ្រែងដូចក្នុងរូបខាងស្តាំក៏បានដែរ។
- សម្អាតធ្នើរ និងល្បែងជាប្រចាំ។
- ការរៀបចំសម្ភារៈផ្លាស់ប្តូរតាមប្រភេទល្បែង។ ល្បែងខ្លះមានបំណែកតូចៗជាច្រើន ដូចជាល្បែងផ្គុំរូបជាដើម។ ដើម្បីកាត់បន្ថយការបាត់បង់បំណែកទាំងនេះ យើងរៀបចំប្រអប់ដាក់ដាច់ដោយឡែក និងបិទស្លាកសញ្ញាសម្ភារៈល្បែងទាំងនោះ។



- ណែនាំកុមារពីការប្រើប្រាស់ធ្នើរនេះជាប្រចាំ ដោយពន្យល់ពីមុខល្បែងនីមួយ របៀបលេង និងរបៀបទុកដាក់នៅពេលលេងរួច។
- ក្នុងករណីខ្លះ គ្រូរៀបចំជ្រុងនេះជាមួយកុមារដើម្បីបង្រៀនគាត់ពីរបៀបទុកដាក់សម្ភារៈ និងមានសណ្តាប់ធ្នាប់។



## ឧទាហរណ៍

### ល្បែងចាប់គូ



| | |
|---|---|
| មុខវិជ្ជា | - បុរេគណិត៖ ល្បែង ចាប់គូពណ៌ និងរូបភាពដូចគ្នា |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីរូបភាព ពណ៌ និងរបៀបលេង<br>- ប្រាប់ពីចំនួនគូៗនៃកំប៉ុងរូបភាព។<br>បំណិនសម្បទា៖<br>- ពន្យល់បានពីន័យនៃគូរបស់រូបភាព និងរៀបរាប់ពីពណ៌<br>- មានសមត្ថភាពសមហេតុផល( ចាប់គូរូបភាព/វត្ថុដូចគ្នា ឬមានទំនាក់ទំនងគ្នា )។<br>ចរិយាសម្បទា៖<br>- ចែករំលែករូបភាព សប្បាយរីករាយ និងចេះសហការគ្នាក្នុងការលេង<br>- មានភាពអត់ធ្មត់ក្នុងការលេង<br>- មានភាពរហ័សរហួនក្នុងការលេង។ |
| ថ្នាក់/អាយុ | - កម្រិតខ្ពស់៥ឆ្នាំ |
| រយៈពេល | - ៣០នាទី( ១ម៉ោងសិក្សា ) |
| សម្ភារៈ | - កែវជ័របិទរូបជាគូៗ<br>- តុសម្រាប់ក្រុមកុមារ |

| | |
|---|---|
| របៀបលេង | - ប្រាប់ឈ្មោះល្បែង<br>- បែងចែកកុមារជាក្រុមតូចៗក្នុងមួយក្រុមចាប់ពី២នាក់ឡើងទៅ<br>- រៀបកែវលើតុឱ្យកុមារសង្កេត មុនពេលលេង<br>- កុមារត្រូវយកកែវដែលមានរូបដូចគ្នាដាក់ត្រួតពីលើគ្នាឱ្យត្រូវគូ ហើយយកដាក់នៅខាងមុខរៀងៗខ្លួន<br>សម្គាល់៖ ល្បែងនេះអាចលេងជាលក្ខណៈបុគ្គល ឬក្រុម។ |
| លក្ខខណ្ឌ | - កុមារប្រមូលបានកែវដែលត្រូវគូៗរូបភាពដូចគ្នាច្រើនជាងគេជាអ្នកឈ្នះ។ |

### ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

#### បរិស្ថាន





- ចែកកុមារជាក្រុមតូចតាមចំនួនដាក់ស្លែង
- រៀបចំតុ ឬទីកន្លែងតាមចំនួនក្រុម
- រៀបចំសម្ភារៈល្បែងសម្រាប់ក្រុមនីមួយៗតិច ឬច្រើនគូតាមចំនួនកុមារ និងចំនួនគូនៃកែវដែលមានរូបភាព
- បន្ទាប់ពីលេងរួចកុមារបានរៀបចំដាក់ក្នុងកញ្ច្រែង និងជួយរៀបចំសម្ភារៈត្រូវកន្លែងដើមវិញ។

#### ការចូលរួមរបស់គ្រូ





- ណែនាំពីរបៀបលេង
- សាកល្បង និងលេងជាមួយកុមារប្រកបដោយការសប្បាយរីករាយ
- ដើរមើលតាមក្រុម ដើម្បីឱ្យដឹងថាកុមារមានបញ្ហាអ្វីខ្លះពេលកំពុងលេង
- សម្របសម្រួល និងលើកសរសើរដល់កុមារ
- សង្កេតពីសកម្មភាពឆ្លើយតបរបស់កុមារ។

## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



នៅពេលលេងដំបូង កុមារមិនទាន់យល់ពីរបៀបលេងទេ ទោះបីជាបានលេងសាកល្បងម្តងរួចហើយក៏ដោយ។ កុមារខ្លះចេះតែប្រមូលមកដាក់ខាងមុខកន្លែងរបស់ខ្លួន ទាំងខុសគូក៏មាន ខណៈពេលដែលកុមារខ្លះហាក់ដូចមិនដឹងថាត្រូវធ្វើអ្វី។ កុមារខ្លះទៀតមិនសូវសប្បាយចិត្តទេដោយសារតែលេងមិនឈ្នះគេសោះ ដោយនិយាយថា«ដណ្តើមមិនឈ្នះគេសោះ»។ ឃើញស្ថានភាពបែបនេះ គ្រូជួយកុមារដែលលែងមិនឈ្នះគេនោះ។ គ្រូបានពន្យល់ពីរបៀបលេងម្តងទៀត និងលើកទឹកចិត្តឱ្យលេងបន្តទៀត។ បន្ទាប់ពីលេង២ទៅ៣ដង កុមារចាប់ផ្តើមយល់ពីរបៀបលេងបានកាន់តែច្បាស់។ កុមារខ្លះដែលលេងមុនដំបូងមានភាពយឺតយ៉ាវលើកនេះចាប់ផ្តើមលឿនជាងមុនបន្តិចម្តងៗ។

កុមារខ្លះមើលទៅហាក់ដូចជាមិនទាន់លេងអស់ចិត្ត ព្រោះមិនទាន់បានឈ្នះនៅឡើយ។ ឃើញប្រតិកម្មដូច្នេះ គ្រូបានប្រាប់កុមារថា«អ្នកគ្រូនឹងរៀបល្បែងនេះនៅជ្រុងល្បែងសម្រាប់ប្អូនៗដែលចង់លេងបន្តបាននៅពេលចេញលេង» ហើយក៏រៀបទុកនៅជ្រុងនោះ។ កុមារមួយចំនួនបានទៅលេងបន្តនៅជ្រុងនេះនៅពេលចេញលេង។

តាមរយៈការលេងល្បែងនេះ គ្រូសង្កេតឃើញថាកុមារបានរៀនសូត្រជាច្រើនដូចជា៖
- ស្គាល់ពីបញ្ញត្តិគូ ស្គាល់រូបរាង ពណ៌ និងចំនួន។
- កុមារកាន់តែមានភាពរហ័សរហួនបន្ទាប់ពីលេងបាន២ទៅ៣ដង។
- កុមារចេះចែករំលែក។ កុមារខ្លះចាប់បានរូបដូចគ្នា ក្នុងនោះមានម្នាក់សុខចិត្តប្រគល់កំប៉ុងរបស់ខ្លួនឱ្យមិត្តភក្តិម្នាក់ទៀត បើទោះបីដឹងថាធ្វើបែបនេះគេអាចនឹងចាញ់ក៏ដោយ។ កុមារខ្លះទៀតជួយមិត្តភក្តិរបស់គេស្វែងរកគូ។
- គ្រូទទួលបានបទពិសោធថា បើមានការលេងល្បែងនេះលើកក្រោយ គួរផលិតចំនួនកំប៉ុងឱ្យបានកាន់តែច្រើន។
- កុមារខ្លះបាននិយាយថា«ហេតុអ្វីបានជាក្រុមរបស់យើងសុទ្ធតែស្រី» ដូច្នេះ ត្រូវរៀបចំឱ្យមានតុល្យភាពយេនឌ័រនៅពេលក្រោយ។



កុមារចេះតែប្រមូលកែវដាក់មុខរៀងខ្លួនបើទោះបីជាខុសគូក៏ដោយ



គ្រូពន្យល់បន្ថែមដល់កុមារតាមក្រុមនីមួយៗ



កុមាររីករាយនៅពេលដែលលេងឈ្នះ




រៀបចំល្បែងនៅជ្រុងល្បែង ឱ្យកុមារបានលេងនៅពេលក្រោយ

## ៣.៨. ជ្រុងសិក្សា

ជ្រុងសិក្សាគឺជាជ្រុងដែលរៀបចំឡើងសម្រាប់ទុកដាក់សម្ភារៈបង្រៀន និងរៀនដូចជាសៀវភៅរឿងនិទាន សៀវភៅឬផ្ទាំងរូបភាពផ្សេងៗទាក់ទងនឹងការសិក្សារបស់កុមារ និងសម្ភារៈដែលរៀនរួចតាមមុខវិជ្ជា។ គ្រូត្រូវរៀបចំទុកដាក់របស់របរទាំងនេះឱ្យមានរបៀបរៀបរយ មានសណ្ដាប់ធ្នាប់ ថែរក្សាអនាម័យឱ្យបានល្អតាមមុខវិជ្ជានីមួយៗ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់កុមារឱ្យចង់លេងល្បែងទាំងនោះដោយពេញចិត្ត។

### ៣.៨.១. ធ្នើរ ឬកន្លែងដាក់សៀវភៅ







ធ្នើរ ឬកន្លែងដាក់សៀវភៅគឺជាកន្លែងរៀបដាក់តាំងសៀវភៅសម្រាប់កុមារយកមកអានបានតាមតម្រូវការ។ សៀវភៅរូបភាពបានជះឥទ្ធិពលជាច្រើនដល់កុមារ។ ទោះបីជាកុមារមិនចេះអានអក្សរក៏ដោយ កុមារអាចអានរូបភាព។ កុមារចងចាំសាច់រឿងដែលគ្រូបានអាន ឬនិទាន ហើយពួកគាត់ចង់ឃើញសៀវភៅនេះម្ដងទៀត។ ចុងក្រោយ កុមារទទួលបាននូវសារអប់រំផ្សេងៗពីសៀវភៅរូបភាពកាន់តែចាប់អារម្មណ៍លើភាសា និងការសរសេរ អភិវឌ្ឍន៍ញាណ ការស្រមើស្រមៃ និងបំណិនគិត។ ដូច្នេះ ត្រូវបង្កលក្ខណៈងាយស្រួលដល់កុមារអាចយកសៀវភៅដែលពួកគាត់ចូលចិត្តមកអានបានគ្រប់ពេល។

#### ៣.៨.១.១. លទ្ធផលរំពឹងទុកការអភិវឌ្ឍរបស់កុមារតូច

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់ពីប្រភេទសៀវភៅ និងចំណងជើងសៀវភៅ<br>- ប្រាប់បានពីទីកន្លែងទុកដាក់សៀវភៅ និងរូបភាពដែលមានក្នុងសៀវភៅរឿង។ |
| បំណិនសម្បទា | - កំណត់ពីប្រភេទសៀវភៅ និងចំណងជើងសៀវភៅ<br>- អភិវឌ្ឍការផ្ដោតអារម្មណ៍តាមរយៈការស្ដាប់រឿង<br>- អភិវឌ្ឍញាណ ការស្រមើស្រមៃពេលស្ដាប់សាច់រឿង និងពេលទទួលបានអារម្មណ៍ផ្សេងៗ។ |
| ចរិយាសម្បទា | - ស្រឡាញ់ ចូលចិត្ត ថែរក្សាសៀវភៅ និងទុកដាក់មានសណ្ដាប់ធ្នាប់<br>- បណ្ដុះឱ្យកុមារមានទម្លាប់អានសៀវភៅ<br>- ចែករំលែកអារម្មណ៍ផ្សេងៗជាមួយមិត្តភក្ដិពេលស្ដាប់រឿងនិទាន<br>- អភិវឌ្ឍពាក្យពេចន៍និយាយស្ដីបានត្រឹមត្រូវ។ |

#### ៣.៨.១.២. ការរៀបចំ

**ក. ការរៀបចំ៖** រៀបចំកន្លែងដាក់សៀវភៅ ដោយមានធ្នើរ ទូ ឬកញ្ច្រែងនៅក្នុងថ្នាក់រៀន និងមានលក្ខណៈងាយស្រួលសម្រាប់គ្រូ និងកុមារប្រើប្រាស់ដូចខាងក្រោម៖

- ជ្រើសរើសប្រភេទធ្នើរ ទូ ឬកញ្ច្រែង ហោប៉ៅសៀវភៅ ទៅតាមលទ្ធភាពរបស់សាលារៀន តែសូមពិនិត្យថាតើវាមានសុវត្ថិភាព អាចដាក់តាំងសៀវភៅបាននឹងល្អ និងសមស្របនឹងកម្ពស់របស់កុមារតូច។
- ដាក់ធ្នើរ ទូ ឬកញ្ច្រែង ហោប៉ៅសៀវភៅ នៅទីតាំងដែលកុមារងាយយកសៀវភៅមកអាន។
- រៀបចំឱ្យមានកន្លែងសម្រាប់កុមាររីករាយអានសៀវភៅ ដោយដាក់កម្រាលកៅស៊ូ ឬការ៉ូ ដើម្បីបង្កើនផាសុកភាពសម្រាប់កុមារអាន ដើម្បីញែកកន្លែងឱ្យកុមារដឹងថាកន្លែងណាសម្រាប់អង្គុយអានសៀវភៅ។
- អាស្រ័យតាមប្រភេទធ្នើរ រៀបចំដាក់តាំងឱ្យឃើញក្របសៀវភៅដើម្បីបង្កើតភាពទាក់ទាញដល់កុមារ។
- បើសិនជាមានសៀវភៅច្រើន គួររៀបសៀវភៅតាមប្រភេទតាមជាន់ ដូចជាប្រភេទសៀវភៅរូបភាព សៀវភៅវិទ្យាសាស្ត្រ ឬសៀវភៅរឿងបរទេសជាដើម។
- ណែនាំកុមារជាប្រចាំពីរបៀបយកអាន និងដាក់សៀវភៅទៅកន្លែងដើមវិញ។
- រៀបចំឱ្យមានកន្លែងសម្រាប់ដាក់តាំងសៀវភៅមកដល់ថ្មី បើអាចធ្វើទៅបាន។

**ខ. បរិមាណសៀវភៅ៖** រៀបចំចំនួនសៀវភៅសមស្របនឹងចំនួនកុមារ ធ្វើយ៉ាងណាឱ្យកុមារម្នាក់មានសៀវភៅមួយក្បាលអានក្នុងពេលតែមួយទាំងអស់គ្នា។

**គ. ការថែទាំ និងជួសជុល**

- ថែទាំ សម្អាត និងរក្សាអនាម័យជាប្រចាំ។
- ជួសជុលសៀវភៅជាប្រចាំ។
- ណែនាំកុមារឱ្យរាយការណ៍ទៅគ្រូនៅពេលមានសៀវភៅខូចខាត ឬរហែក។

## ឧទាហរណ៍

### ការអានសេរីបន្ទាប់ពីស្តាប់ការនិទានរឿង

ក្នុងម៉ោងភាសាខ្មែរ គ្រូមត្តេយ្យសិក្សាបាននិទានរឿង«ទន្សាយចង់ស៊ីចេក»។ គ្រូសង្កេតឃើញថាកុមារពេលនោះកំពុងតែមានការចាប់អារម្មណ៍ខ្លាំងនឹងសាច់រឿង ហើយចង់ស្វែងយល់បន្ថែម។ ដូច្នេះ គ្រូរៀបចំបរិស្ថានដោយមានសៀវភៅរូបភាពជាច្រើនឱ្យកុមារអានយ៉ាងសប្បាយរីករាយ។



| | |
|---|---|
| មុខវិជ្ជា | - ភាសាខ្មែរ៖ អំណានសេរី |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីរបៀបបើកសៀវភៅអាន<br>- ប្រាប់បានពីរូបភាពនៅក្នុងសៀវភៅ<br>- ប្រាប់បានពីទិសអំណាន។<br>បំណិនសម្បទា៖<br>- បើកសៀវភៅបានត្រឹមត្រូវ និងតាមទិសអំណាន<br>- រៀបរាប់ពីសកម្មភាព តាមលំដាប់លំដោយក្នុងសាច់រឿង។<br>ចរិយាសម្បទា៖<br>- បណ្តុះបានទម្លាប់ក្នុងការអានសៀវភៅ<br>- បណ្តុះបានភាពស្និទ្ធស្នាល និងសប្បាយរីករាយ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម ៤ឆ្នាំ |
| រយៈពេល | - ៣០នាទី |
| សម្ភារៈ | - សៀវភៅនិទានរឿង រៀបចំនៅជ្រុងសិក្សា(ធ្នើរដាក់សៀវភៅ)ជាពិសេសសៀវភៅរឿង «ទន្សាយចង់ស៊ីចេក» សម្រាប់ដាក់តាំង<br>- កម្រាលកៅស៊ូ ឬកន្ទេលសម្រាប់កុមារអង្គុយស្តាប់រឿងនិទាន។ |
| របៀបដំណើរការ | - ឱ្យកុមារអានសេរីក្នុងថ្នាក់រៀន។ |



### ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

#### បរិស្ថាន





- រៀបចំតុទៅម្ខាង ដើម្បីឱ្យកុមារស្តាប់រឿងនិទានបានងាយស្រួល
- រៀបចំកន្លែងឱ្យកុមារស្តាប់រឿងនិទាន(កម្រាលកៅស៊ូ ឬកន្ទេលដែលងាយស្រួលសម្រាប់កុមារអង្គុយស្តាប់ និងអានរឿងនិទាន)
- រៀបចំកន្លែងកុមារអានសៀវភៅនៅក្នុងថ្នាក់រៀន
- រៀបចំសៀវភៅក្នុងធ្នើរឱ្យបានស្អាត និងតាំងបង្ហាញសៀវភៅរឿង «ទន្សាយចង់ស៊ីចេក»
- រៀបចំដាក់តាំងសៀវភៅរឿង«ទន្សាយចង់ស៊ីចេក» មានដូចជា ចេកពិត ត្រកួនដែលជាចំណីរបស់ទន្សាយ រូបតុក្កតាសត្វទន្សាយ សៀវភៅរូបភាពផ្លែឈើ និងរូបសត្វនៅជ្រុងវិទ្យាសាស្ត្រ ដើម្បីបន្ថែមការស្រាវជ្រាវ ពេលចេញលេង។

#### ការចូលរួមរបស់គ្រូ



- នៅពេលនិទានរឿងចប់ គ្រូដឹងថាកុមារពិតជាចង់ស្វែងយល់ពីសាច់រឿងបន្ថែម។ ដើម្បីទាញការចាប់អារម្មណ៍របស់កុមារ នៅចុងបញ្ចប់នៃសាច់រឿង គ្រូបានប្រាប់ពីការរៀបចំនៅធ្នើរសៀវភៅ និងជ្រុងវិទ្យាសាស្ត្រ។
- លើកទឹកចិត្តឱ្យកុមារអាន និងខ្ចីសៀវភៅយកទៅផ្ទះ ដើម្បីឱ្យមាតាបិតាអានឱ្យស្តាប់
- បានចូលរួមជាមួយសិស្ស និងណែនាំពីរបៀបបើកសៀវភៅ ព្រមទាំងប្រាប់ពី រូបភាពសត្វ វត្ថុផ្សេងៗដល់កុមារ។

## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



កុមារខ្លះបានទៅកន្លែងធ្នើរដាក់សៀវភៅ រួចទាញយកសៀវភៅរឿងដែលទើបបាននិទាន និងខ្លះទៀតរកសៀវភៅណាដែលគាត់ចូលចិត្ត ហើយអង្គុយអានរៀងៗខ្លួន ឬជាក្រុម។ កុមារមើលរូបបណ្ដើរ និទានរឿងឡើងវិញបណ្ដើរតាមសាច់រឿង និងរូបភាពដែលគ្រូបាននិទាន ក្នុងពេលនោះមានកុមារម្នាក់បានប្រាប់ទៅមិត្តភក្តិគាត់ថា «អូនចង់មើលសៀវភៅដែលមានសត្វ និងផ្កាច្រើន» បន្ទាប់មកក៏បានទៅរកសៀវភៅនោះយកមកមើលជាមួយគ្នាយ៉ាងសប្បាយរីករាយ ដោយសួរគ្នាទៅវិញទៅមកថា«នេះជាសត្វអ្វី នោះជាសត្វអ្វី»។

កុមារ«មង្គល»បានយកដៃរុញសន្លឹកសៀវភៅបើកម្ដងមួយទំព័រៗ ពេលនោះមានកុមារម្នាក់ទៀតឃើញដូច្នេះបានប្រាប់ថា«កុំបើកអ៊ីចឹងត្រូវកាន់ចុងសន្លឹកបើកម្ដងមួយទំព័រៗ» ហើយគាត់បានធ្វើតាម។

ចំណែកឯជ្រុងវិទ្យាសាស្ត្រវិញ កុមារបន្តការសង្កេតទៅលើរូបភាពដែលបានឃើញពេលគ្រូនិទាន។ កុមារខ្លះនិយាយឆ្លើយឆ្លងគ្នាថា«នេះជាទន្សាយអម្បាញ់មិញ» «ទន្សាយនេះល្អិចណាស់» ជាដើម។ កុមារខ្លះ សង្កេតមើលផ្លែចេក ហើយនិយាយថា«ទន្សាយចូលចិត្តស៊ីផ្លែចេក ខ្ញុំក៏ចូលចិត្តញ៉ាំផ្លែចេកដែរ» ពួកគេបានប្រាប់ទៅមិត្តផ្សេងទៀតពីត្រកួន និងសត្វទន្សាយដែលគ្រូបានដាក់តាំងនៅជ្រុងវិទ្យាសាស្ត្រផងដែរ។

តាមរយៈសកម្មភាពនេះ គ្រូសង្កេតឃើញថា កុមារចាប់អារម្មណ៍សៀវភៅកាន់តែច្រើន នៅពេលដែលគ្រូបានឱ្យកុមារអានដោយសេរី បន្ទាប់ពីនិទានរឿង។ លើសពីនេះទៅទៀត ការខ្ចីសៀវភៅយកទៅអាននៅផ្ទះ ក៏មានការកើនឡើងជាងសព្វដង។

បន្ទាប់ពីរៀបចំសកម្មភាពនេះរួចមក គ្រូបានរកឃើញថា គួរតែបង្ហាញកុមារពីរបៀបបើកសៀវភៅឱ្យបានត្រឹមត្រូវ ព្រោះកុមារខ្លះមិនទាន់ដឹងពីការប្រើប្រាស់សៀវភៅនៅឡើយ។



កុមារស្ដាប់រឿងនិទាន«ទន្សាយចង់ស៊ីផ្លែចេក»។



កុមារស្វែងរកសៀវភៅអាននៅធ្នើរដាក់សៀវភៅបន្ទាប់ពីបានស្ដាប់រឿងនិទាន



គ្រូចូលរួមអានសៀវភៅជាមួយកុមារ។



មាតាបិតាខ្ចីសៀវភៅទៅអាននៅផ្ទះ

## ៣.៨.២. ធ្នើរ ឬកន្លែងដាក់សម្ភារៈសិក្សា






ធ្នើរ ឬកន្លែងដាក់សម្ភារៈសិក្សាជាទីកន្លែងរក្សាទុកដាក់ឯកសាររដ្ឋបាល សម្ភារៈប្រើប្រាស់ និងសម្ភារៈឧបទេសសម្រាប់ដំណើរការរៀន និងបង្រៀនមុខវិជ្ជានីមួយៗ បានត្រៀមផ្គត់ផ្គង់បម្រុងជាស្រេចតាមស្ថានភាពមូលដ្ឋានជាអាទិ៍មាន៖ សៀវភៅ បញ្ជីរដ្ឋបាលថ្នាក់រៀន ក្រដាស ប៊ិក ខ្មៅដៃ បន្ទាត់ កាវ ស្កុតកំណាត់ កន្ត្រៃ កាំបិត ខ្សែ អំបោះ ម្ជុលដេរ តួអក្សរ ឬលេខមានស្នាមចុច ប័ណ្ណ ព្យញ្ជនៈ ស្រៈ លេខ ផ្ទាំងរូបភាព សម្ភារៈពញ្ញាក់អារម្មណ៍ ម៉ែត្រវាស់កម្ពស់ ជញ្ជីងថ្លឹងទម្ងន់ៗលៗ អាស្រ័យលើការរៀបចំរបស់គ្រូ សម្ភារៈនៅទីនេះក៏អាចរៀបចំនៅជ្រុងល្បែងបានដែរ។

### ៣.៨.២.១. ប្រសិទ្ធភាព

- សម្រួលដល់ការបង្រៀន និងរៀន។
- ងាយស្រួលយកសម្ភារៈមកប្រើប្រាស់ក្នុងកិច្ចការងាររដ្ឋបាល។
- គ្រប់គ្រងសម្ភារៈបានគង់វង្ស និងមានសណ្ដាប់ធ្នាប់ល្អ។

### ៣.៨.២.២. ការរៀបចំ

**ក. សម្រាប់គ្រូ៖**

- ការរៀបចំ
  - ជ្រើសរើសធ្នើរ ទូដែក ទូឈើ ទៅតាមលទ្ធភាពរបស់សាលា។ ជាការល្អ យើងអាចជ្រើសរើសទូមានសោរ ដើម្បីបង្ការកុំឱ្យកុមារយកសម្ភារៈក្នុងទូរបស់គ្រូលេង។
- ការប្រើប្រាស់
  - រៀបតាមប្រភេទឯកសារ តាមមុខវិជ្ជា ឬសម្ភារៈ ក្នុងកញ្ច្រែង ឬប្រអប់ ដោយមានបិទស្លាកសញ្ញាសម្គាល់។
  - ផ្លាស់ប្ដូរសម្ភារៈបង្រៀនក្នុងធ្នើរជារៀងរាល់ខែដើម្បីកាត់បន្ថយបរិមាណក្នុងធ្នើរ។



- ការថែទាំ
  - សម្អាតធ្នើរ ឬកន្លែងដាក់សម្ភារៈជាប្រចាំ។
  - ណែនាំកុមារកុំឱ្យយកសម្ភារៈរបស់គ្រូលេង។




**ខ.សម្រាប់កុមារ៖**

- ការរៀបចំ
  - រៀបធ្នើរ ឬតុសម្រាប់ដាក់តាំងសម្ភារៈដែលគ្រូបង្រៀនរួចទុកឱ្យកុមារលេងមានដូចជាល្បែងគូសតាមស្នាម ចុចៗ លេខ ព្យញ្ជនៈ ល្បែងគូសភ្ជាប់ចំនួនទៅនឹងលេខ...។
- ការប្រើប្រាស់
  - រៀបចំសម្ភារៈល្បែងសិក្សាតាមមុខវិជ្ជាដាក់តាំងឱ្យកុមារងាយមើលឃើញ និងងាយយកលេង។
  - ផ្លាស់ប្ដូរល្បែងជាប្រចាំដែលមានបន្ថែមហ្វឹត និងអេប៉ុងលុបសម្រាប់កុមារលេង។




- ការថែទាំ
  - សម្អាតធ្នើរ ឬកន្លែងដាក់សម្ភារៈល្បែងជាប្រចាំ។
  - ណែនាំកុមារជាប្រចាំពីការរៀបចំទុកដាក់សម្ភារៈល្បែងនៅកន្លែងដើមវិញពេលលេងរួច។




ល្បែងសិក្សាតាមមុខវិជ្ជាក៏អាចដាក់នៅជ្រុងល្បែងឱ្យកុមារលេងបានដែរ។

## ឧទាហរណ៍

### ល្បែងផ្គុំចំនួនរូបភាពទៅនឹងលេខពី១ ដល់១០



មុននឹងលេងល្បែងផ្គុំរូប កុមារបានរៀនពីចំនួន រាប់ចំនួន និងយល់ន័យនៃ ចំនួន១ ដល់១០ រួចហើយ ដោយគ្រូបានបង្ហាញពីចំនួនរូបភាពឱ្យត្រូវនឹងចំនួនលេខ ព្រមទាំងរូបផ្សេងៗ សម្រាប់ឱ្យកុមារមានការចងចាំពីលេខទាំងនោះបានល្អជាងមុន។ ផ្សារភ្ជាប់នឹងសកម្មភាពនេះ គ្រូបានរៀបចំល្បែងមួយដែលហៅថា «ផ្គុំចំនួនរូបភាពទៅនឹងលេខ១ ដល់១០» ធ្វើបែបនេះ កុមារនឹងបានពង្រីកការយល់ដឹង ក៏ដូចជាបង្កើនការចងចាំពីចំនួនរូបភាព និងស្គាល់លេខនីមួយៗកាន់តែច្បាស់បន្ថែមទៀត ហើយនៅក្នុងល្បែងនេះ គ្រូបានរៀបចំបរិស្ថានសម្រាប់កុមារលេងផងដែរ។

| | |
|---|---|
| មុខវិជ្ជា | - បុរេគណិត ល្បែងផ្គុំចំនួនរូបភាពទៅនឹងលេខពី១ដល់១០ |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីពណ៌ ឈ្មោះរូបភាព ចំនួន និងលេខពី១ ដល់១០<br>បំណិនសម្បទា៖<br>- រាប់ចំនួនរូបភាព និងលេខបានពី១ ដល់១០<br>- ផ្គុំចំនួន និងលេខបានត្រឹមត្រូវ។<br>ចរិយាសម្បទា៖<br>- សប្បាយរីករាយ និងសហការគ្នាក្នុងពេលលេងបានល្អ។ |
| ថ្នាក់/អាយុ | - កម្រិតមធ្យម ៤ឆ្នាំ |
| រយៈពេល | - ៣០នាទី |
| សម្ភារៈ | - ល្បែងផ្ទាំងរូបភាព( ៤ឈុត ) |
| របៀបលេង | - កុមារផ្គុំចំនួនរូបភាពឱ្យត្រូវនឹងលេខ |



១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

#### បរិស្ថាន





- ដាក់សម្ភារៈនៅក្នុងប្រអប់ ហើយបិទស្លាកសញ្ញាសម្គាល់ទុកលើធ្នើរសម្ភារៈសិក្សា ឬតុ ងាយស្រួលកុមារមើលឃើញ និងយកលេង
- បែងចែកកុមារជាក្រុមតូចៗ
- រៀបតុផ្គុំបញ្ចូលគ្នា និងដាក់តាមចំនួនក្រុមកុមារ
- រៀបចំប្រអប់សម្ភារៈល្បែងដាក់លើតុឱ្យហើយ ងាយស្រួលដល់កុមារលេង។

#### ការចូលរួមរបស់គ្រូ



- បង្រៀនពីចំនួន និងលេខដល់កុមារ មុនពេលចាប់ផ្តើមលេងល្បែង
- ណែនាំពីរបៀបលេងទៅកាន់កុមារ
- ដើរមើលការលេងរបស់កុមារតាមក្រុម ដើម្បីឱ្យដឹងថាកុមារមានបញ្ហាអ្វីខ្លះពេលកំពុងលេង
- សម្របសម្រួល និងលើកសរសើរដល់កុមារ
- ចូលរួមលេងជាមួយកុមារប្រកបដោយភាពសប្បាយរីករាយ
- នៅចុងម៉ោងមុនពេលចេញលេង ណែនាំកុមារថា«អ្នកគ្រូបានរៀបល្បែងផ្គុំរូបភាពនៅធ្នើរសម្ភារៈសិក្សា និងតុ ហើយបើកូនណាចង់លេង អាចលេងដោយសេរីបាន»។

## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល



កុមារពិតជាសប្បាយរីករាយនៅពេលឃើញគ្រូបានរៀបចំសម្ភារៈលេងនៅលើតុរបស់ពួកគេ បន្ទាប់មកគ្រូចាប់ផ្តើមឱ្យកុមារលេង។ តាមរយៈការលេងនេះ គ្រូបានសង្កេតឃើញថា មានកុមារមួយចំនួនតូចហាក់បីដូចជាមិនសូវជាចាប់អារម្មណ៍នឹងការលេងទេ ហើយព្រមទាំងមានកុមារខ្លះទៀតលេងមិនត្រូវសោះ បើទោះបីជាលេងបាន២ទៅ៣ដងក៏ដោយ។ ពេលនោះ គ្រូបានព្យាយាមណែនាំពីរបៀបលេង និងលើកទឹកចិត្តដល់កុមារដែលមិនសូវចង់លេង ចុងក្រោយពួកគេក៏បានលេងដោយជោគជ័យទាំងអស់គ្នា និងបានទះដៃស្រែកថា«ជយោ! យើងធ្វើបានហើយ»។

បន្ទាប់ពីលេងចប់ គ្រូបានរៀបចំសម្ភារៈទាំងនោះនៅជ្រុងសិក្សា ហើយបានណែនាំពួកគេឱ្យលេងនៅម៉ោងចេញលេង។ ក្នុងអំឡុងពេលនោះដែរ មានកុមារប្រមាណ៣ទៅ៤នាក់បានយកទៅលេងល្បែងនៅធ្នើរសម្ភារៈសិក្សា។ ក្រោយមកមានកុមារជាច្រើននាក់ទៀតចង់លេងដែរ តែគ្រូបានណែនាំឱ្យកុមារចាំលេងនៅពេលក្រោយទៀត ដោយសារកន្លែងចង្អៀត។



នៅក្នុងសកម្មភាពនេះ យើងឃើញថាមានចំណុចមួយចំនួនគ្រូគួរតែកែលម្អនៅពេលក្រោយ៖

- គ្រូគួររៀបចំបណ្ណរូបភាព និងបណ្ណលេខឱ្យបានទំហំធំជាងនេះ ដើម្បីឱ្យកុមារយល់ និងមើលឃើញបានច្បាស់។
- គ្រូគួររៀបចំឱ្យកុមារលេងល្បែងនៅពាក់កណ្តាលម៉ោងសិក្សា ( ឧ៖ នៅម៉ោង៨:៣០ព្រឹក ឬម៉ោង៩:០០ព្រឹក ) ចៀសវាងកុមារមានភាពនឿយហត់ពេលលេងល្បែងនេះ
- គ្រូគួរលើកទឹកចិត្តកុមារឱ្យបានច្រើន បើទោះបីជាគាត់លេងខុសដដែលៗក៏ដោយ។



គ្រូពន្យល់បន្ថែមដល់កុមារ



កុមារជួយគ្នាស្វែងរកគូរូបភាព និងចំនួន



កុមារលេងល្បែងនៅពេលសម្រាក



# ជំពូកទី ៣
# ការរៀបចំបរិស្ថានក្រៅថ្នាក់រៀន

## បរិស្ថានក្រៅថ្នាក់



ក្រៅពីការរៀបចំបរិស្ថានក្នុងថ្នាក់រៀន គ្រូក៏ត្រូវយកចិត្តទុកដាក់ខ្ពស់ដល់ការរៀបចំបរិស្ថានក្នុងសាលារៀន ឬក្រៅថ្នាក់រៀនឱ្យមានលក្ខណៈទាក់ទាញជាទីមេត្រីរបស់កុមារ ដោយត្រូវផ្តោតសំខាន់ទៅលើបរិស្ថានស្រស់ស្អាតមានអនាម័យ មានម្លប់ មានសុវត្ថិភាព ក្នុងនោះមានល្បែងក្រៅថ្នាក់ មានសួនជីវៈចម្រុះ មានកន្លែងទុកដាក់សំរាម មានកន្លែងលាងដៃ មានបង្គន់អនាម័យ (កុមារា កុមារី) និងទីធ្លាស្រឡះល្អងាយស្រួលកុមារលេងល្បែងចលនា ឬធ្វើសកម្មភាពតាមកម្មវិធីផ្សេងៗ ដើម្បីទាក់ទាញកុមារឱ្យស្រឡាញ់ចូលចិត្តមក សាលារៀន និងរីករាយចូលរួមគ្រប់សកម្មភាព។

## ១. ប្រសិទ្ធភាពការអភិវឌ្ឍរបស់កុមារ

បរិស្ថានក្រៅថ្នាក់មានសារៈសំខាន់ណាស់ក្នុងការជួយកុមារដូចជា៖

- ការអភិវឌ្ឍបុគ្គលិកលក្ខណៈ ចរិយាសម្បទាប្រកបដោយចរិតសង្គម(ឧ៖ ចេះសម្របសម្រួលខ្លួន ចេះអធ្យាស្រ័យ ចេះចែករំលែក សហការ ជួយគ្នាជាដើម)។
- សុខភាពល្អ រាងកាយមាំមួន ស្វាហាប់ រហ័សរហួន និងក្លាហាន។
- បទពិសោធក្នុងការផ្សារភ្ជាប់ខ្លួនទៅក្នុងបរិស្ថានធម្មជាតិ វត្ថុ មនុស្ស និងមានមូលដ្ឋានគ្រឹះនៃជំនាញអរូបនិយ្តា។
- កុមារភ្ញាក់រឭកក្នុងការរើសសំរាម និងមានអនាម័យលាងសម្អាតដៃជាប់ជាប្រចាំ។



## ២. ល្បែងក្រៅថ្នាក់







សាលាមត្តេយ្យសិក្សាមានសកម្មភាពច្រើនយ៉ាង កុមាររៀនតាមរយៈការលេង និងបរិស្ថាន សកម្មភាពរៀនក្នុង និងក្រៅថ្នាក់សំខាន់ដូចគ្នា។ កុមារតូចត្រូវការអភិវឌ្ឍសុខភាព និងរាងកាយជាចាំបាច់ ដូច្នេះគ្រូត្រូវរៀបចំសួនកុមារមានទោងឡើងចុះ ក្តាររំអិល រង្វិលផែនដី ឡើងខ្សែពួរ លូនចូលក្នុងសំបកកង់រថយន្ត លេងអាងខ្សាច់ កន្លែងធ្វើសកម្មភាពផ្សេងៗដូចជា សកម្មភាពសិល្បៈ ឬចិត្តចលភាព មានហាត់ប្រាណតាមរឿងនិទានបទចម្រៀងជាដើមជាសកម្មភាពក្រៅថ្នាក់ដែរ តាមលទ្ធភាពសាលាដែលអាចធ្វើទៅបាន។ កុមារអាចតោងឡើង លោត លូន ជិះ រំអិល រមៀល ហក់ រត់ និងហាត់ប្រាណ។ សកម្មភាពទាំងនេះធ្វើឱ្យកុមារសប្បាយរីករាយ និងអភិវឌ្ឍន៍រូបរាងកាយ។

### ២.១. លទ្ធផលរំពឹងទុកការអភិវឌ្ឍរបស់កុមារតូច

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីឈ្មោះល្បែងដែលគ្រូបានរៀបចំនៅក្នុងបរិវេនសាលារៀន<br>- ប្រាប់បានពីរបៀបលេងនៅតាមទីកន្លែងនៃការរៀបចំនីមួយៗ។ |
| បំណិនសម្បទា | - លេងឱ្យបានត្រឹមត្រូវតាមទីកន្លែងដែលបានរៀបចំនីមួយៗ។ |
| ចរិយាសម្បទា | - អត់ធ្មត់សម្របសម្រួលខ្លួនដោយអធ្យាស្រ័យគ្នាទៅវិញ ទៅមក<br>- សប្បាយរីករាយជាមួយមិត្តភក្តិ គ្រូ ឬគ្រួសារកុមារ។ |

## ២.២. ការរៀបចំ

- គ្រូផលិត និងកែច្នៃល្បែងក្រៅថ្នាក់ពីវត្ថុមានស្រាប់នៅមូលដ្ឋាន និងតុបតែងលាបពណ៌ឱ្យមានលក្ខណៈទាក់ទាញ ងាយស្រួលលេង សមស្របតាមវ័យកុមារ និងធានាសុវត្ថិភាព។
- ល្បែងក្រៅថ្នាក់ត្រូវមានកម្រាលទន់ៗ មានក្រាលស្មៅ ឬខ្សាច់សើម មានការជួសជុលឱ្យថ្មីជានិច្ច និងមានការថែទាំ សម្អាតជាប្រចាំ។
- ល្បែងក្រៅថ្នាក់ត្រូវរៀបចំឱ្យឆ្ងាយពីដើមឈើធំដែលមានមែកពុកផុយ ឬដើមឈើដែលមានផ្លែជ្រុះ។
- ការរៀបចំល្បែងក្រៅថ្នាក់នីមួយៗត្រូវរើសទីតាំងឱ្យបានសមស្រប តាមលក្ខខណ្ឌបច្ចេកទេសដើម្បីបញ្ចៀសគ្រោះថ្នាក់ដល់កុមារនៅពេលលេង។

## ២.៣. ការអនុវត្តល្បែងក្រៅថ្នាក់

- កុមារលេងល្បែងក្រៅថ្នាក់តាមចំណង់ចំណូលចិត្តនៅក្រៅម៉ោងសិក្សា ក្នុងអំឡុងពេលដែលគ្រូកំពុងទទួលកុមារ(ម៉ោងចូល) និងនៅពេលចេញលេង។ កុមារលេងល្បែងក្រៅថ្នាក់តាមខ្លឹមសារកម្មវិធីដែលគ្រូបានគ្រោងទុក (ល្បែងដណ្តើមស្លឹកឈើ ល្បែងលោតបារ ល្បែងដកកន្ទុយ ឬល្បែងដែលបានរៀបចំឡើងតាមកម្មវិធីលម្អិតសម្រាប់មត្តេយ្យសិក្សាក្នុងមុខវិជ្ជាចិត្តចលភាព)។
- កុមារលេងល្បែងក្រៅថ្នាក់ទៅតាមកម្មវិធីដែលបានប្រារព្ធដូចជា ពិធីកីឡាកុមារ ទិវាកុមារអន្តរជាតិ១មិថុនា បុណ្យចូលឆ្នាំថ្មី កម្មវិធីវិស្សមកាលធំជាដើម។

ដើម្បីឱ្យកុមារលេងល្បែងក្រៅថ្នាក់បានសប្បាយរីករាយ មានសុវត្ថិភាព គ្រូគប្បី៖

- ណែនាំកុមារឱ្យលេងដោយប្រុងប្រយ័ត្ន លេងជាមួយគ្នា ចេះចែករំលែក មានការអធ្យាស្រ័យមិនបង្កជម្លោះ និងចេះសម្របខ្លួនឱ្យចុះសម្រុងជាមួយគ្នា បង្កើនទំនុកចិត្តដល់កុមារ។
- តាមដាន សម្របសម្រួល និងលេងជាមួយកុមារ។
- បង្កលក្ខណៈឱ្យគ្រួសារកុមារលេងជាមួយកូនៗមុនពេលចូលរៀន ក្នុងគោលបំណង ជួយសម្រាលបន្ទុក។
- គ្រូឱ្យឱកាសដល់កុមារផ្សេងទៀតបានចូលរៀន ឬធ្វើការងារផ្សេងៗ និងបង្កើនទំនុកចិត្តលើកុមារ។



គូរល្បែងផ្សេងៗលើកម្រាលបេតុងធ្វើជាល្បែងក្រៅថ្នាក់








សំបកកង់រថយន្ត ម៉ូតូចាស់ៗជាធនធានដ៏ល្អសម្រាប់ច្នៃធ្វើល្បែងក្រៅថ្នាក់

## ២.៨. អាងខ្សាច់



សកម្មភាពសិក្សារបស់កុមារតូចនៅកន្លែងលេងអាងខ្សាច់មានភាពសប្បាយរីករាយ ទាំងនេះគឺជាវិធីដ៏ទាក់ទាញដើម្បីឱ្យកុមារទទួលការអប់រំនៅខាងក្រៅថ្នាក់។ អាងខ្សាច់មានសក្តានុពលច្រើនដូចជាមន្ទីរពិសោធន៍វិទ្យាសាស្ត្រ វិស្វកម្ម គណិតវិទ្យា និងការបង្កើតរូបរាងផ្សេងៗ។ កុមារតូចចូលចិត្តលេងខ្សាច់ជាមួយមិត្តភក្តិរបស់គេ ដូច្នេះគ្រូត្រូវរៀបចំអាងខ្សាច់មានសម្ភារៈប៉ែលធុងទឹក ស្លាបព្រា ចានប្លាស្ទិច និងសម្ភារៈចាស់ៗ កែវ រថយន្តដឹក រថយន្តចូក បាយឡុកបាយឡផ្សេងៗ។ អាងខ្សាច់ជាឱកាសដ៏ល្អដើម្បីឱ្យកុមារតម្រៀបរបស់របរលេងផ្ទះបាយប្លាស្ទិច បង្កើតបានជាគំនិតច្នៃប្រឌិតតាមចំណង់ចំណូលចិត្តពួកគេ លេងដោយសកម្មភាពរស់រវើក។

### ២.៨.១. លទ្ធផលរំពឹងទុកការអភិវឌ្ឍរបស់កុមារតូច

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីឈ្មោះរូបរាងឬទ្រង់ទ្រាយដែលបានបង្កើតឡើង<br>- ប្រាប់បានពីរបៀបបង្កើតរូបរាងផ្សេងៗតាមរយៈសម្ភារៈ និងគំនិតច្នៃប្រឌិត។ |
| បំណិនសម្បទា | - កំណត់បានពីបរិមាណទឹកលាយជាមួយដីខ្សាច់សម្រាប់លេងបង្កើតរូបរាងទៅតាមវត្ថុប្រើប្រាស់ និងគំនិតច្នៃប្រឌិត<br>- បង្កើតនិងបកស្រាយអំពីទំនាក់ទំនងរវាងរូបរាង ទំហំ ទ្រង់ទ្រាយ បរិមាណ ចំនួនរបស់ខ្លួន និងមិត្តភក្តិដែលបានបង្កើតឡើង។ |
| ចរិយាសម្បទា | - ចូលចិត្តលេងខ្សាច់ជាមួយមិត្តភក្តិ<br>- មានទម្លាប់ល្អក្នុងការរៀបចំទុកដាក់សម្ភារៈពេលលេងរួច និងមានបម្រុងប្រយ័ត្នក្នុងការលេងខ្សាច់។ |



### ៣.២. ការរៀបចំ

**ក. ការរៀបចំ៖**

- គ្រូរៀបចំអាងខ្សាច់នៅកន្លែងសមរម្យ ដូចជានៅក្បែរថ្នាក់រៀននៅចំហៀង ឬខាងមុខថ្នាក់។
- អាងខ្សាច់គួរមានស៊ុមរៀបដោយឥដ្ឋ បន្ទះឈើ បន្ទះដំរ សំបកដបទឹកសុទ្ធ សំបកដបទឹកក្រូច សំបកកង់រថយន្ត ព័ទ្ធជុំវិញកុំឱ្យខ្សាច់ហូរចេញ។
- អាងខ្សាច់គួរនៅក្រោមម្លប់ដើមឈើ ឬមានដំបូល តែគួរឱ្យត្រូវកំដៅដើម្បីរក្សាអនាម័យល្អ។
- រៀបចំកន្លែងសម្រាប់លាងជើង លាងដៃដោយសាប៊ូ និងជូតជើង ជូតដៃដោយកូនកន្សែងក្រោយពេលលេងដីខ្សាច់រួច។

**ខ. ការប្រើប្រាស់៖**

- គ្រូរៀបចំសម្ភារៈដូចជា ប៉ែល ធុងទឹក ស្លាបព្រា ចានប្លាស្ទិច សម្ភារៈចាស់ៗ សល់ពីផ្ទះបាយ ដំរប្លាស្ទិច កែវ រថយន្តដឹក រថយន្តចូក បាយឡុកបាយឡផ្សេងៗ ឬរបស់របរកែច្នៃពីសំណល់អាចកែច្នៃបានជាដើម។
- ផ្តល់ឱកាសឱ្យកុមារលេងសេរីលើអាងខ្សាច់តាមការចូលចិត្តរបស់ពួកគេ។
- ឱ្យកុមារយកសម្ភារៈដែលលេងរួចទៅទុកដាក់ឱ្យបានត្រឹមត្រូវនៅកន្លែងដើមវិញ។
- ណែនាំកុមារឱ្យលាងសម្អាតដៃជើងបន្ទាប់ពីលេងរួច។

**គ. ការថែទាំ៖**

- គ្រូពិនិត្យមើលដីខ្សាច់ឱ្យបានច្បាស់លាស់ ចៀសវាងមានអំបែងកែវ អំបែងដប ឬរបស់កខ្វក់ផ្សេងៗដូចជាលាមកសត្វជាដើម។
- ដើម្បីចៀសវាងសត្វឆ្កែ ឆ្មា មាន់ ទាចូលទៅធ្វើឱ្យកខ្វក់កន្លែងលេងដីខ្សាច់ ដូច្នេះត្រូវប្រើសំណាញ់ មកព័ទ្ធបាំង ឬគ្របអាងខ្សាច់។
- គួរបាញ់ថ្នាំការពារសត្វល្អិត ខ្ទួយ ក្អែប ស្រមោចភ្លើង សង្ការ និងសត្វទិចនានា។
- បោសសម្អាតជាប្រចាំធ្វើអនាម័យកុំឱ្យមានសំរាមបណ្តាលឱ្យស្អុយរលួយលើខ្សាច់។
- រៀបចំខ្សាច់ឱ្យបានស្អាត ខ្សាច់មានភាពស្មើសាច់គ្រប់គ្រាន់សម្រាប់កុមារលេង បើខ្សាច់មិនគ្រប់ត្រូវដាក់ខ្សាច់បន្ថែម។

## ឧទាហរណ៍

### ល្បែងបើកហាងអាហារ





ល្បែងក្រៅថ្នាក់មិនមែនមានតែទោងយោល ក្តាររំអិល និងការរត់លេងដេញចាប់គ្នានៅខាងក្រៅថ្នាក់នោះទេ។ អាងខ្សាច់នេះក៏ជាកន្លែងលេងដ៏ទាក់ទាញបំផុតសម្រាប់កុមារ និងមានអត្ថប្រយោជន៍ផ្សេងៗលើការអភិវឌ្ឍកុមារ។ ជាមួយនឹងការរៀបចំបរិស្ថានតិចតួចកុមារនឹងអាចពង្រីកការលេងរបស់ពួកគេដោយគ្មានទីបញ្ចប់។ យើងនឹងណែនាំជូននូវឈុតឆាកមួយដែលកុមារចូលចិត្តលេងលក់ដូរក្នុងហាងដោយប្រើអាងខ្សាច់។

| | |
|---|---|
| មុខវិជ្ជា | - បុរេគណិត(ល្បែងបើកហាងអាហារ) |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានចំនួន រូបរាង តម្លៃ និងឈ្មោះវត្ថុដែលបានបង្កើតឡើងដោយផ្ទាល់។<br>បំណិនសម្បទា៖<br>- រាប់បានចំនួន រូបរាងដែលបានបង្កើត និងតម្លៃរបស់របវត្ថុនោះ។<br>ចរិយាសម្បទា៖<br>- ចូលចិត្តលក់របស់របរ ទិញនំ និងអាហារ<br>- រីករាយក្នុងការប្រើប្រាស់ចលនាម្រាមដៃដើម្បីបង្កើតរូបភាព<br>- រីករាយសហការជាមួយមិត្តភក្តិ<br>- រីករាយក្នុងការស្វែងរក និងគិតតាមរយៈការសាកល្បង និងកំហុស។ |
| ថ្នាក់/អាយុ | - កម្រិតទាប មធ្យម និងខ្ពស់ ៣ ដល់៥ឆ្នាំ។ |
| រយៈពេល | - ៣០នាទី (១ម៉ោងសិក្សា) |
| សម្ភារៈ | - ប្រដាប់ប្រដាក្មេងលេងនៅក្នុងអាងខ្សាច់ បាយឡុកបាយឡសម្ភារៈប្រើប្រាស់សល់ពីផ្ទះបាយដូចជាពែងប្លាស្ទិចដបស្លាបព្រាចានជាដើម<br>- វត្ថុធម្មជាតិ ដូចជា ផ្កាដែលគេបោះបង់ចោល ស្លឹក គ្រាប់ជាដើម<br>- ទឹកលាយជាមួយដីខ្សាច់<br>- ទឹកសម្រាប់លាងដៃ និងជើងក្រោយពេលលេងរួច<br>- កន្សែងសម្រាប់ជូតដៃជើង។ |
| របៀបលេង | - ណែនាំពីសុវត្ថិភាពដល់កុមារមុនពេលលេង<br>- ឱ្យកុមារលេងដោយសេរីតាមការចូលចិត្ត។ |
| លក្ខខណ្ឌ | - មានអាងខ្សាច់ ឬកន្លែងសម្រាប់លេងខ្សាច់។ |

## ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

### បរិស្ថាន





- ពិនិត្យមើលស្ថានភាពរបស់អាងខ្សាច់ជាមុនហើយយកកម្ទេចកម្ទីដែលមានគ្រោះថ្នាក់ដូចជាវត្ថុមុតស្រួចជាដើមដើម្បីសុវត្ថិភាព
- រៀបចំសម្ភារៈគ្រប់គ្រាន់នៅជិតអាងខ្សាច់ជាមុន រួមទាំងប្រដាប់ប្រដាមានប្រយោជន៍ផងដែរ
- រៀបចំទឹកដើម្បីឱ្យកុមារឃើញពីភាពប្រែប្រួលនៃខ្សាច់នៅពេលលាយទឹក
- រៀបចំកន្ត្រករក្សាសម្ភារៈដើម្បីឱ្យកុមារអាចរៀបចំដោយខ្លួនឯងបាននៅចុងបញ្ចប់នៃសកម្មភាព។

### ការចូលរួមរបស់គ្រូ



- ផ្តល់គំនិត និងជំនួយតាមតម្រូវការនៅពេលដែលកុមារមិនច្បាស់ពីរបៀបធ្វើឱ្យរូបភាពរបស់ខ្លួន ក្លាយជាការពិត
- គ្រូក៏ចូលរួមលេងផងដែរដើម្បីជួយសម្រួលដល់កុមារពង្រីកសកម្មភាពក្នុងការលេង
- គ្រូប្រាប់កុមារឱ្យលាងដៃ និងជើងមុនពេលចូលថ្នាក់រៀន។



## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល

កុមារចាប់ផ្តើមបង្កើតវត្ថុតូចៗដោយប្រើពែងប្លាស្ទិច ប៉ុន្តែដោយសារតែខ្សាច់នៅស្ងួតពេក កុមារមិនអាចបង្កើតរូបរាងដូចដែលពួកគេស្រមៃចង់បានយ៉ាងងាយស្រួលនោះទេ។ កុមារបានព្យាយាមដោះស្រាយដោយខ្លួនឯង ហើយឃើញទឹកនៅក្នុងធុងទឹក។ កុមារស្រោចទឹកលើដីខ្សាច់ ប៉ុន្តែពួកគេមិនអាចទទួលបានរាងត្រឹមត្រូវនៅឡើយទេពីព្រោះពួកគេចាក់ទឹកច្រើនពេក ដីខ្សាច់ក្លាយជាដីភក់។ ឃើញដូច្នេះ គ្រូបានណែនាំគន្លឹះតូចមួយដល់កុមារ គឺកាត់បន្ថយបរិមាណទឹក។ ទីបំផុតពួកគេអាចបង្កើតវត្ថុជាច្រើនប្រភេទបាន។



ដីខ្សាច់ជាប់គ្នានៅពេលវាសើម។

ពេលកំពុងធ្វើវត្ថុទាំងនោះ កុមារីម្នាក់បានបង្កើតគំនិតបើកហាងកាហ្វេ។ នាងបានដាក់ខ្សាច់នៅក្នុងពែងដូចជាកាហ្វេហើយតម្រង់ជួរនៅលើគែមនៃប្រអប់ខ្សាច់។ នាងស្រែក«តើអ្នកចង់បានកាហ្វេទេ? ខ្ញុំលក់វា» ឮបែបនេះអ្នកគ្រូដើរតួជាអតិថិជន ហើយសួរនាង«កាហ្វេនេះថ្លៃប៉ុន្មាន?» អ្នកគ្រូទិញដោយប្រើស្លឹកឈើជំនួសក្រដាសប្រាក់។



ខ្ញុំលក់កាហ្វេល្អបំផុត!

នាងឆ្លើយ«មួយពែងថ្លៃ១០០០រៀល»។ គ្រូក៏បាននិយាយថា«កាហ្វេនេះមានក្លិនឈ្ងុយណាស់។ ក្រៅពីនេះវាមានរសជាតិឆ្ងាញ់»។ កុមារផ្សេងទៀតបានឃើញដូចនេះ ក៏ធ្វើតាមដែរ។ «ខ្ញុំលក់នំមួយថ្លៃ៥.៥០០រៀល» «ខ្ញុំលក់ការ៉េមថ្លៃ៥០០រៀលវាផ្អែមឈ្ងុយឆ្ងាញ់ណាស់»។ កុមារចូលចិត្តលេងទិញ និងលក់ឱ្យគ្នាទៅវិញទៅមក។



សូមអរគុណចំពោះការទិញ។

អំឡុងពេលនៃសកម្មភាពអ្នកគ្រូបានឃើញថាការលេងផ្ទាល់ជាមួយដីខ្សាច់ងាយនឹងប្រឡាក់ឯកសណ្ឋានរបស់កុមារ។ គ្រូបានសម្រេចចិត្តជូនដំណឹងដល់ឪពុកម្តាយរបស់ពួកគេឱ្យរៀបចំខោ ឬសម្លៀកបំពាក់កីឡាតាមរយៈក្តារខៀនព័ត៌មានដើម្បីឱ្យកុមារអាចអង្គុយលេងបានតាមសប្បាយ។

## ៣. សួនជីវៈចម្រុះ



សួនជីវៈចម្រុះមានរុក្ខជាតិច្រើនមុខនៅសាលាមត្តេយ្យសិក្សាទៅតាមទំហំផ្ទៃដីរបស់សាលារៀន ងាយស្រួលសាប ឬបណ្តុះកូនរុក្ខជាតិ(គោក ទឹក និងអាកាស) ព្រមទាំងថែរក្សាកូនរុក្ខជាតិបានលូតលាស់ល្អមុនពេលយកទៅដាំ ឬ ស្ទូងតាមលទ្ធភាព និងអាចមានសត្វចិញ្ចឹមងាយៗដូចជាត្រី ចង្រិត...។ កុមារតូចគឺជាអ្នកវិទ្យាសាស្ត្រវ័យក្មេង ដូច្នេះការមានសួនជីវចម្រុះបង្កលក្ខណៈឱ្យកុមារបានសង្កេត ស្រាវជ្រាវ រុករក និងស្វែងយល់តាមចំណង់ចំណូលចិត្ត និងតាមតម្រូវការបង្រៀនរបស់គ្រូផងដែរ។ គេនិយាយថាកុមារមិនពិបាកនឹងញ៉ាំបន្លែទេ បើសិនគេជាអ្នកដាំបន្លែទាំងនោះដោយផ្ទាល់។

### ៣.២. លទ្ធផលរំពឹងទុកការអភិវឌ្ឍរបស់កុមារតូច

| | |
|---|---|
| វិជ្ជាសម្បទា | - ប្រាប់បានពីឈ្មោះ និងលក្ខណៈគ្រាប់ពូជ ឬកូនរុក្ខជាតិដែលអាចដុះល្អ តាមរយៈការសង្កេត និងពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយគ្រូបានត្រឹមត្រូវ<br>- ប្រាប់បានពីលក្ខខណ្ឌរស់នៅរបស់រុក្ខជាតិតាមរយៈការអនុវត្តដោយផ្ទាល់។ |
| បំណិនសម្បទា | - កំណត់បានពីគ្រាប់ពូជ ឬកូនរុក្ខជាតិដែលដុះបានល្អ រៀបរាប់បានពីការដាំដុះដំណាំងាយៗ តាម រយៈការដាំ ថែទាំជាបុគ្គល និងក្រុម បានត្រឹមត្រូវ។កំណត់ពីលក្ខខណ្ឌរស់នៅរបស់រុក្ខជាតិនីមួយៗ។ |
| ចរិយាសម្បទា | - កុមារបង្ហាញនូវស្មារតីភ្ញាក់រឭក ស្រឡាញ់ ទទួលខុសត្រូវថែទាំដាំដំណាំ ដោយគោរពតាមការណែនាំរបស់គ្រូបានត្រឹមត្រូវ<br>- មានទម្លាប់សង្កេត តាមដាន កត់ត្រាដោយគំនូសតាង សញ្ញាតាង និងការបង្ហាញហេតុផល<br>- ស្រឡាញ់ចូលចិត្តសម្រស់បរិស្ថាន<br>- មានម្ចាស់ការ ទទួលខុសត្រូវ ចេះជួយគ្នា សហការគ្នា។ |



### ៣.២. ការរៀបចំ

**ក. ការរៀបចំសួនជីវៈចម្រុះ**

- ជ្រើសរើសដីមួយកន្លែងតូចល្មមធ្វើជាច្បារដាំដំណាំគ្រប់ប្រភេទដែលងាយស្រួលដល់កុមារសាបបណ្តុះគ្រាប់ពូជដាំ ឬស្ទូងកូនដំណាំ និងថែរក្សា ដោយធានាសុវត្ថិភាពកុមារ។ ករណីសាលារៀនមានផ្ទៃដី អាចរៀបចំសួននៅលើដីតែម្តង តែបើគ្មានផ្ទៃដី អាចពិចារណាជម្រើសផ្សេងៗ ដូចជាដាក់ផើងផ្កាធំៗ ដាក់ពាងទឹកសម្រាប់ចិញ្ចឹមត្រី ឬដាំរុក្ខជាតិក្នុងទឹកជាដើម។
- ជ្រើសរើសជីវៈចម្រុះដូចជាបន្លែ ផ្កា កូនឈើ ត្រី ច្រើនមុខ ច្រើនពណ៌តាមលទ្ធភាពរៀងៗខ្លួន។
- ធ្វើរបងសាមញ្ញព័ទ្ធសួនពីស្បែនីឡុង ឬធ្វើពីឫស្សី ជាងដូង ជាងត្នោត ឬមែកឈើ មានខ្លោងទ្វារ និងស្លាក«**សួនជីវៈចម្រុះមត្តេយ្យសិក្សា**»។
- បើមានលទ្ធភាព រៀបចំឱ្យមានជីលាមកសត្វ ជីកំប៉ុស្តធម្មជាតិស្ងួត ឱ្យកុមារបានស្គាល់។
- រៀបចំសម្ភារៈស្រោចស្រពទឹក និងថែទាំងាយៗដូចជាធុងទឹក បោយទឹក ប៉ែលជាដើម តែត្រូវឱ្យសមស្របនឹងកុមារ។

  **គន្លឹះបន្ថែម៖** *ដាំផ្កាស្បៃរឿង ម្រះព្រៅ ស្លឹកគ្រៃ រំដេងធ្វើជារបង ឬអមរបងដើម្បីជួយទប់ស្កាត់សត្វល្អិតបំផ្លាញ។*

**ខ. ការផ្លាស់ប្តូរសកម្មភាព**

- គ្រូជាអ្នកគិតច្នៃប្រឌិតសកម្មភាពសាបព្រោះ ដាំ ស្ទូង និងថែទាំដំណាំដោយខ្លួនឯង។ សូមគិតថាតើគ្រូអាចធ្វើឱ្យកុមារចង់ដឹង ចង់ឮ ចង់ឃើញ ចង់ពិសោធ ចង់អនុវត្តន៍បង្កើនការយល់ដឹង ពិសេសធ្វើយ៉ាងណាឱ្យកុមារស្វែងយល់ដោយការសង្កេតស្រាវជ្រាវបន្ថែមលើប្រធានបទកំពុងរៀន។
- គ្រូអាចពិនិត្យមើលលើសកម្មភាពឆ្លើយតបរបស់កុមារថា តើគាត់ចាប់អារម្មណ៍លើអ្វីដែលមានក្នុងសួនជីវៈចម្រុះដែរ ឬទេ? និងត្រូវគិតថាគួររៀបចំសកម្មភាពដាំដុះអ្វីបន្ថែមទៀត។

**គ. ការថែទាំ**

- ថែទាំដោយស្រោចទឹក ដាក់ជី ដកស្មៅ ឬឱ្យចំណីសត្វជាប្រចាំ។
- អនុញ្ញាតឱ្យកុមារចូលរួមក្នុងសកម្មភាពថែទាំដើម្បីឱ្យពួកគាត់ទទួលបានបំណិនងាយៗតាមរយៈវេនសម្អាត ឬសកម្មភាពថ្នាក់រៀនដែលរៀបចំដោយគ្រូ។

### ៣.៣. ការអនុវត្តសកម្មភាពក្នុងសួនជីវៈចម្រុះ

- សាកល្បងនាំកុមារទស្សនាសង្កេតបរិវេណក្នុងសាលារៀនតាមខ្លឹមសារដែលបានកំណត់ ដោយនាំកុមារពិភាក្សាពីដីទំនេរ មានដីជាតិ ជិតប្រភពទឹក ជ្រើសរើសគ្រាប់ពូជ ឬកូនរុក្ខជាតិដែលនឹងដុះបានល្អ និងការការពារសត្វចូលស៊ីដំណាំ ដោយឱ្យកុមារបង្ហាញពីហេតុផលករណីកុមារសម្រេចចិត្តជ្រើសរើស។
- នាំកុមារជួយសម្អាតដី ជួយដីឱ្យត្រសុស ព័ទ្ធរបង ដោយឱ្យកុមារជួយតែសកម្មភាពងាយសមល្មមនឹងកម្លាំងកុមារ។
- ចំពោះដីដែលមិនអំណោយផលគ្រូអាចច្នៃប្រឌិតដាំដំណាំក្នុងផើង ឬថង់តាមលទ្ធភាព និងស្ថានភាពជាក់ស្តែង។
- នាំកុមារបណ្តុះ ឬសាបគ្រាប់ពូជ ឬដាំកូនរុក្ខជាតិ និងណែនាំពីរបៀបថែទាំ។
- បែងចែកវេនកុមារថែទាំដំណាំ និងណែនាំកុមារពីរបៀបថែទាំ ការប្រើប្រាស់សម្ភារៈ និងឧបករណ៍ថែសួនរួមទាំងការទុកដាក់របស់ទាំងនោះផងដែរ។
- កុមារតាមដានដំណាក់កាលលូតលាស់នៃដំណុះរុក្ខជាតិដោយកំណត់ត្រាគំនូសតាងលើតារាងលូតលាស់នៃដំណុះរុក្ខជាតិ។
- រាល់សកម្មភាពនៃការដាំដុះ គ្រូនាំកុមារសង្កេត និងបូកសរុបតាមដំណាក់កាលនីមួយៗ និងទាញការសន្និដ្ឋានពីលក្ខខណ្ឌរស់នៅរបស់រុក្ខជាតិ។
- គ្រូអាចនាំកុមារយកលទ្ធផលកូនរុក្ខជាតិដែលដាំបានដាក់តាំងនៅជ្រុងវិទ្យាសាស្ត្រតាមប្រធានបទ។







ប្រើសំបកកង់យន្តចាស់ៗ ឬប្រើផើងករណីសាលាមិនសូវមានដីទំនេរ

## ឧទាហរណ៍

### សង្កេតសួនជីវចម្រុះ





ថ្ងៃមួយនៅក្នុងម៉ោងសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ គ្រូបាននាំកុមារធ្វើសកម្មភាពសង្កេតរុក្ខជាតិនៅក្នុងសួនជីវៈចម្រុះ និងសួនផ្កានៅក្នុងសាលារៀន។ គ្រូប្រាប់កុមារឱ្យដើរជាក្រុម ពី៣ ទៅ៤នាក់ ហើយពួកគេមានភាពសប្បាយរីករាយណាស់ នៅពេលដែលបានផ្លាស់ប្តូរបរិយាកាសសិក្សា ដោយបានដើរសង្កេតរុក្ខជាតិ ក្រៅថ្នាក់រៀន។ កុមារចាប់អារម្មណ៍ទៅនឹងដើមរុក្ខជាតិប្លែកៗពីគ្នា ដូចជា ដើមចេក ផ្លែចេក ដើមក្រូចឆ្មារ ស្លឹកម្រះព្រៅ ស្លឹកគ្រៃ ស្លែ និងផ្កាផ្សេងៗទៀតជាដើម។

| | |
|---|---|
| មុខវិជ្ជា | - វិទ្យាសាស្ត្រ (សង្កេតសួនជីវៈចម្រុះ) |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីឈ្មោះដំណាំ និងផ្កា<br>- ប្រាប់បានពីក្លិន និងពណ៌នៃដំណាំ និងផ្កា។<br>បំណិនសម្បទា៖<br>- ពន្យល់បានពីប្រភេទដំណាំ និងផ្កាក្នុងសួន<br>- បញ្ជាក់បានដើមក្រូចមានបន្លាមានគ្រោះថ្នាក់។<br>ចរិយាសម្បទា៖<br>- រីករាយ ស្រឡាញ់ចូលចិត្ត ដំណាំបន្លែនិងផ្កាផ្សេងៗ<br>- មានបម្រុងប្រយ័ត្នចំពោះដើមឈើមានបន្លា និងមានគ្រោះថ្នាក់។ |
| ថ្នាក់/អាយុ | - មធ្យម និងខ្ពស់ ៤ ដល់៥ឆ្នាំ |
| រយៈពេល | - ៣០ ទៅ៦០នាទី |
| សម្ភារៈ | - កញ្ចៃ(អាស្រ័យលើចំនួនកុមារ និងបរិស្ថាន ឧបករណ៍សង្គ្រោះបឋម ម្ជុក ទឹកផឹក)។ |
| របៀបដំណើរការ | - ឱ្យកុមារលេងដោយសេរីតាមការចូលចិត្ត។ |
| លក្ខខណ្ឌ | - សួន ឬវត្ថុធម្មជាតិនៅសាលារៀន ភូមិ វាលស្រែ...។ |

### ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

#### បរិស្ថាន





- រៀបចំសួនជីវៈចម្រុះដែលមានផ្កាដើមឈើនៅទីធ្លាសាលា
- ពិនិត្យមើលទីតាំងដែលត្រូវទៅទស្សនាជាមុនដើម្បីការពារសុវត្ថិភាពកុមារ។

#### ការចូលរួមរបស់គ្រូ





- សំណួរបំផុស និងលើកទឹកចិត្តកុមារ ឱ្យចាប់អារម្មណ៍និងសង្កេតតាមផ្លូវ «តើកូនឃើញអ្វីខ្លះ?»
- ប្រាប់កុមារអំពីសញ្ញាណគ្រោះថ្នាក់ដូចជាជាន់ថ្មស្រួច ឬបន្លា
- ប្រាប់ពីរបៀបថែរក្សាធម្មជាតិដូចជារក្សាផ្កា ដំណាំផ្សេងៗ
- ចែករំលែកអ្វីដែលកូនៗដឹង អ្វីបានឃើញជាមួយមិត្តភក្តិ
- ឆ្លើយសំណួរដែលកុមារសួរអំពីផ្សេងៗគ្នា។

## ២. សកម្មភាពឆ្លើយតបរបស់កុមារ និងលទ្ធផល




កុមារភាគច្រើនចាប់អារម្មណ៍ក្លិនស្លឹកម្រះព្រៅហើយបាននិយាយថា«ស្លឹកនេះមានក្លិនឈ្ងុយណាស់» គ្រូឃើញ និងឮដូច្នេះក៏ប្រាប់កុមារថា«ស្លឹកនេះគេហៅថាស្លឹកម្រះព្រៅវាមានក្លិនឈ្ងុយ ហើយយើងក៏អាចយកវាទៅដាក់សម្លបានដែរ ដើម្បីបង្កើនក្លិនឈ្ងុយឆ្ងាញ់»។ កុមារ ៤ ទៅ៥នាក់នាំគ្នាឱនហិតក្លិនស្លឹកម្រះព្រៅដោយទឹកមុខសប្បាយ ពេញចិត្តនឹងក្លិនឈ្ងុយ។

រីឯកុមារមួយក្រុមទៀតចាប់អារម្មណ៍ទៅនឹងដើមក្រូចឆ្មារ និងផ្លែរបស់វា។ ពួកគេប្រាប់គ្នាថាដើមក្រូចឆ្មារនេះមានបន្លាច្រើនណាស់ ប្រសិនបើយើងប៉ះមិនប្រយ័ត្ន វាអាចបណ្ដាលឱ្យមុតដៃរបស់យើងបាន។ កុមារម្នាក់ទៀតចង្អុលហើយស្រែកថា«ខ្ញុំឃើញផ្លែរបស់វាហើយ ខ្ញុំចង់បេះវា ប៉ុន្តែប្រហែលជាវាមានរសជាតិជូរណាស់»។ ពេលនោះគ្រូបានប្រាប់កុមារថា«ពិតហើយកូនៗ ផ្លែរបស់វាមានរសជាតិជូរ ប៉ុន្តែឥឡូវកូនៗមិនអាចបេះវាបានទេ ពីព្រោះវានៅខ្ចី»។

បន្ទាប់ពីសង្កេតនៅក្នុងសួនជីវៈចម្រុះរួចមក គ្រូបាននាំកុមារមកសង្កេតក្នុងសួនផ្កាម្ដង កុមារា កុមារីចាប់អារម្មណ៍ទៅលើ ពណ៌ និងក្លិនរបស់ផ្កា។ កុមារម្នាក់ចាប់អារម្មណ៍លើផ្កាមួយទងមានពណ៌លឿងស្អាត ហើយបាននិយាយប្រាប់គ្រូថា «ខ្ញុំចង់កាច់ផ្កាមួយទងនោះណាស់ដើម្បីយកទៅជូនម្ដាយខ្ញុំ»។ គ្រូប្រាប់ថា«ផ្កានេះស្អាតពិតមែនហើយ តែកូនមិនអាចកាច់វាបានទេព្រោះគេដាំទុកសម្រាប់ចែកគ្នាមើល បើកូនចង់បានយើងសាកល្បងនាំគ្នាដាំហើយអាចកាច់យកទៅជូនម្ដាយកូនៗបានគ្រប់ៗគ្នា។»

បន្ទាប់ពីសង្កេតសួនផ្កាចប់ គ្រូបាននាំកុមារអង្គុយជារង្វង់នៅក្រោមម្លប់ដើមឈើក្បែរថ្នាក់រៀន គ្រូបានសួរទៅកុមារថា«តើកូនៗបានសង្កេតឃើញអ្វីខ្លះ? នៅក្នុងសួនជីវៈចម្រុះ និងសួនផ្កា?» កុមារ ឆ្លើយថា«ខ្ញុំឃើញផ្លែក្រូចឆ្មារ ផ្លែចេក ដើមស្លឹកម្រះព្រៅ ស្លែ ផ្កាពណ៌លឿង ផ្កាពណ៌ក្រហម ផ្កាតូចៗ ផ្កាម៉ោង១០ ផ្កាស្បៃរឿង...។ គ្រូបន្ត«តើកូនៗចង់ធ្វើអ្វីបន្តទៀត?» កុមារឆ្លើយថា «ខ្ញុំចង់ដាំផ្កាស្អាតៗ ខ្ញុំចង់បេះផ្លែក្រូចឆ្មារ ខ្ញុំចង់ញ៉ាំផ្លែចេកទុំ»។ កុមារភាគច្រើនចង់ដាំផ្កា អីចឹងពេលក្រោយយើងនាំគ្នាដាំផ្កា កូនៗត្រៀមដីដែលមានជីជាតិម្នាក់១កូនថង់ អ្នកគ្រូនឹងរកកូនផ្កា ឬគ្រាប់ផ្កាឱ្យកូនដាំ។



នេះគឺជាក្រូចឆ្មារ!
តើខ្ញុំអាចបេះវាបានទេ?



តើកូនបានរកឃើញអ្វីខ្លះនៅក្នុងសួនច្បារ?

## ៤. ទីកន្លែងធ្វើសកម្មភាពផ្សេងៗនៅក្រៅថ្នាក់



កន្លែងធ្វើសកម្មភាពផ្សេងៗក្រៅថ្នាក់ជាទីធ្លាទំនេរមួយសម្រាប់គ្រូអាចបត់បែនធ្វើសកម្មភាពផ្សេងៗជាមួយកុមារតាមតម្រូវការសកម្មភាពថ្នាក់រៀន ឬតម្រូវការរៀបចំជាព្រឹត្តិការណ៍ពិសេសផ្សេងៗ។ គ្រូអាចរៀបចំជាសកម្មភាពលេងកីឡា ល្បែងរាំដណ្តើមកៅអី លោតបាវប្រណាំង លូនក្នុងលូ លោតមឹក លោតអន្ទាក់ រកចាប់សត្វល្អិត និងធ្វើចលនាតាមគំនូសសញ្ញាជាដើម តាមមុខវិជ្ជាចិត្តចលភាព និងល្បែងផ្សេងៗកែច្នៃតាមចំណង់ចំណូលចិត្តកុមារ។

### ៤.១. ប្រសិទ្ធភាពការអភិវឌ្ឍរបស់កុមារ

- ផ្លាស់ប្តូរបរិយាកាសរៀន ធ្វើឱ្យកុមារកាន់តែរីករាយនឹងការរៀន ដោយគ្រូអាចបត់បែនធ្វើសកម្មភាពក្រៅថ្នាក់ជាជាងតែសកម្មភាពបង្រៀននៅក្នុងថ្នាក់។
- អភិវឌ្ឍន៍សុខភាពរាងកាយ រហ័សរហួន ពេលធ្វើសកម្មភាពក្រៅថ្នាក់។

### ៤.២ ការរៀបចំ

#### ក. ការរៀបចំ៖

- រៀបចំឱ្យមានទីកន្លែងទំនេរសម្រាប់គ្រូទុកធ្វើសកម្មភាពក្រៅថ្នាក់ ទំហំធំ ឬតូចតាមទំហំដែលសាលារៀនមាន។
- តាមការច្នៃប្រឌិត និងលទ្ធភាពរបស់ខ្លួន សាលារៀនអាចរៀបចំទីធ្លានេះជាការចាក់បេតុង ដាំស្មៅ ឬដីល្បាយខ្សាច់ដើម្បីសម្រួលដល់ការធ្វើសកម្មភាពមិនថារដូវប្រាំង ឬវស្សា។
- គូររូបនៅលើឥដ្ឋ ឬកម្រាលកៅស៊ូសម្រាប់កុមារធ្វើសកម្មភាពចិត្តចលភាព។
  - ☛ ប្រសិនបើសាលារៀនមានលទ្ធភាពអាចប្រើប្រាស់ធនធានមានស្រាប់នៅក្នុងសហគមន៍ រៀបចំសួនកុមារតាមការរៀបរាប់ខាងលើរឹតតែប្រសើរ ទោះបីយ៉ាងណាសាលារៀនត្រូវតែរៀបចំឱ្យបានខ្លះ។



#### ខ. ការថែទាំ

- ឧស្សាហ៍លាងសំអាត លាបថ្នាំថ្មី ជួសជុល កាត់ស្មៅ និងស្រោចទឹកស្មៅតាមស្ថានភាពជាក់ស្តែង។
- បើអាចគួរមានដំបូលប្រក់ការពារកុំឱ្យខូច សឹក ហើរពណ៌ និងបានជាម្លប់សម្រាប់កុមារលេង។



ក្រៅពីសកម្មភាពថ្នាក់ យើងអាចប្រើទីកន្លែងនេះសម្រាប់ព្រឹត្តិការណ៍សាលារៀនផ្សេងៗបានផងដែរ

## ឧទាហរណ៍

### ល្បែងដណ្តើមស្លឹកឈើ





ល្បែងដណ្តើមស្លឹកឈើរៀបចំឡើង ដើម្បីធ្វើឱ្យកុមារទទួលបានភាពសប្បាយរីករាយ និងបានសិក្សារៀនសូត្រពីបរិយាកាសជុំវិញសាលារៀន ព្រមទាំងអភិវឌ្ឍការធ្វើចលនារបស់កុមារ។ ល្បែងដណ្តើមស្លឹកឈើមានចំនួនអ្នកលេង ២ ក្រុម ដោយក្នុងមួយក្រុមមានគ្នា៤នាក់(អាចមានច្រើនជាងនេះ អាស្រ័យលើស្ថានភាពជាក់ស្តែង)។ មានក្រុមអ្នកលើកទឹកចិត្ត នៅឈរចាំមើល។

| | |
|---|---|
| មុខវិជ្ជា | - ចិត្តចលភាព(ល្បែងដណ្តើមស្លឹកឈើ) |
| វត្ថុបំណង | វិជ្ជាសម្បទា៖<br>- ប្រាប់បានពីឈ្មោះល្បែង ចំនួនក្រុម ចំនួនមនុស្សក្នុងក្រុម អាជ្ញាកណ្តាល និងរបៀបលេងបានត្រឹមត្រូវ។<br>បំណិនសម្បទា៖<br>- កំណត់បានច្បាស់នូវលេខតំណាងឱ្យខ្លួន និងលេខតំណាងឱ្យអ្នកដទៃ នៅពេលអនុវត្តជាក់ស្តែងជាមួយដៃគូ ឬគូជំនួយ<br>- ផ្លាស់ប្តូរទីដោយភាពរហ័សរហួន បត់បែនបានច្បាស់លាស់ ផ្អែកលើស្ថានភាពលេងជាក់ស្តែង។<br>ចរិយាសម្បទា៖<br>- បណ្តុះបាននូវស្មារតីប្រុងប្រយ័ត្ន និងភាពរហ័សរហួនខ្ពស់<br>- ស្រឡាញ់ និងសប្បាយរីករាយលេងដណ្តើមស្លឹកឈើជាមួយមិត្តភក្តិ<br>- ចេះសហការគ្នារកគន្លឹះយកជ័យជំនះលើគូប្រកួត។ |

| | |
|---|---|
| ថ្នាក់ និងអាយុ | - កម្រិតខ្ពស់ ៥ឆ្នាំ |
| រយៈពេល | - ៣០ នាទី |
| សម្ភារៈ | - ស្លឹកឈើ កាតលេខសម្គាល់សម្រាប់គ្រូ និងកុមារ |
| របៀបលេង | - ចែកកុមារជា២ក្រុម ដែលក្រុមនីមួយៗមានចំនួនកុមារស្មើគ្នាពី៤ ឬ៥ ឬ៦នាក់ក្នុងមួយក្រុម<br>- ក្រុមទាំងពីរឈរទល់មុខគ្នានៅលើខ្សែចម្ងាយពីគ្នា៨ ទៅ១០ម៉ែត្រ<br>- នៅចំពាក់កណ្តាលរវាងក្រុមទាំង២ គេដាក់ស្លឹកឈើមួយមែកតូច<br>- មុនចាប់លេងក្រុមនីមួយៗពិគ្រោះពិភាក្សាគ្នាដើម្បីកំណត់លេខសម្គាល់ខ្លួនឈរឱ្យត្រូវតាមលេខរៀងដោយគិតចាប់ពីលេខ១ ទៅដល់លេខចុងក្រោយនៃចំនួនកុមាររបស់ក្រុម<br>- នៅពេលឮអាជ្ញាកណ្តាលហៅលេខ ណាមួយកុមារក្នុងក្រុមដែលមានលេខនោះ ត្រូវរត់ទៅ ដណ្តើមស្លឹកឈើដែលនៅចំកណ្តាលឱ្យបានទាន់ហើស និងរត់សំដៅមកទីរបស់ខ្លួនវិញ។ ប្រសិនបើកុមារដៃគូម្ខាងទៀតដេញចាប់មិនបានទេ កុមារដែលកាន់ស្លឹកឈើមកដល់ខាងទីរបស់ខ្លួនជាអ្នកឈ្នះ<br>- ក្រុមណាដែលដណ្តើមស្លឹកឈើបានច្រើនដងជាងគេ គឺជាអ្នកឈ្នះ។<br>*បញ្ជាក់៖ គ្រូអាចជំនួសលេខ ជាសញ្ញាសម្គាល់ផ្សេងៗទៀត ដូចជា ពណ៌ តួអក្សរ រាងធរណីមាត្រ សត្វជាដើម។* |
| លក្ខខណ្ឌ | - គ្រូត្រូវពន្យល់ពីលក្ខខណ្ឌដល់កុមារមុនពេលលេង<br>- អ្នកលេងត្រូវស្តាប់អាជ្ញាកណ្តាលហៅលេខ ឬសញ្ញាសម្គាល់របស់ខ្លួន<br>- អ្នកដែលកាន់ស្លឹកឈើរត់ទៅដល់ទីដោយដៃគូប្រកួតចាប់ ឬប៉ះមិនបានគឺជាអ្នកឈ្នះ<br>- អ្នកកាន់ស្លឹកឈើលើកផុតពីដី ហើយត្រូវបានគេប៉ះ(លេខ១ និងលេខ១) ជាអ្នកចាញ់<br>- អ្នកចាប់កាន់ស្លឹកឈើប្រសិនបើគិតថារត់មិនរួច អាចទម្លាក់ស្លឹកឈើក្នុងរង្វង់វិញបាន ក្នុងករណីដៃគូមិនទាន់ប៉ះ។ |

## ១. ការរៀបចំបរិស្ថាន និងការចូលរួមរបស់គ្រូ

### បរិស្ថាន

- គ្រូត្រូវពិនិត្យទីកន្លែងដែលត្រូវនាំកុមារលេងថាមានសុវត្ថិភាពជាមុនសិន មុននឹងនាំកុមារលេង
- ចែកកុមារជា២ក្រុម
- គ្រូរៀបចំសកម្មភាពនេះនៅទីធ្លាសម្រាប់ធ្វើសកម្មភាពផ្សេងៗ
- រៀបចំកន្លែងសម្រាប់អ្នកឈរមើល និងគាំទ្រនៅអមសងខាង
- រៀបចំលេខសម្គាល់បិទលើអ្នកលេងម្នាក់ៗ។



### ការចូលរួមរបស់គ្រូ

- ពន្យល់កុមារពីលក្ខខណ្ឌនៃការលេងល្បែងដណ្ដើមស្លឹកឈើ
- រៀបចំកុមារឱ្យឈរនៅកន្លែងទីតាំងលេង
- ចាប់ផ្ដើមសាកល្បងលេងបង្ហាញឱ្យកុមារយល់សិន
- ជួយសម្របសម្រួលកុមារឱ្យដំណើរការលេងបានសម្រេច ដូចជាគ្រូចូលរួមលេងជាមួយកុមារ ធ្វើជាអាជ្ញាកណ្ដាល
- ព្យាយាមបង្វែរអារម្មណ៍កុមារឱ្យផ្ដោតទៅលើការលេងល្បែងនេះ
- លើកទឹកចិត្តដល់ក្រុមដែលលេងចាញ់ ឱ្យខំប្រឹងបន្តទៀត។





## ២. សកម្មតាពឆ្លើយតបរបស់កុមារ និងលទ្ធផល

ពេលលេងល្បែងដណ្ដើមស្លឹកឈើ គ្រូបានហៅគូលេខ១មុន។ កុមារលេខ១ទាំងពីរក្រុមបានរត់តម្រង់ស្លឹកឈើតែមិនដឹងថាត្រូវធ្វើអ្វី។ ស្របពេលនោះដែរមានកុមារម្នាក់ក្នុងក្រុមក្រហមដែលបានយល់ពីល្បែងនោះ ស្រែកប្រាប់ទៅកាន់សមាជិកក្រុមថា «ឆក់មក ឆក់យកស្លឹកឈើមក ហើយរត់មកនេះមក» ពេលនោះកុមារលេខ១(ក្រុមក្រហម) ក៏បានឆក់ហើយរត់តាមសមាជិកប្រាប់។ អ្នកឈរមើលមានអារម្មណ៍ភ័យអរជំនួសអ្នកលេង រីឯអ្នកគាំទ្រក្រុមអ្នកឈ្នះបាន ក្រឡុកបន្លឺសំលេងលើកទឹកចិត្តដល់អ្នកឈ្នះ។ ករណីដែលកុមារឈ្នះគឺគ្រាន់តែព្យាយាមរត់ទៅយកឱ្យបានលឿន ហើយរត់ត្រឡប់មកទីវិញ។ គ្រូគិតថាការលេងល្បែងម្ដងនេះកុមារធ្វើបានល្អភាគច្រើន បើទោះបីជាការលេងលើកដំបូង ហើយកុមារបានរៀនចំណាំលេខរបស់ខ្លួន ដឹងពីអ្វីដែលខ្លួនត្រូវធ្វើ។

ល្បែងដណ្ដើមស្លឹកឈើនេះនៅមានចំណុចមួយចំនួនដើម្បីធ្វើការកែលម្អសម្រាប់ពេលលេងលើកក្រោយ៖

- ល្បែងនេះមានភាពស្មុគស្មាញបន្តិច ទម្រាំកុមារបានយល់ពីរបៀបលេង។ ក្នុងរយៈពេល៣០នាទី អាចលេងបានតែមួយក្រុម។ ដូច្នេះ សម្រាប់ការលេងលើកក្រោយគ្រូគួរតែបន្ថែមម៉ោង ឬកំណត់នាទីណាមួយដើម្បីលេងឱ្យបានច្រើនក្រុមជាងនេះ។ ការកំណត់ទីតាំងសម្រាប់រត់ដូចជាឆ្ងាយពីគ្នាបន្តិច ដូច្នេះតម្រូវឱ្យគ្រូស្រែកខ្លាំង។ យកល្អគួររៀបចំឱ្យមានឧបករណ៍បំពងសំឡេង ឬដាក់ទីឱ្យជិតគ្នាជាការល្អ។
- គ្រូសង្ឃឹមថាកុមារនឹងធ្វើការងារជាក្រុមបានកាន់តែល្អប្រសើរឱ្យសមស្របនឹងលទ្ធផលរំពឹងទុករបស់សកម្មភាពនៅពេលក្រោយ។


ក្រុមលើកទឹកចិត្តស្រែកឱ្យអ្នកលេងខំប្រឹង


គ្រូបានជួយសម្រួលដល់កុមារ


ព្យាយាមរត់ចាប់ដើម្បី ទទួលបានជ័យជំនះ

## ៥. កន្លែងទុកដាក់សំរាម



### ការរៀបចំ

ដើម្បីឱ្យកុមារមានទម្លាប់ទុកដាក់សំរាមបានត្រឹមត្រូវ គ្រូត្រូវ៖

- ដាក់ធុងសំរាមតូចល្មមនៅជិត និងងាយស្រួលកុមារទុកដាក់សំរាម។
- ប្រមូលសំរាមពីធុង និងសម្អាតធុងសំរាមជាប្រចាំ។
- ណែនាំកុមារពីរបៀបចោលសំរាម តាមដានកុមារចោលសំរាម អប់រំកុមារឱ្យចេះរំឭកគ្នាទុកដាក់សំរាមតាមកន្លែងកំណត់។
- ការរៀបចំតារាងរូបភាពអប់រំកុមារពីការទុកដាក់សំរាមភ្ជាប់ទៅនឹងដើមឈើ ឬដាំបង្គោលណាមួយដែលកុមារឃើញរាល់ថ្ងៃ។



ធុងទុកដាក់សំរាមតាមប្រភេទ



មានសម្ភារៈអនាម័យគ្រប់គ្រាន់



## ៦. កន្លែងលាងដៃ



### ការរៀបចំ

ការរៀបចំកន្លែងលាងដៃសម្រាប់កុមារ គឺជាប្រការមួយសំខាន់មិនអាចខ្វះបាន ប៉ុន្តែក៏មិនតម្រូវឱ្យទំនើបពេកនោះទេ គឺអាស្រ័យតាមលទ្ធភាពថវិការបស់សាលារៀន។ កន្លែងលាងដៃដែលល្អ គឺរៀបចំឡើងមានលក្ខណៈសមស្របនឹងវ័យកុមារ មានអនាម័យមានលក្ខណៈទាក់ទាញមិនប្រឹងឈរជំទើតជើង ចំកោងខ្លួនលាងដៃ មិនខ្ទាតទឹកប្រឡាក់ខ្លួន មានសាប៊ូ ក្រដាសជូតដៃ ឬកន្សែងជូតដៃ និងមានរូបភាពអំពីរបៀបលាងដៃ។ ជាពិសេស គ្រូរៀបចំកន្លែងលាងដៃដែលអាចបង្ហូរទឹកស្រោចដំណាំ ដើម្បីឱ្យកុមារមើលឃើញ និងបណ្ដុះនិស្ស័យសន្សំសំចៃ។ ជានិច្ចជាកាល កុមារត្រូវការលាងដៃញឹកញាប់ជាពិសេសនៅពេលធ្វើសកម្មភាព ដូច្នេះការរើសទីតាំងកន្លែងលាងដៃនៅជិតថ្នាក់រៀនបង្កលក្ខណៈងាយស្រួលដល់កុមារ។



## ៧. បន្ទប់អនាម័យ



### ការរៀបចំ

ថ្វីត្បិតតែកុមារនៅតូចប៉ុន្តែកុមារក៏ត្រូវការបង្គន់ស្អាតមានអនាម័យងាយស្រួលបន្ទោរបង់។ ដូច្នេះ សាលារៀនត្រូវរៀបចំបន្ទប់ទឹក និងបង្គន់អនាម័យ សម្រាប់កុមារា កុមារីដាច់ដោយឡែកពីគ្នា ដើម្បីងាយស្រួលសម្អាត និងគ្រប់គ្រងកុមារ។ យើងលើកទឹកចិត្តឱ្យគិតពិចារណាឧបករណ៍ក្នុងបង្គន់អនាម័យសមស្របនឹងវ័យរបស់កុមារតាមលទ្ធភាព។ លើសពីនេះ សាលារៀនអាចប្រើប្រាស់ផ្ទាំងរូបភាព ឬសញ្ញាផ្សេងៗដើម្បីឱ្យកុមាររៀនពីរបៀបប្រើប្រាស់ និងថែទាំបង្គន់បានត្រឹមត្រូវ ដូចជារបៀបលាងដៃ របៀបអង្គុយលើចានបង្គន់ សញ្ញាត្រូវឈរសម្រាប់ការបត់ជើងតូចជាដើម។







កន្លែងបន្ទោបង់ និងលាងដៃក្នុងបង្គន់អនាម័យសមស្របសម្រាប់កុមារតូច


ឧបសម្ព័ន្ធ
160g

## ១. ឧទាហរណ៍ប្លង់នៃការរៀបចំថ្នាក់រៀនមត្តេយ្យសិក្សារដ្ឋ







**សម្គាល់:**

១. ធ្នើរដាក់ស្បែកជើងរបស់កុមារ
២. ក្តារខៀនព័ត៌មានសម្រាប់មាតាបិតា
៣. ជ្រុងអនាម័យ
៤. តារាងទាំង៧
៥. ជ្រុងសិក្សា
៦. ជ្រុងល្បែង
៧. ជ្រុងសិល្បៈ
៨. កន្លែងដាក់សម្ភារៈ និងសម្លៀតរបស់កុមារ
៩. ជ្រុងវិទ្យាសាស្ត្រ
១០. កន្លែងធ្វើសកម្មភាពផ្សេងៗក្នុងថ្នាក់

* ការរៀបចំកន្លែង ឬជ្រុងនីមួយៗមានការបត់បែនខ្លះទៅតាមស្ថានភាពបន្ទប់រៀន និងសង្ហារិមរបស់សាលានីមួយ។



ការរៀបចំប្លង់បន្ទប់ជាក់ស្តែង

## ២. ការរៀបចំថ្នាក់រៀនសម្រាប់បន្ទប់១ប្រើប្រាស់២វេន

បញ្ហាកង្វះថ្នាក់រៀន និងកង្វះខាតគ្រូបង្រៀន ខណៈពេលដែលមានកំណើនកុមារមត្តេយ្យសិក្សានៅតាមបណ្តាសាលារៀនបានតម្រូវឱ្យសាលាមួយចំនួនដំណើរការថ្នាក់មត្តេយ្យសិក្សាពីរវេនសម្រាប់បន្ទប់រៀនមួយ។ ក្នុងករណីនេះ ការរៀបចំថ្នាក់មត្តេយ្យសិក្សាតម្រូវឱ្យមានការបត់បែន ដើម្បីឱ្យដំណើរការបង្រៀន និងរៀនមានសភាពរលូន។ ក្នុងផ្នែកនេះ យើងសូមលើកឡើងតែលើការប្រើប្រាស់ស្លាកសញ្ញាសម្គាល់ និងជ្រុងមួយចំនួនទៀតប៉ុណ្ណោះ។

នេះជាបទពិសោធរបស់គ្រូមត្តេយ្យសិក្សាដែលបានអនុវត្តន៍ក្នុងគម្រោង «ធ្វើឱ្យប្រសើរឡើងគុណភាពអប់រំកុមារតូច ក្នុងមត្តេយ្យសិក្សារដ្ឋ ក្នុងខេត្តបាត់ដំបង» (ECE)។ សូមជ្រើសរើសយករបៀបណាមួយដែលអ្នកគិតថាសមស្រមនឹងបរិបទសាលារបស់ខ្លួន។ ការពិភាក្សាគ្នាដើម្បីរកដំណោះស្រាយជាមធ្យោបាយមួយដ៏ប្រសើរបំផុត។

### ២.១. ធ្នើរដាក់ស្បែកជើង



- របៀបទី១៖ បិទស្លាកសញ្ញាពីរផ្សេងគ្នា មួយនៅខាងក្នុង និងមួយនៅខាងក្រៅសម្រាប់ថ្នាក់ព្រឹក និងរសៀល។



- របៀបទី២៖ បិទស្លាកសញ្ញាសម្គាល់២ទទឹមគ្នា ខាងឆ្វេងសម្រាប់ថ្នាក់ព្រឹក ខាងស្តាំសម្រាប់ថ្នាក់ល្ងាច។ ស្លាកសញ្ញាអាចបិទនៅផ្នែកខាងមុខ ឬផ្នែកខាងក្នុង។



- របៀបទី៣៖ បិទស្លាកសញ្ញាតែមួយ ឬពីរសម្រាប់កុមារទាំងពីរនាក់ តែមិនសរសេរឈ្មោះទេ។

### ២.២.កៅអីកុមារ

- របៀបទី១៖ បិទស្លាកពីរទន្ទឹមគ្នា មួយសម្រាប់ថ្នាក់ព្រឹក និងមួយសម្រាប់ថ្នាក់ល្ងាច ហើយសរសេរឈ្មោះកុមារធម្មតា។ អាស្រ័យលើស្ថានភាពកៅអី ទទឹមគ្នា ឬលើក្រោម។



- របៀបទី២៖ បិទស្លាកតែមួយសម្រាប់កុមារទាំងពីរវេន។ មិនចាំបាច់សរសេរឈ្មោះព្រោះទំហំស្លាកសញ្ញាបិទនៅលើកៅអីមានសណ្ឋានតូច។



### ២.៣.កន្លែងដាក់សំពៀតកុមារ

- របៀបទី១៖ បិទស្លាកពីរទន្ទឹមគ្នា មួយសម្រាប់ថ្នាក់ព្រឹក និងមួយសម្រាប់ថ្នាក់ល្ងាច ហើយសរសេរឈ្មោះកុមារ។



- របៀបទី២៖ បិទស្លាកសញ្ញាម្ខាងម្នាក់ ម្ខាងសម្រាប់ពេលព្រឹក ម្ខាងសម្រាប់ពេលល្ងាច។ នៅចុងម៉ោង ណែនាំជាប្រចាំឱ្យកុមារត្រឡប់ប្រអប់ឱ្យឃើញស្លាកសញ្ញារបស់កុមារនៅវេនមួយទៀត (បើកុមារមានស្លាកសម្គាល់រូបផ្កាក្រោក ត្រឡប់ឱ្យរូបផ្កាកុលាបមកខាងមុខវិញម្តង)។



- របៀបទី៣៖ បិទស្លាកតែមួយសម្រាប់កុមារទាំងពីរនាក់ប្រើរួមគ្នា តែមិនសរសេរឈ្មោះ។



## ២.៨.ជ្រុងសិល្បៈ

- <u>របៀបទី១៖</u> បែងចែកចំនួនផ្ទាំងជ្រុងសិល្បៈជាពីរស្មើគ្នា។ ទោះបីជាយ៉ាងនេះក្តី ទំហំផ្ទាំងកាន់តែតូចបើសិនជាក្នុងថ្នាក់មានចំនួនកុមារច្រើន( មានរូបត្រូវតាំងច្រើន តែកន្លែងតាំងមានតូច )។
- <u>របៀបទី២៖</u> ចែករយៈពេលគ្នាប្រើមួយសប្តាហ៍ម្នាក់។

## ២.៩.ជ្រុងបណ្ណាល័យ

បញ្ហាដែលចោទខ្លាំងនៅលើជ្រុងនេះគឺការគ្រប់គ្រងសៀវភៅ ការដំណើរសេវាកម្មខ្ចីសងសៀវភៅ និងការរៀបចំទុកដាក់របស់កុមារនៅពេលអានរួច។

- គ្រូទាំងពីរអាចកំណត់អ្នកដែលគ្រប់គ្រងបញ្ជីរួម និងបញ្ជីសារពើភ័ណ្ឌ ឬសហការធ្វើរួមគ្នាតែម្តងនៅពេលទទួលបានសៀវភៅថ្មី។
- សម្រាប់សេវាកម្មខ្ចីសង អាចប្រើប្រាស់បញ្ជីរួមគ្នា ឬធ្វើដាច់រៀងខ្លួន។
- គ្រូនីមួយៗត្រូវពិនិត្យថាសៀវភៅត្រូវបានរៀបចំបានល្អ។ ធ្វើដូច្នេះចំពោះផ្នែកដទៃទៀតដែរ ដូចជាជ្រុងសម្ភារៈរៀន ជ្រុងអនាម័យ ការរៀបចំតុ និងកៅអី។



## ឯកសារយោង


- កម្មវិធីមត្តេយ្យសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ ដោយនាយកដ្ឋានអប់រំកុមារតូច នៃក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨។
- ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ដោយនាយកដ្ឋានអប់រំកុមារតូច នៃក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៣។
- ឯកសារ Investing in young children, An early childhood developent guide for poicy dialogue and project preparation បោះពុម្ពឆ្នាំ២០១១ ដោយធនាគារពិភពលោក។
- ឯកសារ Early Childhood Environment Rating Scale បោះពុម្ពឆ្នាំ២០១៥ ដោយ Thelma Harms, Richard M. Clifford និង Debby Cryer។